១.លោក ឱកសេរីសោភក្តិ

ទី៤យើងនឹងជូនសំដីនេះទៅបងៗទាំងអស់បងស្រី បងប្រុសដែលមានវត្តមាននៅទីនេះតាមខ្សែរភ្នែករបស់បង បងមើលឃើញថាស្ថានការរៀបចំបោះឆ្នោតសំរាប់២០០៧នឹង២០០៨យើងមើលឃើញបញ្ហាអ្វីខ្លះ? ហើយយើងចូលរួមដោះស្រាយជាមួយគ្នាយ៉ាងម៉េចខ្លះបាន។ ទី៥ផ្សេងៗបើសិនមានបញ្ហាអ្វីទៀតយើងនឹងពិភាក្សាតាមដំណើរ។ នៅក្នុងព្រឹកនេះដែរលោក ឡារី ស្ត្រេន្ទ លោកមានហេតុការណ៍ជួបជាមួយនិងឯកឧត្តមអភិបាលនៅម៉ោង១០កន្លះ ដូច្នេះលោកសូមអនុញ្ញាតចេញទៅជួបមួយភ្លែតហើយ ហើយនិងត្រឡប់មកបន្តទៅទៀត។ ដូច្នេះដើម្បីជាកិច្ចចាប់ផ្តើមខ្ញុំព្រះករុណាខ្ញុំសូមអញ្ជើញលោក ឡារី ស្ត្រេន្ទ ដែលជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI លោកអញ្ជើញមានមតិស្វាគមន៍។

២.លោក ឡារី ស្ត្រេន្ទ

ជាបឋមខ្ញុំព្រះករុណាខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គគ្រប់ព្រះអង្គដែលបាននិមន្តមកក្នុងថ្ងៃនេះនិងសូមគោរពចំពោះអស់លោកលោកស្រីដែលបានអញ្ជើញមកក្នុងថ្ងៃនេះ។ មុននិងចាប់ផ្តើមនេះខ្ញុំបាទសូមអធ្យាស្រ័យដោយខ្ញុំបាទមិនអាចនិយាយភាសារខ្មែរបានខ្ញុំបាទសូមនិយាយជាភាសារអង់គ្លេស។ថ្ងៃនេះជាកិត្តិយសណាស់ដែរខ្ញុំព្រះករុណាខ្ញុំក្នុងតំណាងជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI មានកិត្តិយសក្នុងការបើកកិច្ចប្រជុំខប់សែលប្រ៉មនៅក្នុងខេត្តរតនៈគីរីនេះ។ ខ្ញុំព្រះករុណាខ្ញុំសូមនូវសំដែងការស្វាគមន៍ចំពោះលោកប៉ែន ឈុនឌី ដែលជាប្រធានគណៈកម្មាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តរតនៈគីរីដែលលោកបានគាំទ្រចូលរួមនៅក្នុងកម្មវិធីនេះ។ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំព្រះករុណាខ្ញុំសូមស្វាគមន៍និងសូមថ្លែងអំណរគុណចំពោះខាងរដ្ឋបាលមូលដ្ឋានខេត្តរតនៈគីរីដែលបានចូលរួមនៅក្នុងថ្ងៃនេះដែលបានជួយជាប្រចាំនៅក្នុងការចែករំលែកនឹងជាពិសេសការជួយបញ្ជូននូវរាល់កំណត់ហេតុរបស់យន្តការខប់សែលទៅក្នុងខេត្តរតនៈគីរីនេះ។ខ្ញុំព្រះករុណាខ្ញុំសូមស្វាគមន៍និងសូមថ្លែងអំណរគុណផងដែរចំពោះតំណាងគ្រប់ស្ថាប័នជាពិសេសគឺតំណាងមកពីខាងសាលាខេត្តតំណាងអាជ្ញាធរស្រុកនិងជាពិសេសតំណាងឃុំនិងជាពិសេសលោកប្រធានតំណាងខាងផ្នែកលោកប៉ូលីសនិងតំណាងខាងស្ថាប័នពាក់ព័ន្ធនៅក្នុងខេត្តរតនៈគីរីយើងនេះ ហើយជាពិសេសតំណាងខាងអង្គការសង្គមស៊ីវិល ដែលធ្វើការនៅក្នុងខេត្តរតនៈគីរីនេះទៀតដែលបានចូលរួមនៅក្នុងកិច្ចប្រជុំខប់សែលប្រ៉មនៅក្នុងខេត្តរតនៈគីរីព្រឹកនេះ។ ខ្ញុំព្រះករុណាខ្ញុំសូមធ្វើការបង្ហាញបន្តិចទាក់ទងថាហេតុអ្វីបានជាវិទ្យាស្ថាន CDRI បានរៀបចំបង្កើតនូវកម្មវិធីរីយន្តការបង្ការទំនាស់និងបោះឆ្នោតនៅកម្ពុជានៅក្នុងថ្ងៃនេះ។ វិទ្យាស្ថាន CDRI ជា វិទ្យាស្ថានមួយដែលធ្វើការចំបងទៅលើការស្រាវជ្រាវមួយឯករាជ្យដែលការស្រាវជ្រាវនេះគឺជាការមួយដើម្បីជាការរៀបចំគោលនយោបាយផ្សេងៗ ខាងវិទ្យាស្ថាន CDRI បានធ្វើការយ៉ាងជិតស្និតជាមួយនិងស្ថាប័នផ្សេងៗទៀតពាក់ព័ន្ធនិងការស្រាវជ្រាវពាក់ព័ន្ធទៅនិងស្ថាប័នផ្សេងៗទាក់ទងទៅនឹងការអភិវឌ្ឍន៍ ដើម្បីរៀបចំជាគោលនយោបាយ ដើម្បីជូនជាអនុសាសន៍ជូនទៅខាងរាជរដ្ឋាភិបាល។វិស័យដែលខាងវិទ្យាស្ថាន CDRI ធ្វើការស្រាវជ្រាវទៅលើនោះមានដូចជាខាងផ្នែកសេដ្ឋកិច្ចនិងការធ្វើពាណិជ្ជកម្ម ផ្នែកខាងកាត់បន្ថយភាពក្រីក្រ ផ្នែកខាងអភិវឌ្ឍន៍ផ្នែកខាងកសិកម្ម ផ្នែកខាងការគ្រប់គ្រងធនធានធម្មជាតិ ផ្នែកខាងអភិបាលកិច្ចនិងកំណែរទំរង់ផ្នែករដ្ឋបាលជាពិសេសទៅទៀតនោះគឺ ផ្នែកសន្តិសុខមនុស្សដែលក្នុងនោះរួមមានទាំងការកសាងសន្តិភាពនិងការដោះស្រាយទំនាស់ផងដែរ។នៅក្នុងផ្នែករបស់វិទ្យាស្ថាន CDRI ដែលទាក់ទងទៅនិងអភិបាលកិច្ចប្រកបទៅដោយលក្ខណៈប្រជាធិតេយ្យនិងការកសាងសន្តិភាពនិងការដោះស្រាយទំនាស់ខាងវិទ្យាស្ថាន CDRI បានបង្ហាញពីឆន្ទៈយ៉ាងមុតមាំនៅក្នុងការធ្វើការសហការជាមួយនិងស្ថាប័នផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតាំងពីផ្នែករដ្ឋាភិបាល ខាងសង្គមស៊ីវិល និងភាគីដែលពាក់ព័ន្ធនានានៅក្នុងវិស័យផ្សេងៗដែលខាងវិទ្យាស្ថាន CDRI បានធ្វើដើម្បីពង្រឹងអភិបាលកិច្ចដើម្បីប្រកបទៅដោយលក្ខណៈប្រជាធិតេយ្យ។ ការដែលខាងវិទ្យាស្ថាន បានអនុវត្តនូវសកម្មភាពនិងកម្មវិធីទាំងអស់នេះគឺដោយសារតែវិទ្យាស្ថាន CDRI បានមើល

ឃើញថាការពង្រឹងនូវលទ្ធិប្រជាធិតេយ្យអោយបានស៊ីជម្រៅនិងពិតប្រាកដមែនទែន ជាជំហានតំបូងដែលសំខាន់បំផុតនៅក្នុងការជំរុញអោយមានការអភិវឌ្ឍន៏នានានៅគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ។ លោកឱកសេរីសោភក្ត៏ ដែលគាត់ជាទីប្រឹក្សានៃវិទ្យាស្ថាន CDRI និងជាអ្នកសម្របសម្រួលយន្តការ ខប់សែលនេះលោកនឹងបង្ហាញជូនអស់លោកលោកស្រីនៅក្នុងថ្ងៃនេះអោយបានលំអិតអំពីយន្តការវិធីខប់សែលហើយនឹងគោលបំណង ប៉ុន្តែឈ្លាតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ គ្រាន់តែសូមបង្ហាញជូនអំពីគោលបំណងដ៏សំខាន់មួយរបស់យន្តការខប់សែលនៅក្នុង ចំនុចនេះខ្ញុំព្រះករុណាខ្ញុំគ្រាន់តែសូមបង្ហាញជូនបន្តិចថាពាក្យថា ខប់សែលនេះគឺជាពាក្យអក្សរកាត់ដែលអក្សរពេញមានមកពាក្យថាយន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតនៅកម្ពុជា ដែលយើងហៅភាសារអង់គ្លេសថា Conflict Prevention in Cambodian Elections ហើយយន្តការនេះត្រូវបានបង្កើតឡើយដោយខ្មែរសុទ្ធសាធនិងជារបស់ខ្មែរនិងចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ពិភាក្សាផ្សេងៗដោយខ្មែរជាអ្នកចូលរួមសុទ្ធសាធ ហើយជាគោលបំណងសំខាន់នៅក្នុងការបង្កើតនូវយន្តការខប់សែលនេះឡើង គឺចង់ផ្តល់ឱកាសប្រគេនជូន ទៅព្រះតេជគុណអស់លោក លោកស្រី ពិភាក្សាលើកយកបញ្ហាណាដើម្បីដោះស្រាយនៅចំពោះមុខដោយត្រង់ទៅត្រង់មក ឆ្លៀតនៅក្នុងឱកាសនេះខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញជូនថាចាប់ពីយន្តការខប់សែលនេះបានបើកធ្វើសន្និសិទ្ធជាផ្លូវការនៅខែកក្កដាឆ្នាំ២០០៥បើកដោយតំណាងឯកឧត្តមប្រធានគជបនិងឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃមកគឺយន្តការខប់សែលនេះបានបើកនូវកិច្ចប្រជុំជាច្រើនទាំងថ្នាក់ជាតិថ្នាក់ខេត្តហើយនៅក្នុងកិច្ចប្រជុំទាំងឡាយនោះគឺយន្តការខប់សែលបានអញ្ជើញអ្នកចូលរួមប្រជុំជាច្រើន ដែលក្នុងនោះ អស់លោក លោកស្រី ជាតំណាងជាពិសេស បើនៅក្នុងថ្នាក់ជាតិគឺយើងមានឯកឧត្តមដែលលោកជាអគ្គលេខាធិការគជបដែលលោកជាអគ្គលេខាធិការគជបនៅក្នុងទីក្រុងភ្នំពេញតំណាងក្រសួងមហាផ្ទៃតំណាងគណបក្សនយោបាយនានា តំណាងអង្គការសង្គមស៊ីវិលដែរ ធ្វើការងារពាក់ព័ន្ធទៅនិងការបោះឆ្នោតដោយឡែកនៅក្នុងកិច្ចប្រជុំខប់សែលប្រ៉មនៅតាមខេត្តនិមួយៗនេះក៏ខាងយន្តការខប់សែលនេះបានអញ្ជើញអ្នកចូលរួមមកពី តំណាងពីខាងគ្រប់ស្ថាប័នដែលធ្វើការងារពាក់ព័ន្ធការបោះឆ្នោតនេះនិងដែលមានជា លោកប្រធានតំណាងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត លោកតំណាងអាជ្ញាធរខេត្ត និងលោកតំណាងអាជ្ញាធរឃុំស្រុក និងលោកខាងតំណាងប៉ូលីស លោកខាងតំណាងគណបក្សនយោបាយទាំងអស់ដែលលោកមានមូលដ្ឋាននៅក្នុងខេត្តនិមួយៗហ្នឹង និងតំណាងរបស់អង្គការ សង្គមស៊ីវិលនានាដែលធ្វើការនៅក្នុងខេត្តទាំងឡាយនោះការដែលរៀបចំកិច្ចប្រជុំនេះ ដើម្បីផ្តល់ឱកាសជូនអស់លោកលោកស្រីលើកឡើងបញ្ហាណាដែលកើតមានពាក់ព័ន្ធនិងកិច្ចការបោះឆ្នោតហើយជាកង្វល់របស់អស់លោកលោកស្រី ដើម្បីពិភាក្សានៅចំពោះមុខប្រកបទៅដោយការស្មោះត្រង់ដោយការត្រង់ទៅត្រង់មកការគោរពគ្នាជាទីបំផុត។ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ចប់តែត្រឹមនេះមិនហ៊ាននៅយូរពេលទេគឺគ្រាន់តែសូមស្វាគមន៏ចំពោះព្រះតេជគុណនិងអស់លោក លោកស្រី ដែលបានចំនាយពេលចូលរួមនៅក្នុងកិច្ចប្រជុំនៅក្នុងព្រឹកនេះ និងសូមជូនពរអស់លោកលោកស្រីនៅក្នុងកិច្ចប្រជុំព្រឹកនេះសូមអោយទទួលបានផ្លែផ្កានិងជោគជ័យជាទីបំផុត ។សូមថ្លែងអំណរគុណ

៣.លោកឱកសេរី សោភក្ត៏

ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកឡារី ស្រ្តេនដែលលោកមានប្រសាសន៏ជំរាបជូនបានយ៉ាងក្បោះក្បាយនូវអត្ថន័យដែលយើងមកជួបគ្នាប្រជុំថ្ងៃនេះ។ បន្ទាប់មកខ្ញុំព្រះករុណាខ្ញុំសូមធ្វើបទអត្ថាធិបាយដើម្បីបញ្ជាក់ថាតើខប់សែលនេះកើតចេញពីណាមក។ ខ្ញុំព្រះករុណាខ្ញុំបាទបានឆ្លងកាត់អាយុជាងកន្លះសតវត្សនេះខ្ញុំព្រះករុណាខ្ញុំបានឆ្លងកាត់ច្រើនណាស់និងជាពិសេសដោយសារខ្ញុំបាទមិនបាននៅពេលដែលប៉ុលពតនោះចូលមកខ្ញុំបាទបានទៅសិក្សាវិជ្ជាពេទ្យនៅប្រទេសបារាំង ប៉ុន្តែបានតាមដានសភាពការណ៏ហ្នឹងរួចហើយក៏ឃើញការសំលាប់រង្គាលហ្នឹងមើលតែពីចំងាយទេ ប៉ុន្តែដល់ពេល៨១ខ្ញុំបាទបានទៅតស៊ូនៅតាមជាយដែននៅក្នុងព្រៃទៅជាមួយអង្គការសេរីការជាមួយលោកប្រធានសឺនសាន ទៅធ្វើទាំងខាងនយោបាយធ្វើទាំងខាងទាហានជាទាហានរំដោះ

នោះហើយពេលនោះជាមួយនឹងការឃើញការស្លាប់រង្គាលនោះ ក៏បានឃើញប្រជាពលរដ្ឋរបស់យើងដែលទៅត្រូវស្លាប់បន្តទៅទៀត ស្លាប់ច្រើនណាស់ទាំងជាន់មីនទាំងគេធ្វើបាបគ្រប់កន្លែងទាំងអស់រួចដល់ចូលមកវិញឆ្នាំ១៩៩២ចូលមកវិញឃើញសភាពការណ៍បែបនេះ រួចក៏គិតថាស្រុកខ្មែរមិនគួរឆ្លងកាត់សភាពការណ៍បែបនេះទៀតទេ គួតែរកឃើញនូវការកែប្រែទំលាប់កែប្រែតវិយាបទកែប្រែគំនិត ការយល់ឃើញដើម្បីយ៉ាងណាអោយយើងអាចនិយាយរកគ្នាបានដោយមិនចាំបាច់កាប់សំលាប់គ្នា នៅពេលនោះ៩២ឯកឧត្តម ស ខេង លោកធ្លាប់ឈ្លោះគ្នាពីអតីតឆ្នាំ៩២ជួបគាត់ គាត់ស្នើរថាបងយើងធ្វើការជាមួយគ្នាទៅខ្ញុំថាមានអីឯកឧត្តមយើងធ្វើការជាមួយគ្នាទៅ យើងល្មមដល់ពេលដែលយើងអាចធ្វើការជាមួយគ្នាបាន លោកក៏ស្នើរអោយខ្ញុំធ្វើជាទីប្រឹក្សា និងជានាយកខុទ្ទការល័យរបស់លោក នៅទីស្តីការគណៈរដ្ឋមន្ត្រីជាទីប្រឹក្សារបស់ឧបនាយកមន្ត្រី ពេលនោះហើយដែលរៀបចំយន្តការបោះឆ្នោតឆ្នាំ១៩៩៨ហើយក្នុង៩៥នាំអ្នកឯកទេសមកច្រើនណាស់ ដើម្បីរៀបចំយន្តការបោះឆ្នោត ព្រោះឆ្នាំ៩៣អ៊ុនតាក់គេរៀបចំអោយ ហើយឆ្នាំ៩៨យើងរៀបចំខ្លួនយើង ហើយយើងអត់ដឹងអីទាំងអស់ហើយ៩៥យើងនាំអ្នកឯកទេសគ្រប់សកលលោកគ្រប់ប្រទេសមកចូលធ្វើការហ្នឹង ហើយយើងរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ហ្នឹងតាំងពី៩៤បទលិខិតបទដ្ឋានស្អី១មានទាំងអស់ ព្រោះកាលនោះយើងគ្រោងរៀបចំការបោះឆ្នោតតំបូងក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាម២000 ប៉ុន្តែដល់មានព្រឹត្តិការឆ្នាំ៩៧ទៅយើងក៏ប្រញាប់រៀបចំបោះឆ្នោត៩៨ ក៏រុញការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ពី២000ទៅ២00២។ នៅពេលនោះនៅពេលដែលខ្ញុំបាទនៅធ្វើការជាមួយឯកឧត្តមឧបនាយកនិងគឺថា ខ្ញុំបាទបានទៅធ្វើការសិក្សាច្រើនអំពីបញ្ហាវិប្បធមិសន្តិភាព ហើយទឹកចិត្តមួយដែលមានពីជាយដែនមកថា ខំធ្វើយ៉ាងណាគឺថាជីវិតដែលនៅសេសសល់ហ្នឹងខំធ្វើយ៉ាងណាកសាងយន្តការមួយដើម្បីអោយខ្មែរនិងខ្មែរអាចនិយាយរកគ្នាបានដោយមិនចាំបាចប្រើកាំភ្លើងទៀតគំនិតហ្នឹងគឺថាដក់ជាប់តាំងពីយូរមកដល់ពេលបានមកធ្វើដំណើរទៅច្រើនណាស់ ទៅរៀននៅអាមេរិក ទៅរៀននៅស្រុកក្រៅ រៀនពីបញ្ហាវិប្បធមិសន្តិភាពរួចហើយក៏មកធ្វើការជាមួយអង្គការCDRIនេះ ហើយនិងបានធ្វើការជាមួយអង្គការកាណាដា ពេលនោះគាត់បានមក CDRI មកស្អី១ទាំងអស់ហ្នឹងទៅរួចហើយយើងក៏បានរួមគ្នាបង្កើតនូវមជ្ឈមណ្ឌលមួយនៅក្នុងCDRI ហ្នឹងដែរយើងហៅថាមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់កាលនោះឆ្នាំ៩៥ ហើយសម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន លោកបានអញ្ជើញទៅបើកនិងបិទ ហើយក្នុងសុន្ទរកថាបិទរបស់លោកហ្នឹងលោកបានមានប្រសាសន៏ថា កាលនោះអ្នកស្រីអេវ៉ា គាត់ជាប្រធានមុនលោកឡារី ស្រេន្តនេះ ហើយគាត់ប្រាប់ថាអ្នកស្រីអេវ៉ាហើយនិងលោកសោភក្តិ៍ សូមបង្កើតមជ្ឈមណ្ឌលមួយទៅយើងខ្ញុំក៏បង្កើតឆ្នាំ៩៧-៩៨ហ្នឹងក៏បង្កើតមជ្ឈមណ្ឌលហ្នឹងឡើង។ ខ្ញុំបាទដល់ធ្វើការជាប់អញ្ចឹងទៅ ហើយ៩៩ក៏ចេញពីរាជរដ្ឋាភិបាល ព្រោះខ្ញុំបាទធ្វើការ៥ឆ្នាំជាមួយរាជរដ្ឋាភិបាលឃើញថាបានស្គាល់សព្វគ្រប់អស់ហើយ ចង់ទៅស្គាល់អង្គការមិនមែនរាជរដ្ឋាភិបាលនោះយ៉ាងម៉េចខ្លះចង់ទៅសិក្សា៥ឆ្នាំទៀត នៅពេលនោះហើយដែលខ្ញុំបាទបានធ្វើជាអ្នកសម្របសម្រួលកម្មវិធីដោះស្រាយទំនាស់និងអភិវឌ្ឍន៏របស់អង្គការCDRIនេះ។ ឆ្នាំ៩៩ខ្ញុំបាទក៏មានពេលយកគំនិតដែរដុះចាក់រឹសពីជាយដែនមកហើយបានរៀនសមស្របទៀតនោះ ក៏បានបង្កើតនូវយន្តការខប់សែលនេះឡើងដោយសារឃើញថាឆ្នាំ៩៨យើងបោះឆ្នោតនោះ យើងឈ្លោះគ្នាច្រើនពេករួចហើយមានរូបភាពអាក្រក់ណាស់ ដែលទៅតាមរយ:CNN ទៅបញ្ចាំងអោយពិភពលោក កាលនោះយើងឃើញហើយព្រះសង្ឃបានទទួលការធ្វើបាបនៅតាមផ្លូវនៅតាមអ្វី១នោះ គឺថាខ្ញុំព្រះករុណាហ្នឹងគឺស្លុតបំផុតដែលរូបភាពឃោឃៅហ្នឹងបានជ្រះទៅដល់ពិភពលោកទាំងមូល។ បានខ្ញុំបាទគិតថាត្រូវតែយន្តការបោះឆ្នោតនៅកម្ពុជាលែងមានអំពើរហឹង្សាទៀត បានជា៩៩ធ្វើការនៅCDIR ហ្នឹង ក៏នឹកឃើញស្រមៃគូសវែសនូវយន្តការខប់សែលនេះឡើង ដើម្បីបង្ការទំនាស់នៅក្នុងយន្តការបោះឆ្នោតនៅកម្ពុជាហើយនៅពេលនោះហើយបានដូចពេលលោកឡារីស្រេន្តលោកនិយាយថាយន្តការខប់សែលនេះគឺស្រម័យគិតឡើងដោយខ្មែរខ្លួនឯងអនុវត្តដោយខ្មែរខ្លួនឯងហើយខ្មែរខ្លួនឯងជាម្ចាស់។ កាលនោះយើងបានធ្វើការប្រជុំគ្នា៥0ដងគឺថា៤ឆ្នាំរាល់ខែមិនដែលខានទេ ហើយរាជរដ្ឋាភិបាលដែលមានសម្តេចនាយក ហើយនិងឯកឧត្តមឧបនាយកហ្នឹង គឺថាលោកគាំទ្រ

តែម្តងគណបក្សធំៗទាំង៣លោកចូលរួម ក្រសួង៥របស់រាជរដ្ឋាភិបាលក៏ចូលរួម ហើយឯកឧត្តមអ៊ឹមសួស្តីដែលកាលនោះលោកជាអគ្គលេខាធិការនៅឡើយនោះគជបដែរលោកតាឆេងផុនលោកជាប្រធានកាលនោះលោកមកជំនុំរាល់ពេលទាំងអស់រួចហើយអង្គការសង្គមស៊ីវិលអង្គការអន្តរជាតិធំៗ ក៏បានចូលរួមប្រជុំពេលនោះ ខ្ញុំបាទនៅចាំច្បាស់ជំនុំពីរបីដងតំបូង គណបក្សជំទាស់គណបក្សឯកឧត្តមសមរង្ស៊ីដែលខ្ញុំបាទក៏ពួកម៉ាកគាត់ដែលនៅរៀនស្រុកបាំរាំងជាមួយគ្នា ប៉ុន្តែខ្ញុំបាទមិនមានគោលនយោបាយទេ ខ្ញុំបាទបានចូលធ្វើរាជរដ្ឋាភិបាលប៉ុន្តែខ្ញុំបាទមិនចូលចិត្តប្រកាន់នយោបាយទេ សម្តេចក្រុងព្រះក៏ខ្ញុំបាទថ្វាយបង្គំព្រោះធ្លាប់ធ្វើការជាមួយគ្នានៅជាយដែនរួចហើយឯកឧត្តមសមរង្ស៊ីក៏ជាពួកម៉ាក ប៉ុន្តែCPPខ្ញុំបាទក៏ធ្លាប់ធ្វើការជាមួយឯកឧត្តម ស ខេង ហើយនិងសម្តេចនាយក ដូច្នេះហើយបានជាខប់សែលហ្នឹងគ្មានគោលនយោបាយទេ គោលបំណងតែមួយគត់គឺចង់អោយជជែកជាមួយគ្នាថា ព្រោះសង្គមខ្មែរយើងបើសិនជាខ្ញុំបាទថាខុសក៏ថាអោយខ្ញុំបាទចុះ ប៉ុន្តែខ្ញុំបាទតែងតែសង្កេតឃើញថា យើងចូលចិត្តនិយាយពីក្រោយខ្នងគ្នាហ្នឹងច្រើនណាស់ ប៉ុន្តែនៅពេលដែលយើងនៅមុខគ្នាយើងមិនសូវនិយាយទេយើងចូលចិត្តញញឹមដាក់គ្នាប៉ុន្តែដល់ពេលដែរបែរខ្នងដាក់គ្នាយើងវ៉ាត់គ្នាមួយរយៗតែម្តង ខ្ញុំបាទគិតថាយើងធ្វើបែបនេះយូរៗទៅឈ្លោះគ្នាហើយ បើមានអ្វីដែលមិនពេញចិត្តនិយាយនៅនិងមុខគ្នាហ្នឹងតែម្តងទៅ។ ដូច្នេះយន្តការខប់សែលធ្វើការអញ្ចឹងកាលពីពីរបីតំបូងខាងឯកឧត្តមសមរង្ស៊ីនិងគណបក្សប្រជាជនអត់មើលមុខគ្នាទេ ជំនុំខប់សែលពីរបីតំបូងខែសីហាឆ្នាំ៩៩ខែកញ្ញាឆ្នាំ៩៩ហ្នឹង ប៉ុន្តែដល់បីបួនដងក្រោយមកគាត់គៀកគ្នាទៅញ៉ាំបាយជាមួយគ្នាមិនអោយទាំងដឹងទៅទៀតគាត់បន្តទៅជជែកគ្នា មិនបានសេចក្តីថាគាត់ត្រូវគាត់ទេ ក៏ប៉ុន្តែខ្ញុំបាទសង្កេតឃើញថានៅពេលដែលគាត់មានឳកាសនិយាយគ្នាអស់ចិត្តអស់ចង់ទៅគាត់ចាប់ផ្តើមយល់គ្នាថាហេតុអី បានជាម្នាក់ទៀតយល់ខុសគ្នាពីគាត់ ដល់អញ្ចឹងទៅគាត់ចាប់ផ្តើមគោរពភាពខុសគ្នានៃមតិនយោបាយដែលទាក់ទងទៅនិងរឿងបោះឆ្នោតការគោរពហ្នឹងហើយ ដែលចាក់រឹសនៅក្នុងវប្បធម៌នៃការជជែកពិភាក្សាគ្នានេះហើយជារឿងសំខាន់ណាស់យើងធ្វើបែបនេះរហូតដល់យើងបានធ្វើការបោះឆ្នោតនៅឆ្នាំ២០០២ ហើយការបោះឆ្នោតនៅឆ្នាំ២០០៣។ យន្តការខប់សែលក៏បានបញ្ចប់នៅខែកញ្ញាឆ្នាំ២០០៣ ខ្លួនខ្ញុំបាទផ្ទាល់ដែលជាស្ថាបត្យករនៃយន្តការនេះក៏យើងគិតថាបញ្ចប់ហើយព្រោះគេធ្វើការទៅហើយគេជជែកអីហើយទៅ ក៏ប៉ុន្តែនៅឆ្នាំ២០០៤នេះខាងអង្គការសហប្រជាជាតិUNDPដែលយើងសូមឆ្លៀតឳកាសនេះដែរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ លោកបានមើលនូវឯកសារខប់សែលហ្នឹងទាំងអស់ ហើយលោកបានមកទាក់ទងលោក ឡារី ស្ត្រេន្ទ ហើយនិងខ្ញុំបាទថាកម្ពុជាមានរៀបចំបោះឆ្នោតព្រឹទ្ធសភា២០០៦បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់លើកទីពីរ២០០៧បោះឆ្នោតថ្នាក់ជាតិ២០០៨ ហេតុអីក៏អ្នកឯងមិនបន្តយន្តការហ្នឹងទៅ យន្តការហ្នឹងល្អណាស់ ដល់យើងមានការគាំទ្រយ៉ាងខ្លាំងហើយថវិការគាត់អោយមកហ្នឹងក៏ច្រើនគួរសមដែរ បានយើងក៏យល់ព្រមលោក ឡារី ស្ត្រេន្ទ ក៏លោកយល់ព្រមខ្ញុំបាទក៏យល់ព្រមធ្វើជាអ្នកសម្របសម្រួលតទៅទៀត ប៉ុន្តែពេលនោះខ្ញុំបាទបានថយខ្លួនប្រហែលជាមួយអាទិត្យទៅពិចារណាមើល ហើយពេលនោះខ្ញុំបាទបានទៅថ្វាយបង្គំព្រះសង្ឃមួយចំនួនដែលខ្ញុំបាទកោតគោរពនោះបានធ្វើសមាធិផងអីផង ព្រោះចូលចិត្តធ្វើសមាធិរួច ហើយក៏បានជជែកជាមួយលោកយូរៗទៅទើបគិតថា ខប់សែលនេះមិនគួរនៅតែថ្នាក់ជាតិទៀតទេ ខប់សែលនេះគួរតែចុះទៅថ្នាក់ក្រោមថ្នាក់មូលដ្ឋានខ្ញុំបាទក៏ដើរមើលពិនិត្យមើលគ្រប់ភូមិឃុំស្រុកទាំងអស់ជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់ ដូច្នេះហើយបានជាថ្ងៃនេះអញ្ជើញក្រុមប្រឹក្សាឃុំសង្កាត់មកទាំង៣គណបក្សនិងជាការសំខាន់ណាស់ដែរ យើងនឹងត្រងត្រាប់ចាំស្តាប់ប្រសាសន៏របស់ក្រុមប្រឹក្សាឃុំសង្កាត់ជាពិសេសបើមានបងស្រីៗផងនោះព្រោះយើងចង់លើកតំកើនតួនាទីរបស់ស្ត្រី នៅក្នុងនយោបាយថ្នាក់មូលដ្ឋាន អញ្ចឹងហើយបានជាខប់សែលដំណាក់កាលទី២នេះមានរចនាសម្ព័ន្ធច្រើនមានខប់សែលដែលធ្វើនៅ ថ្នាក់ជាតិហើយនិងខប់សែលប្រ៉េមដែលយើងហៅថា Provincial Meetings នេះគឺធ្វើនៅថ្នាក់មូលដ្ឋាន២៤ខេត្តក្រុងនេះយើងធ្វើទាំងអស់ ហើយធ្វើ២ដងរហូតដល់ឆ្នាំ២០០៨យើងធ្វើរួចហើយនៅតាកែវ កំពត កំពង់សោម កំពង់សឺ កណ្តាល ហើយម្សិលម៉្ងៃយើងធ្វើនៅ មណ្ឌលគីរី ម្សិលមិញយើងធ្វើនៅស្ទឹងត្រែងថ្ងៃនេះ

យើងនៅរតនៈគីរី ហើយប៉ុន្មានខែទៀតយើងទៅធ្វើនៅក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀងហើយបន្តទៅទៀតនៅបន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងសៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំហើយមានឆ្លៀតទៅធ្វើនៅកោះកុងទៀត ដូច្នេះយើងដើរធ្វើអញ្ចឹងទាំងអស់ដើម្បីស្តាប់ ព្រោះបញ្ហាទំនាស់កើតឡើងច្រើនតែនៅក្នុងមូលដ្ឋាន ហើយត្រូវតែដោះស្រាយភ្លាមៗ ដូច្នេះហើយបានជានៅពេលដែលខ្ញុំបាទគូសវាសដំណាក់កាលទី២ហ្នឹង ក៏បានអោយតំលៃខ្លាំងទៅលើខប់សែលប្រ៊មនេះឯងនេះហើយ ដែរចង់ធ្វើយ៉ាងណាអោយវប្បធម៌នៃការពិភាក្សាគ្នានេះបានជ្រួតជ្រាបនៅក្នុងរឿងនេះឯង មិនមែនបានសេចក្តីថាអង្គការដទៃៗទៀតគេអត់បានធ្វើនោះទេ អង្គការច្រើនណាស់ដែលបានធ្វើគ្រាន់តែថាវិទ្យាស្ថាន CDRI និង យន្តការខប់សែលនេះមិនមានពណ៌នយោបាយទាល់តែសោះ ហើយមានការទុកចិត្តការកសាងទំនុកចិត្តនោះធំណាស់ពីគ្រប់តួអង្គទាំងអស់ដែល ពាក់ព័ន្ធយន្តការបោះឆ្នោតលក្ខណៈពិសេសគឺនៅត្រង់ហ្នឹងឯង។ នៅក្នុងការធ្វើខប់សែលប្រ៊មនេះយើងមានគោលដៅធំ៧៣ គោលដៅធំទី១យើងសង្កេតឃើញថាប្រជាពលរដ្ឋរបស់យើងមិនដូចស្រុកគេទេ គឺប្រជាពលរដ្ឋរបស់យើងដោយសារសង្គ្រាម២៨ឆ្នាំទៅយើងខ្ទេចខ្ទាំអស់យើងមិនសូវអោយតំលៃទៅលើក្រដាសស្នាមទេយើងកើតក៏កើតទៅស្លាប់ក៏ស្លាប់ទៅរៀបការក៏រៀបការទៅ មិនសូវអោយតំលៃទៅលើក្រដាសស្នាទេ ក៏ប៉ុន្តែដល់ពេលដែរយើងទៅរកការងារធ្វើយើងទៅមានកម្មសិទ្ធទៅអី គឺថាបានយើងស្វះស្វែងរកអត្តសញ្ញាណប័ណ្ណជាតិ ព្រោះធម្មតាដើម្បីអោយក្លាយទៅជាខ្មែរពេញលក្ខណៈទាល់តែមានអត្តសញ្ញាណប័ណ្ណជាតិ ដល់ពេលយើងធ្វើយន្តការខប់សែលបានយើងសង្កេតថាដើម្បីបោះឆ្នោតបានឯកសារដែរជាឯកសារសំខាន់បំផុតគឺអត្តសញ្ញាណប័ណ្ណជាតិហ្នឹង ហើយយើងបានសង្កេតឃើញថាមានប្រជាពលរដ្ឋរាប់លាននាក់ដែលអត់ទាន់បានទទួល១៨ឆ្នាំអត់ទាន់បានទទួលអត្តសញ្ញាណប័ណ្ណជាតិ អញ្ចឹងហើយបានជាយើងធ្វើការជាមួយក្រសួងមហាផ្ទៃជាមួយគជបដើម្បីអោយប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨ឆ្នាំបានទទួលអត្តសញ្ញាណប័ណ្ណជាតិទាំងអស់គ្នាដើម្បីសម្រួលការចុះឈ្មោះបោះឆ្នោត ហើយនិងការបោះឆ្នោត យើងធ្វើបាន៣ខែបានក្រសួងមហាផ្ទៃឯកឧត្តមឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោកចេញសេចក្តីថ្លែងការជាសាធារណៈកាលពីប៉ុន្មានខែមុននេះ លោកថាទិសដៅ២០០៦របស់ក្រសួងនិងបញ្ចេញអោយបាននូវអត្តសញ្ញាណប័ណ្ណជាតិចំនួន១លាន៩សែននាក់ហើយដើម្បីសម្រួលនេះទៀតយើងរកឃើញថាការដែរចៅហ្វាយខេត្តតែម្នាក់ឯងមានសិទ្ធហត្ថលេខាលើអត្តសញ្ញាណប័ណ្ណជាតិនេះយឺតណាស់គាត់រវល់ទៅបេសកកម្មអីផង ហើយចៅហ្វាយខេត្តខ្លះហ្នឹងគរនៅការិយាល័យរបស់គាត់ហ្នឹងរាប់ពាន់សន្លឹកដោយអត់មានពេលហត្ថលេខា បានជាឯកឧត្តមឧបនាយករដ្ឋមន្ត្រីលោកចេញសេចក្តីថ្លែងការមួយទៀតថាចាប់ពីពេលនេះទៅប្រគល់ប្រតិភូកម្មអំណាច ទៅអោយអភិបាលរងទី១ ពេលអភិបាលខេត្តមិននៅ អភិបាលរងទី១មានសិទ្ធហត្ថលេខាបានដូច្នេះយុទ្ធនាករសំរាប់ឆ្នាំ២០០៦ រឿងអត្តសញ្ញាណប័ណ្ណជាតិនេះខ្លាំងណាស់ ហើយបងខាងប៉ូលីសវីលោកវរសេនីយ៍ទោលោកនៅទីនេះស្រាប់ហើយលោកអាចជាសាក្សីអាចមានប្រសាសន៍បាន។ គោលដៅធំទី២ គឺធ្វើយ៉ាងណាអោយការចុះឈ្មោះបោះឆ្នោតចំពោះអ្នកដែលមានអាយុ១៨ឆ្នាំមានប័ណ្ណគ្រប់គ្រាន់ហើយនោះអោយបានចុះឈ្មោះបោះឆ្នោតគ្រប់ៗគ្នា នៅខេត្តយើងនេះចុះឈ្មោះពីឆ្នាំ២០០៥គោលដៅបាន៩៤ភាគរយនៅ ស្ទឹងត្រែងបានតែ៩១ភាគរយទេប៉ុន្តែមានខេត្តខ្លះបាន១០០ភាគរយ ក្នុងឆ្នាំ២០០៦នេះគឺ៩ខែត្រៀមចុះឈ្មោះត្រៀមដូច្នេះហើយ បានជាយើងអញ្ជើញក្រុមប្រឹក្សាឃុំសង្កាត់មកចូលរួម គឺថាសូមអោយប្រើប្រាស់ពេល៩ខែឥឡូវយើងបានមកដល់ខែទី៤ ហើយអស់៣ខែនៅសល់៦ខែទៀតទេប្រើប្រាស់នៅប៉ុន្មានខែនេះត្រៀម ដើម្បីរៀបចំការចុះឈ្មោះមែនទែននៅខែ១០និង២០ថ្ងៃនោះព្រោះ២០ថ្ងៃតិចណាស់ អញ្ចឹងហើយបានជាយើងត្រូវប្រើប្រាស់ពេលវេលាត្រៀមហ្នឹងដើម្បីដល់ពេល២០ថ្ងៃហ្នឹងយើងធ្វើគំហុកអោយហើយតែម្តងនិងដើម្បីអោយ បានចូលទៅដល់រៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ដែលនឹងធ្វើនៅថ្ងៃទី០១ខែមេសាឆ្នាំ២០០៧។ ដូច្នេះការចុះឈ្មោះបោះឆ្នោត អត្តសញ្ញាណប័ណ្ណគឺត្រូវគិតអ្នកដែលមានអាយុ១៨ឆ្នាំទៅទល់នឹងថ្ងៃ០១ខែមេសាឆ្នាំ២០០៧ អ្នកណាដែលមានអាយុគ្រប់១៨ឆ្នាំ ថ្ងៃទី០១ខែមេសាឆ្នាំ២០០៧អ្នកនោះមានសិទ្ធិបានចុះឈ្មោះបាន

បោះឆ្នោតទាំងអស់យើងនឹងធ្វើអោយបាន១០០ភាគរយ ហើយនៅក្នុងនេះយើងនឹងធ្វើយុទ្ធនាការសម្រិតសម្រាំងឈ្មោះនៅក្នុងបញ្ជីអ្នកចុះឈ្មោះបោះឆ្នោត ព្រោះខ្មែរយើងមិនសូវប្រុងប្រយ័ត្នទេខុសឈ្មោះច្រើនណាស់ដូចឈ្មោះខ្ញុំបាទឱកសេរីសោភក្ដិហ្នឹងទៅកន្លែងរាជការទៅកន្លែងរដ្ឋបាលគេមិនសូវសរសេរអោយទេគេហៅតែឱកសេរីសោភ័ណ្ឌហ្នឹងប៉ុន្តែធ្វើម៉េចបើអញ្ចឹងទៅហើយ ហើយខ្មែរយើងចូលចិត្តណាស់ដូរឈ្មោះចាប់ពីថ្ងៃនេះទៅសូមមេត្តាសូមកុំដូរទៀតគឺថាវង្វេងវង្វាន់អស់ហើយ។ គោលដៅទី៣ គឺសន្តិសុខយុទ្ធនាការឃោសនាការបោះឆ្នោតទាំងប៉ុន្មានត្រូវក្លាយជាការបោះឆ្នោតប្រកបទៅដោយអហឹង្សារឿងនេះយើងធ្វើការជាមួយក្រសួងមហាផ្ទៃធ្វើការជាមួយគណបក្សធ្វើការជាមួយអាជ្ញាធរដែនដី ដូច្នេះហើយបានជាយើងចុះមកធ្វើខប់សែលប្រ៉ម ដើម្បីធ្វើយ៉ាងណាអោយបោះឆ្នោតម្តងៗនោះគឺថាបញ្ហា ដែលថាយប់ឡើងឆ្កែលូអីលែងអោយមានទៅ បញ្ហាទៅសង្កត់សង្កិនបង្កើតបរិយាកាសគួរអោយភ័យខ្លាចលែងអោយមានទៅឈ្នះឆ្នោតដោយទឹកចិត្ត ដោយការគាំទ្ររបស់ប្រជាពលរដ្ឋពិតប្រាកដ ហើយអ្នកដែលអាចឈ្នះឆ្នោតបានមានមធ្យោបាយនឹងឈ្នះឆ្នោតបានរបស់ប្រជាពលរដ្ឋ ដោយទឹកចិត្តមិនចាំបាច់ប្រើរឿងផ្សេងទៀតទេ អញ្ចឹងហើយបានជាគ្រប់ខេត្តទាំងអស់យើងធ្វើការអោយនៅតែរង្វង់ស្ថានីយ៍បោះឆ្នោតហ្នឹងលែងអោយមានវត្តមាន របស់អាជ្ញាធរដែនដី តាំងពីខេត្តតាំងពីឃុំតាំងពីភូមិតាំងពីស្រុកអីទាំងអស់ គឺថាលែងអោយមានទៅ ព្រោះថាចំនេញក៏មកនចំនេញ ហើយរូបភាពខាតក៏មានច្រើន នេះជាគោលដៅធំៗដែលយើងមានបំណងនិងធ្វើការសហប្រតិបត្តិការជិតស្និតជាមួយក្រសួងមហាផ្ទៃ ហើយជាមួយគជប គណបក្សធំៗទាំង៣ និងគណបក្សផ្សេងៗទៀត ហើយនិងអង្គការសង្គមស៊ីវិលទាំងអស់ ដែលពាក់ព័ន្ធទៅនិងអង្គការផ្សេងៗទៀត ហើយនិងអាជ្ញាធរមូលដ្ឋាន។ ទាំងអស់នេះហើយដែលខ្ញុំបាទសូមមេត្តាជំរាបជូនដោយវែងបន្តិចប៉ុន្តែរឿងរ៉ាវខប់សែលគឺវានមានរឿងដើមទងរបស់វាចេញមកអញ្ចឹងហើយដែលយើងមានមោទនភាពណាស់ដែរយើងធ្វើឡើងដោយដៃឯងតែម្តង ហើយយើងជាខ្មែរនេះយើងសង្ឃឹមថាយន្តការទាំងអស់នេះនិងមានជីវិតបន្តទៅទៀតទៅដល់កូនចៅជំនាន់ក្រោយ។ ហើយឆ្លៀតឱកាសនេះផងដែរ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ឯកឧត្តមអភិបាលខេត្តឯកឧត្តម អភិបាលរងទាំងអស់ ដែលអនុញ្ញាតផ្តល់នូវការគាំទ្រនូវយន្តការខប់សែលប្រ៉មនេះ នៅខេត្តរតនៈគីរីរបស់យើងខ្ញុំក៏សូមថ្លែងនូវការកោតសរសើរដល់ បងប៉ែនឈុនឌី ដែលបងជាប្រធានPEC ដែលលោកធ្វើការប្រជុំជាញឹកញាប់តាមដែលខ្ញុំបានដឹងដើម្បីអោយយល់គ្នានៅក្នុងរឿងនេះ។ ដូច្នេះខ្ញុំព្រះករុណាខ្ញុំសូមអរព្រះគុណនិងសូមអរគុណ។

៤.លោក ប៉ែនឈុនឌី( ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោត ខេត្តរតនៈគីរី)

សូមអរគុណបងឱកសេរីសោភក្តិដែលជាទីប្រឹក្សានិងជាអ្នកសំរបសំរួលយន្តការខប់សែលនៃវិទ្យាស្ថាន CDRI។ ជាបឋមនេះខ្ញុំព្រះករុណាខ្ញុំ ខ្ញុំបាទសូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ លោកឡារី ស្រ្តេន្ធ នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា និងសូមគោរពលោកឱកសេរីសោភក្តិ ដែលជាទីប្រឹក្សានិងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI ហើយនិងអស់លោកលោកស្រីដែលជាភ្ញៀវកិត្តិយសទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គប្រជុំដ៏មានសារៈសំខាន់នៅក្នុងថ្ងៃនេះជាទីគោរព។ ថ្ងៃនេះគឺជាថ្ងៃមួយដ៏ល្អប្រសើរណាស់ ដែលខ្ញុំបាទមានកិត្តិយសសូមធ្វើបទអន្តរាគមន៏ពាក់ព័ន្ធនិងការងារបោះឆ្នោតកន្លងមក។ ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណធិតេយ្យ និងអង្គប្រជុំទាំងមូលដែលបានអនុញ្ញាតអោយខ្ញុំបាទបានថ្លែងនូវអន្តរាគមន៏ពាក់ព័ន្ធនិងស្ថានភាព នៃការបោះឆ្នោតនឹងក្នុងពេលអនាគត។ ឆ្លៀតនៅក្នុងឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំបាទសូមអនុញ្ញាតជំរាបជូនការងារជាក់ស្តែង ដែលលេខាធិការដ្ឋានរៀបចំការងារបោះឆ្នោតបានបំពេញការងាររបស់ខ្លួនគឺការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំនិងការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី២។ ក្នុងឆ្នាំ២០០៥ និងឈានចូលដល់ខែមករាឆ្នាំ២០០៦ លេខាធិការដ្ឋានរៀបចំការងារបោះឆ្នោតបានអនុវត្តការងារសំខាន់ៗចំនួន២ ក្នុងពេលជាមួយគ្នានោះគឺការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៥ ការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភានីតិកាលទី២

ឆ្នាំ២០០៦ ការងារទាំង២ខាងលើនេះត្រូវបានអនុវត្តតាមច្បាប់២ផ្សេងគ្នាគឺ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៥ត្រូវបានអនុវត្តតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការរៀបចំបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ត្រូវបានអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ទោះបីច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានតំរូវអោយអនុវត្តបទបញ្ញត្តិមួយចំនួន នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក៏ដោយក៏ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គឺជាការងារមួយដោយឡែកដែលពុំទាក់ទងនិងការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលជាការបោះឆ្នោតអសកលឡើយ។ សំរាប់ការពិនិត្យឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៥ លេខាធិការដ្ឋានរៀបចំការបោះឆ្នោតបានប្រមូលផ្តុំអនុវត្តការងារសំខាន់៧ដូចជា ការចាត់ចែងស្រង់ស្ថិតិប្រជាពលរដ្ឋ ការប៉ាន់ស្មានចំនួននិងទីតាំងការិយាល័យបោះឆ្នោត ការិយាល័យចុះឈ្មោះបោះឆ្នោត ការផ្គត់ផ្គង់ ការវេចខ្ចប់ និងការបញ្ជូនឯកសារនិងបរិក្ខាសំរាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ទៅអោយក្រុមប្រឹក្សាឃុំសង្កាត់និងស្មៀនឃុំសង្កាត់ដែលត្រូវបានគជបធ្វើប្រតិភូកម្មអំណាច និងតែងតាំងអោយទទួលបន្ទុកការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំបានគ្រប់គ្រាន់ចំគោលដៅនិងទាន់ពេលវេលា ហើយបានរៀបចំការវេចខ្ចប់ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជូន គជប បានទាន់ពេលវេលានិងសម្រេចបានលទ្ធផលល្អប្រសើរ។ ជាលទ្ធផលមានការិយាល័យបោះឆ្នោត សរុបចំនួន១៣៥ការិយាល័យ ហើយក្នុងនោះមាន៤មិនបានប្រើប្រជាពលរដ្ឋរួមចំនួន១២៤ពាន់៧៩៥នាក់ក្នុងខេត្តរតនៈគិរី ហើយប្រជាជន១៨ឆ្នាំ ឡើងមាន៦០ពាន់១០២នាក់ចំនួនឈ្មោះក្នុងបញ្ជី២០០៤មាន៥៤ពាន់៥១៥នាក់ចុះឈ្មោះថ្មីបានចំនួន២ពាន់៦៩៣នាក់លុបឈ្មោះពីបញ្ជីបាន៤៦៨នាក់។ បញ្ជីបោះឆ្នោតឆ្នាំ២០០៥មាន៥៦ពាន់៧៤០នាក់គិតជាភាគរយមានចំនួន៩៤,៤១ភាគរយដោយឡែកសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ការងារស្រង់ឈ្មោះអ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែង និងជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងតំណែងការស្រង់ឈ្មោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានធ្វើប្រតិភូកម្មអំណាចជូនដល់ ក្រុមប្រឹក្សាឃុំសង្កាត់ នៅតាមសាលាឃុំសង្កាត់សំរាប់សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងតំណែងនិងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា សំរាប់ការស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែងបន្ទាប់ពីបានទទួលបញ្ជីរាយនាមសមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងតំណែង ដោយមានការអនុម័តយល់ព្រមពី ក្រុមប្រឹក្សាឃុំសង្កាត់លោកអភិបាលស្រុក និង ឯកឧត្តមអភិបាលខេត្តលើបញ្ជីរាយនាមសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងតំណែង បន្ទាប់មកគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត បានរៀបចំបញ្ជូនបញ្ជីឈ្មោះទាំងនោះ មកជូនគជបដើម្បីបញ្ចូលទិន្នន័យក្នុងComputerសំរាប់រៀបចំជាបញ្ជីបោះឆ្នោតតំបូងបន្ទាប់មកទៀតគជប ក៏បានបញ្ជូនបញ្ជីរាយមានត្រឡប់មកវិញ ដើម្បីបិទផ្សាយបំរើគោលដៅនៃការកែតំរូវនិងការប្តឹងតវ៉ារឺប្តឹងជំទាស់ពាក់ព័ន្ធនិងបញ្ជីបោះឆ្នោតតំបូងនេះ។ ខេត្តរតនៈគិរីមានអ្នកបោះឆ្នោត ដែលជាតំណាងរាស្ត្រក្នុងតំណែង និងជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងតំណែងសរុបមាន ចំនួន២៥២រូបមានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួន១ដែលមានទីតាំងឋិតនៅវិទ្យាល័យសម្តេចឪសម្តេចម៉ែ។ ជាការពិតណាស់រាល់ស្នាដៃនិងលទ្ធផលការងាររបស់លេខាធិការដ្ឋានគណៈកម្មាធិការរៀបចំការងារបោះឆ្នោតសម្រេចបាន ពុំអាចកាត់ផ្តាច់បានពីការចូលរួមចំណែកយ៉ាងសកម្ម ពីសំណាក់ក្រុមប្រឹក្សាឃុំនិងស្មៀនឃុំសង្កាត់ ព្រមទាំងគណៈកម្មាធិការការិយាល័យបោះឆ្នោត និងអ្នករាប់សន្លឹកឆ្នោតដែលជាអ្នកអនុវត្តដោយផ្ទាល់បានឡើយ។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះខ្ញុំសូមសំដែងនូវការគោរព និងកោតសរសើរដោយស្មោះស្ម័គ្របំផុត ចំពោះមន្ត្រីបុគ្គលិកលេខាធិការដ្ឋានរៀបចំការបោះឆ្នោត គណៈកម្មាធិការរៀបចំការបោះឆ្នោត ក្រុមប្រឹក្សា និង ស្មៀនឃុំសង្កាត់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ដែលបានសហការគ្នាយ៉ាងល្អប្រសើរ និងបានរួមចំណែកដោយជោគជ័យ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២នាពេលកន្លងមកនេះ ប្រកបដោយសេរីត្រឹមត្រូវ

យុត្តិធម៌និងមានតម្លាភាព។ ទន្ទឹមនិងស្នាដៃនិងលទ្ធិផលការងារដែលទទួលបាន លេខាធិការដ្ឋានគណៈកម្មាធិការរៀបចំការបោះឆ្នោតបានកត់សំគាល់ឃើញនៅមានចំនុចខ្វះខាតមួយចំនួន ដែលត្រូវពុះពារជំនះកែលំអរ និងបង្កើនចំនុចខ្លាំ ដើម្បីជាគន្លឹះក្នុងការឈានទៅអនុវត្តក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតលើកក្រោយទៀតប្រកបដោយជោគជ័យ តាំងនាមថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកនៃលេខាធិការដ្ឋានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត ខ្ញុំសូមលើកឡើងនូវចំនុចខ្វះខាតមួយចំនួនដូចខាងក្រោមដើម្បីសមាជិកសមាជិការនៃអង្គប្រជុំចូលរួមផ្តល់ជាយោបល់កែលំអរ ដើម្បីស្វែងរកអោយឃើញបទពិសោធន៏ល្អសំរាប់ជាគន្លឹះក្នុងពេលបោះឆ្នោតក្រោយៗទៀត ចំពោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការិយាល័យចុះឈ្មោះបោះឆ្នោតថ្មីបន្ថែមដែលគជបបានផ្តល់ជូនតាមសំណើរសូមរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ក៏ប៉ុន្តែស្មៀនឃុំមួយចំនួនតូចពុំសូវយកចិត្តទុកដាក់ចុះឈ្មោះអ្នកបោះឆ្នោតនូវការិយាល័យថ្មីទេ តែបន្តចុះឈ្មោះនៅការិយាល័យចាស់ ដែលមានចំនួនអ្នកចុះជិត៧០០នាក់ទៅហើយ កន្លែងខ្លះទៀតស្មៀនឃុំសង្កាត់ធ្លាប់មានបទពិសោធន៏ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ មានជំងឺត្រូវប្រគល់ភារៈកិច្ចនេះទៅអោយ ជំនួយការស្មៀនដែលជាការងារថ្មីសំរាប់គាត់ កន្លែងខ្លះទៀតក្រុមប្រឹក្សាឃុំស្មៀនឃុំមានការងាររមមាញឹកច្រើនពេកដែលត្រូវពេលគ្នានិងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ ចំពោះការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ក្នុងចំណោមបញ្ជីរាយនាមសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ដែលបានស្រង់ចំនួន៥ច្បាប់ មានមួយចំនួនតូចពុំបានស្រង់បញ្ជាក់អំពីភេទអាយុថ្ងៃខែឆ្នាំកំណើតច្បាស់លាស់ទេ ដែលធ្វើអោយមានការពិបាកនិងយឺតយ៉ាវខ្លះៗដែរ។ ឆ្លៀតក្នុងឱកាសនេះដែរខ្ញុំបាទសូមលើកឡើងនូវចំនុចគន្លឹះចំនួន៣ ដែលគជបបានកត់សំគាល់ក្នុងអង្គសន្និបាតរបស់ខ្លួន កាលពីថ្ងៃទី២៧-២៩ខែកុម្ភៈឆ្នាំ២០០៦នៅក្រុងព្រះសីហនុសំរាប់ការងារបោះឆ្នោតអាណត្តិក្រោយៗទៀត។ ទី១ការពង្រឹងអភិបាលកិច្ចល្អ ក្នុងការអនុវត្តការងារទី២បង្កើនការយល់ដឹងសមត្ថិភាពជំនាញដឹងដល់មន្ត្រីបោះឆ្នោត និងទី៣ពង្រឹងកិច្ចសហការល្អ ជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធពិសេសក្រសួងមហាផ្ទៃ អាជ្ញាធរដែនដី ក្នុងការការពារសន្តិសុខសុវត្ថិភាពក្នុងការបោះឆ្នោត ពិសេសគាំទ្រដល់ក្រុមប្រឹក្សាស្មៀនឃុំសង្កាត់ក្នុងការចូះឈ្មោះបោះឆ្នោត។ ជាថ្មីម្តងទៀតខ្ញុំសូមប្រសិទ្ធពរជ័យជូនអង្គប្រជុំពីយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជាថ្នាក់ខេត្តដែលហៅកាត់ថាខប់សែលប្រ៉មដែលបានប្រារព្ធឡើងនៅខេត្តរតនៈគិរីដែលទទួលបានលទ្ធផលជាផ្លែផ្កា។ ជាទីបញ្ចប់ខ្ញុំ សូមប្រសិទ្ធពរជ័យជូនគណអធិបតេយ្យព្រមទាំងអង្គប្រជុំទាំងមូល សូមមានសុភាពល្អ និងមានជ័យបវរ មហាប្រសើរគ្រប់ប្រការសូមអរគុណ។

៥. លោក ឱកសេរីសោភក្តិ៍

ខ្ញុំបាទសូមថ្លែងនូវអំណរគុណដល់ បងប៉ែនឈុនឌី ដែលលោកមានប្រសាសន៏ដោយស្មោះត្រង់នូវស្ថានភាពនៃការរៀបចំការបោះឆ្នោតនៅខេត្តរតនៈគិរីនេះ ជាពិសេសទៅគឺបញ្ហាការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត ហើយនិងការបោះឆ្នោតព្រឹទ្ធសភានៅខែមករាលើកនេះ។ ខ្ញុំបាទនិងជូនសំដីទៅអង្គប្រជុំ ហើយជាពិសេសខ្ញុំបានក៏សូមជំរាបផងដែរថាមាន២ប្រធានបទដែរយើងខំធ្វើយ៉ាងណាដើម្បីជំរុញលើកតំកើត ទី១គឺតួនាទីស្ត្រីនៅក៏រិតនយោបាយមូលដ្ឋានគឺយើងមើលឃើញថាទៅអនាគតទៅស្ត្រីដែលនៅថ្នាក់មូលដ្ឋានគួរតែចូលរួមអោយបានច្រើននៅក្នុងនយោបាយមូលដ្ឋាន ជាពិសេសតាមរយៈក្រុមប្រឹក្សាឃុំសង្កាត់នេះ ដូច្នេះហើយបានជាយើងចង់ស្តាប់ការលំបាកនោះថាក្នុងការបំពេញតួនាទីនោះយ៉ាងណា ហើយតើយើងគួរធ្វើយ៉ាងណាដើម្បីជួយលើកតំកើនតួនាទីនេះ។ ទី២គឺយើងគិតថាប្រជាពលរដ្ឋខ្មែររបស់យើងជាប្រជាពលរដ្ឋមួយកើនឡើងច្រើនណាស់ដែលឥឡូវមានដល់ទៅ១៣លានកន្លះហើយនៅក្នុងហ្នឹងប្រហែលជា៦០ភាគរយអាយុក្រោម២៥ឆ្នាំ ដូច្នោះយើងចង់លើកតំកើនតួនាទីយុវជនហ្នឹង អោយស្គាល់អោយយល់ដឹងអោយយកចិត្តទុកដាក់នៅក្នុងតួនាទីរបស់ខ្លួនឯងជាពលរដ្ឋដែលទាក់ទងទៅនិង ការបោះឆ្នោត ដូច្នេះហើយបានជាយើងខំយកចិត្តទុកដាក់ទៅលើ

រឿងអត្តសញ្ញាណប័ណ្ណ កាលណាដល់អាយុ១៨ត្រូវតែបានទទួលសំបុត្រអត្តសញ្ញាណប័ណ្ណ ហើយត្រូវតែទៅចុះឈ្មោះបោះឆ្នោតដើម្បីបំពេញតួនាទីជាពលរដ្ឋនេះជាជំហានតំបូងហើយដែរជាតួនាទីប្រជាពលរដ្ឋ ដូច្នេះកិច្ចការទាំងអស់នេះខ្ញុំព្រះករុណាខ្ញុំបាទ សូមជូនសំដីនេះទៅអង្គប្រជុំទាំងមូលទៅបងស្រីទៅបងប្រុសទាំងអស់សូមមេត្តាមានមតិគ្រប់យ៉ាងទាំងអស់អត់មានថារឿងអីដែរយើងនិយាយគ្នាមិនបានទេ ព្រះសង្ឃគ្រប់ព្រះអង្គអាចមានប្រសាសន៍បានបើមានពុទ្ធដីការ យើងខ្ញុំប្រគេនតួនាទីនេះជូនផងដែរបើសិនជាមានដូច្នេះសូមអញ្ជើញមានប្រសាសន៍

៦.លោក សំ សុផាត ( មេឃុំ ឡាបាសៀក ស្រុកបានលុង ខេត្តរតនៈគិរី)

សូមគោរពអង្គប្រជុំ និង សូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ។ ខ្ញុំឡើងមកនេះគឺដោយឯកឧត្តមលើកឡើងមានបញ្ហាមួយពាក់ព័ន្ធនិងអត្តសញ្ញាណប័ណ្ណក្នុងការបោះឆ្នោត យើងពិនិត្យសុក្រឹត្យទៅលើអត្តសញ្ញាណ របស់អ្នកទៅបោះឆ្នោត ដូច្នេះហើយគឺថាប្រជាជនខ្មែរតាំងពីឆ្នាំ២០០២ គឺក្រសួងមហាផ្ទៃបានបង្កើតអោយមានការធ្វើអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន រឺសំបុត្រកំណើត គឺចាប់ពីឆ្នាំ២០០២ គឺយើងបញ្ជាក់កំណើតដើម្បីអោយស្គាល់ថាអ្នកហ្នឹងជាប្រជាជនខ្មែរមាន អាយុមាន ថ្ងៃខែត្រឹមត្រូវ កើតនៅទីកន្លែងណាអោយមានសញ្ញាបន្តិចៗមកអោយស្គាល់ដល់ដើទៅទទេរអញ្ចឹងវាអត់មានយីហោរ ។ ខ្ញុំសូមនិយាយថា រឿងអត្តសញ្ញាណប័ណ្ណដូចឯកឧត្តមនិយាយអញ្ចឹងវាពាក់ព័ន្ធនិងបញ្ជីអត្រានុកូលដ្ឋានគឺការចុះបញ្ជីជាតិហ្នឹងតែម្តង សព្វថ្ងៃមិនមែនថាមិនធ្វើទេគឺធ្វើអោយដោយភាពសុក្រឹត្យ ប៉ុន្តែសុក្រឹត្យហ្នឹងក៏មាន លំអៀងបន្តិចៗដូច្នេះអ្វីដែរជាគន្លឹះដែលធ្វើអោយខុស គឺមានតិចៗនិងយើងត្រូវសំអាតវាព្រោះយើងចង់បានអ្វីដែរសុក្រឹត្យ ឧបមាថា មនុស្សអាយុខ្ទង់២៨ឆ្នាំស្រាប់តែទៅធ្វើបញ្ជីជាតិអាយុ៤០ឆ្នាំឬាយ បើមិនធ្វើអញ្ចឹងម៉េចកើតឯកឧត្តមមិនទាន់យល់ទេបើខ្ញុំនិយាយ បន្តិចទៀតបានយល់ ព្រោះថាកន្លងមកយើងមានភាពចាំបាច់ត្រូវតែធ្វើអញ្ចឹង ព្រោះថាអ្នកទៅគេទៅបាត់ហើយទាល់តែរកអ្នកថ្មីមកជំនួសអញ្ចឹង ហើយសូមជំរាបអោយលំអិតថាការស៊ីឈ្មោះ ការស៊ីឈ្មោះហ្នឹងសម្តេចលោកមានប្រសាសន៍ថ្ងៃមុននិយាយបន្តិចៗហើយថា អោយដាក់ឈ្មោះអោយសុក្រឹត្យតែម្តង អោយចំបើ( ក) ថា( ក) ( ខ) ថា( ខ) អាយុ២២ឆ្នាំស្រាប់តែមានប្រពន្ធហើយកូនដល់ទៅបួនហើយដល់ទៅការប្រពន្ធធ្វើម៉េច ? មាននរណាយក គេមិនហានយកដល់គេមិនហានយកព្រោះនៅក្នុងសាលាកប័ត្រចាស់ ហើយមានប្រពន្ធមានកូនការហើយ ត្រូវដាក់ឈ្មោះប្រពន្ធទៅតាមហ្នឹងទៀត ដើម្បីបើកស៊ីប្រាក់ខែកើតឯកូនបួនប្រាំមិនទាន់កើតដាក់ទៅតាមហ្នឹងទៀតមិនដឹងឈ្មោះអីខ្លះ និងដូចជាភាពអសុក្រឹត្យមិនត្រឹមត្រូវ អញ្ចឹងត្រួតពិនិត្យឃើញថានេះជាមូលហេតុតំបូងហើយពួកខ្ញុំគិតធ្វើយ៉ាងម៉េច? និងដាក់ឈ្មោះគាត់ពិតប្រាកដ អាណ្ណឹងអត់ចូលសាលាប័ត្របានអីបើឈ្មោះស៊ីប្រាក់ខែ ហើយកូនច្រើនអញ្ចឹងមិនដាក់ទៅបាត់លុយខ្ញុំអស់ហើយ ដូច្នេះភាពអសុក្រឹត្យវានៅត្រង់ហ្នឹងបន្តិច ដូច្នេះសូមឯកឧត្តមពិនិត្យពិចារណាឡើងវិញ ជួយធ្វើយ៉ាងណាអោយពួកខ្ញុំមានភាពសុក្រឹត្យ តែពួកខ្ញុំខិតខំធ្វើមិនមែន--------------១២ពាន់១៣ពាន់នាក់ហ្នឹង ឥឡូវឃើញឡើងបាន៩ពាន់ជាងហើយ នៅសល់តែ២-៣ពាន់មិនដឹងជាធ្វើយ៉ាងម៉េចមួយអាទិត្យធ្វើបានតែ៣០នាក់បើកយុទ្ធនាការ៧អាទិត្យគ្រប់ភូមិគ្រប់កន្លែងទៅដល់កាំជណ្តើរផ្ទះហើយនៅមិនទាន់ធ្វើ អញ្ចឹងហើយប្រជាជនយើងនៅខ្វះការយល់ដឹង ដូចឯកឧត្តមនិយាយហើយរឿងលិខិតស្នាមជាផ្លូវការសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់មនុស្សនិមួយៗ ដូចជាមិនស្រូវយកចិត្តទុកដាក់ដោយមមាញឹករឿងលុយរឿងជីវិត គឺថាព្រឹកឡើងអញ្ជទៅរកលុយរកបានទិញអង្ករទិញ ត្រីសាច់អោយកូនស៊ីសិន អញ្ចឹងហើយបានភាពក្រីក្រវានៅទីនេះដែរវាមានការពាក់ព័ន្ធហើយ អញ្ចឹងហើយបានថាទៅដល់ជណ្តើរផ្ទះនៅតែមិនទាន់មាន នៅ៧អាទិត្យហ្នឹងសរុបទៅប្រហែលជាបានតែ២០០ជាងទេ ប្រាំពីចំនុចឃុំដែលចុះទៅអាទិត្យនេះ ដូច្នេះហើយសូមជំរាបត្រង់ហ្នឹង ហើយឯកឧត្តមជួយពិនិត្យពិចារណាផង ហើយធ្វើម៉េចអោយមនុស្សយើងវាមានភាពសុក្រឹត្យ ដូចឯកឧត្តមលើកឡើងខ្ញុំយល់ស្រប រឿងហ្នឹងវាពាក់ព័ន្ធអត្តសញ្ញាណប័ណ្ណដើម្បីទៅចុះឈ្មោះបោះឆ្នោត ចុះបើមនុស្សអាយុ២២ឆ្នាំ ដល់ទៅចុះឈ្មោះអាយុ៤៥ឆ្នាំអាណ្ណឹងវាអសុក្រឹត្យ

ហើយប៉ុនមានរូបភាពគាត់ពេញសិទ្ធហើយ ក៏ប៉ុន្តែវាមិនទាន់សុក្រឹត្យវាប្រាកដត្រឹមត្រូវ អញ្ចឹងធ្វើអោយមនុស្សនោះបាត់អត្តសញ្ញាណរបស់ខ្លួន ឧបមាថាខ្លួនជនជាតិខ្មែរសោះ ក៏ប៉ុន្តែដល់ទៅស៊ីឈ្មោះជនជាតិផ្សេងដោយលាក់មុខអីអញ្ចឹង ត្រង់នេះគួររាជរដ្ឋាភិបាលគិតពិចារណាជួយសំរួលទៅបើបានជាជ្រុលធ្វើចាប់ពី៥ឆ្នាំ៣ឆ្នាំអោយគាត់តែម្តងទៅ ហើយខាងក្រសួងសាធារណៈ ខាងក្រុមប្រឹក្សារដ្ឋមន្ត្រីត្រួតពិនិត្យ គឺដូរឈ្មោះអោយទៅអោយវាសុក្រឹត្យតែម្តង បើធ្វើអញ្ចឹងវាពិបាកណាស់ បាយបាតជាបាយបិណ្ឌ។ បាទខ្ញុំសូមតែប៉ុននេះ សូមអរគុណ។

៧.លោក ឱកសេរីសោភក្តិ

ខ្ញុំបាទសូមអរគុណលោកអ៊ីណាស់ ដែលលោកអ៊ីមានប្រសាសន៏នូវស្ថានការណ៍ជាក់ស្តែងរឿងនេះ ហើយខេត្តឯទៀត១ក៏បានជួបប្រទះបញ្ហានេះដែរ យើងគិតថារាជរដ្ឋាភិបាលនៅពេលដែលរៀបចំក្រុមប្រឹក្សាឃុំសង្កាត់នេះ ដោយសារយើងគិតថានៅជិតគៀកនិងប្រជាពលរដ្ឋ ហើយដោយសារស្ថានការណ៍សង្គ្រាមដែលយើងមានប៉ុន្មានឆ្នាំមកហើយ ដូច្នេះហើយអ្នកណាដែរធំកន្លងផុតទៅក៏ជួបប្រទះនឹងបញ្ហាដែរលោកអ៊ីមានប្រសាសន៏ហើយយើងត្រូវតែរងទាំងអស់គ្នា នេះជាមរតកនៃសង្គ្រាមដែរយើងបានទទួល ប៉ុន្តែយើងគិតថាក្រុមប្រឹក្សាឃុំថ្មី១ដែលកើតមកគឺថាយើងនឹងបញ្ចេញដូចលោកអ៊ីមានប្រសាសន៏អញ្ចឹង គឺថាសំបុត្រកំណើតនោះ គឺថាកើតឡើងភ្លាមយើងបញ្ចេញ ដូច្នេះក្មេង១ជំនាន់ក្រោយប្រហែលជាមិនបានជួបនូវបញ្ហាអសុក្រឹត្យដូចនៅជំនាន់យើងនេះទេ យើងខំអញ្ចឹងយើងខំទៅទោះបីយើងមានការលំបាក ប៉ុន្តែកូនចៅរបស់យើងគឺថាលែងមានការលំបាកដូចយើងទៀតហើយ នេះខ្ញុំបាទជឿអញ្ចឹង សូមអរគុណលោកអ៊ីណាស់ក្នុងរឿងនេះ។ សូមអញ្ជើញបន្តទៅទៀត

៨. លោក ពល អយ (មេឃុំ ចាអ៊ុង ស្រុកអូរជុំ ខេត្តរតនៈគីរី)

ជាបឋមសូមគោរពលោកទាំងបី និងសូមគោរពអង្គប្រជុំទាំងមូល។ ខ្ញុំមានសំនួរ២ទាក់ទងការរៀបចំការបោះឆ្នោតការស្មុគ្រស្មាញគឺ ជំនុំក្រុមប្រឹក្សាឃុំដឹកនាំក្នុងការរៀបចំការបោះឆ្នោត ហើយចំនុចទី១កាត់ឈ្មោះអ្នកស្លាប់ ដឹងស្រាប់ហើយជនជាតិដើមភាគតិចមួយចំនួនមកបញ្ជាក់មរណៈភាពនៅកន្លែងសាលាឃុំ មួយចំនួនអត់ទេ ដល់អញ្ចឹងទៅកាត់ឈ្មោះគាត់ក៏មិនចេះកាត់ព្រោះគាត់អត់មានអីយកកាត់ដើម្បីបញ្ជូនទៅគជប អញ្ចឹងឈ្មោះគាត់នៅតែថៃរក្សាស្ពេរដដែល ស្រាប់តែក្រោយពីការបោះឆ្នោតទៅស្រាប់តែមានចំនួនច្រើនប៉ុន្តែអ្នកបោះតិច នេះចំនុចទី១ ការស្មុគ្រស្មាញក្រុមប្រឹក្សាឃុំ។ ចំនុចទី២ ទាក់ទងអាយុ១៨ឆ្នាំឡើងដើម្បីសំរាប់ការបោះឆ្នោតវាស្មុគ្រស្មាញដែរ ដូចដែលខាងលោកមេឃុំឡាបាសៀកបានមានប្រសាសន៏ជូនក្នុងអង្គប្រជុំដែរ។ បើបើជនជាតិដើមភាគតិចអាយុ១៥រឺ១៦ឆ្នាំគេយកប្រពន្ធហើយ តែគេយកប្រពន្ធគេមិនគោពតាមច្បាប់បញ្ជាក់កំណើតទេ បើយើងមិនបន្ថែមអាយុក៏វាខាតហើយព្រោះគេយកប្តីប្រពន្ធហើយ គេមិនស្តាប់យើងប្រកាសសេចក្តីណែនាំក្នុងការបញ្ជាក់ចុះបញ្ជីអត្រានុកូដ្ឋាន នេះជាការស្មុគ្រស្មាញ។ ក្នុងការដឹកនាំជាក់ស្តែង ដូចសព្វថ្ងៃចុះបញ្ជីអត្រានុកូដ្ឋាន ដល់ពេលចូលឆ្នាំយកប្រពន្ធប្តីហើយ តំឡើងហើយទោះបី១៦ក៏ឡើង១៨ហើយដើម្បីអោយបានឈ្មោះបោះឆ្នោតនិងមានចិត្តបោះឆ្នោតជាការលំបាក ។ ពិសេសការងារក្នុងការពិនិត្យបញ្ជីចុះឈ្មោះបោះឆ្នោត រឺផែនការណ៏ណែនាំពី គជប ជួនកាលវាប៉ះពាល់ដល់ការងារច្រើនពេកដល់អញ្ចឹង ដល់អញ្ចឹងក្រុមប្រឹក្សាឃុំមិនបានទៀងទាត់ទេ ជាក់ស្តែងដូចខ្ញុំហើយទៅដេញកោះអញ្ជើញគេ ដើម្បីមកពិនិត្យបញ្ជីចុះឈ្មោះបោះឆ្នោត ជួនការគេមក ជួនការគេអត់ទៅ ពិព្រោះទីកន្លែងវាឆ្ងាយ១ពេកពីការិយាល័យ អញ្ចឹងវាខាតពេលកន្លែងនេះហើយជាការពិបាក ហេតុដូច្នេះគឺខ្ញុំមានសំនូមពរមួយដែរ គឺក្នុងបែបបទកាត់ឈ្មោះអ្នកស្លាប់ ហើយនិងប្តូរទីកន្លែង គឺសូមការអនុញ្ញាត្តពីលោកឯកឧត្តម កែសំរួលរឿងហ្នឹងបញ្ជូនអោយក្រុមប្រឹក្សាឃុំដើម្បីអោយក្រុមប្រឹក្សាឃុំងាយស្រួលអនុវត្ត នៅក្រោយការរៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំ និងតំណាងរាស្ត្រនៅអាណត្តិក្រោយទៀត។ ខ្ញុំសូមអរគុណ

៩. លោក ឱកសេរីសោភក្តិ

ខ្ញុំបាទសូមអរគុណលោកបង បញ្ហានេះគឺថាការដែលរៀបការអាយុ១៥-១៦ឆ្នាំ នៅខេត្តឯទៀតយើងមិនដែរលឺទេ ទើបតែនិងលឺនេះ ដូច្នេះហើយវាធ្វើអោយមានការលំបាកដល់រឿងចុះឈ្មោះ ហើយនិងរឿងអត្តសញ្ញាណប័ណ្ណនេះជាបញ្ហាជាក់ស្តែងណាស់ បើមិនបានមកផ្ទាល់មិនដឹងទេ។ អរគុណលោកបងមេឃុំ

១០. លោក ផាន់ ភិរុណ ( មន្ត្រីមកពីមន្ទីអប់រំយុវជន និងកីឡា ខេត្តរតនៈគីរី )

ជាបឋមសូមគោរពអង្គសិក្ខាសាលា គណធិតេយ្យ អស់លោក លោកស្រីជាទីគោរព។ ខ្ញុំបាទពេញចិត្តយ៉ាងខ្លាំងចំពោះប្រសាសន៏របស់លោកមេឃុំឡាបាសៀកនិងមេឃុំចាអ៊ុងដែរបានបញ្ជាក់ជូនពីការចុះឈ្មោះអ្នកបោះឆ្នោតដែលគេគិតពីអាយុ១៨ឆ្នាំទៅក៏ប៉ុន្តែផលវិបាកនៅតែជួបប្រទះ ដោយបងប្អូនប្រជារាស្ត្រនៅក្នុងខេត្តរតនៈគីរីយើងនេះពុំបានដឹងប្រាកដប្រជា អំពីអាយុរបស់ខ្លួន បញ្ហានេះក៏ខ្ញុំចង់ជំរាបជូនដែរថាក្នុងវិស័យអប់រំរតនៈគីរីរាល់ថ្ងៃគឺគេបានយកចិត្តទុកដាក់ អំពីការប្រមូលកុមារចូលរៀនអាយុ៦ឆ្នាំ បើនិយាយពីអាំងឌីការទ័រសំរាប់វិស័យអប់រំ ក្មេងអាយុ៦ឆ្នាំនៅខេត្តរតនៈគីរី ដែលបានចូលរៀនគឺបានតែ៦០%ទេ ហើយអត្រារួមនិយាយពីអត្រារួមចូលរៀនដំបូងគឺគិតតែក្នុង៣ឃុំមួយសិក្សាគឺដល់ទៅ១២០-១៣០% ដូច្នេះវាទាក់ទិននិងអ្វី ? គឺវាទាក់ទិននិងបញ្ជីជាតិហ្នឹងហើយរឺហៅថាសំបុត្រកំណើត សំរាប់កូនខ្មែរមិនអីទេ វាមានឆ្នាំដែរហៅថាជាស្តង់ដារមួយស្តង់ដារអាយុគឺជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក ការ ច កុល នេះជាស្តង់ដារសំរាប់មនុស្សខ្មែរគេអាចរាប់អាយុបាន សំរាប់បងប្អូនច្រាយ,កាញូង,កញ្ចាក់ បើសិនជាយើងអោយលោកនាយកសាលាម្នាក់ទៅធ្វើស្ថិតិកុមារមានអាយុ៦ឆ្នាំចូលរៀន សួរថាលោកបង កូនលោកបងឯងអាយុប៉ុន្មានហើយ ? គាត់ថាដូចជាមិនដឹងទេ ព្រោះខ្ញុំនៅស្រុកនេះ ២២ឆ្នាំហើយពេលណាដែលប្រមែប្រមូលកុមារចូលរៀននេះវាមិនខុសអីពីខាង----------- វាទៅតាមសភាវគតិរបស់វា វាមិនទៅតាមអំពើរវាមិនទៅ តាមពាក្យថាសភាវគតិ គឺអ្វីដែលវាមានពីមុនហើយ គឺជានិរន្តភាពមិនបានកែច្នៃសភាវគតិនោះទេ ក៏ប៉ុន្តែបើទៅបែបអំពើរ គឺដូចមនុស្សខ្មែរវាមានឆ្នាំថោះ រោង ម្សាញ់ ឆ្នាំនេះឆ្នាំច អីអញ្ចឹងទៅនេះជាស្តង់ដារអាយុ ហើយសួរថាបងប្អូនធ្វើម៉េចអោយដឹង អាយុ៦ឆ្នាំ គាត់ថាគាត់គិតពីទាក់ប្រពន្ធគាត់គិតចុះគិតឡើងគាត់ជំនុំគ្នាថ យើងធ្វើចំការវាដូចជា៣ដងហើយកន្លែងនេះ ព្រោះស្រុកយើងធ្វើចំការព្រៃសបងណាំ ស្រុកយើងធ្វើអញ្ចឹង បីឆ្នាំក្រោយទៀតគាត់ទៅធ្វើនៅកន្លែងនោះអញ្ចឹងគាត់ដេកគិតប្រហែលជាអាយុ៦ឆ្នាំហើយ ប្រហែល អញ្ចឹងដូចលោកមេឃុំចាអ៊ុង ថាគេចង់បានប្តីការពិតគេទើបតែអាយុ១៦ឆ្នាំរឺ១៥ឆ្នាំទេ ក៏ប៉ុន្តែដើម្បីបំពេញលក្ខណះវិនិច្ឆ័យអាពាហ៏ពិពាហ៏គេត្រូវការតំឡើងអាយុ ដូច្នេះហើយដូចលោកមេឃុំឡាបាសៀកថាវាមិនទាន់មានសុក្រឹត្យភាព អំពីការចុះឈ្មោះបោះឆ្នោតរឺចុះបញ្ជីអត្រានុកូលដ្ឋានរឺក៏សំបុត្រកំណើតនេះទេ។ មួយទៀតទាក់ទងនិងពីប្រធានបទដែរថា តើយើងធ្វើយ៉ាងណាគួរអោយស្ត្រីបានចូលជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ? ខ្ញុំពេញចិត្តមែនទែន។ ទិសដៅរបស់រាជរដ្ឋាភិបាលដែលមាន សម្តេចនាយកស្រែកកោកៗរាល់ថ្ងៃនេះ គឺថាធ្វើម៉េចអោយវាមានសមធមិ អំពីការទទួលចំនេះដឹង សមធមិអំពីការប្រកបមុខរបស់ សមធមិ អំពីការចែករំលែកផ្សេងៗ ក៏ប៉ុន្តែជាក់ស្តែងនៅក្នុងអង្គប្រជុំនេះមានប៉ុន្មានរូបស្ត្រី ? មាននារីខ្មែរ៤រូប និងបរទេស២រូប និងនៅក្រោយ ១រូបទៀតគឺ៧រូបក្រៅពីហ្នឹង សិតតែបុរស១ខ្ញុំនិយាយនេះមិនមែនសំនូមពរទេតែវាដោយត្រង់ៗថាលើកក្រោយបើសិនជាមាន គោលវិធីចង់អោយមានសមធមិផ្នែក Gender គួរអញ្ជើញស្ត្រីអោយបាន៥០%។ ឧទាហរណ៏ស្តង់ដារប្រជុំ ឧបមាថា១០០នាក់អញ្ជើញស្ត្រីអោយបាន៥០នាក់ ហេតុអ្វីបានជាខ្ញុំមានគំនិតយ៉ាងនេះ ? បើយើងមិនបង្កើនថាមពលអោយគេទេ ថាមពលគ្រាន់តែនៅតែក្នុងគំនិតនោះវានឹង ធាក់ថយទៅវិញ ខ្ញុំក៏អញ្ចឹងដែរ ខ្ញុំកាន់វិស័យអប់រំការពិតខ្ញុំនិយាយទៅខ្ញុំគណៈមន្ទី ២១ឆ្នាំដឹកនាំវិស័យអប់រំ ពេលណាក៏ក្រសួងនិងរដ្ឋាភិបាលថា ការអប់រំប្រកបដោយសមធមិ អ្វីទៅដែរហៅថាសមធមិ ? សមធមិគឺគិតទាំងមនុស្សទាំងអស់ កូនចៅយើងក្នុង៤៩ឃុំ ខេត្តរតនៈគីរីត្រូវតែបានចូលរៀនទាំងអស់គ្នាដោយមិនគិតថាអ្នកនេះគថ្លង់រឺខ្វាក់ទេ

ក៏ប៉ុន្តែការដែលធ្វើទៅតែងជួបបញ្ហា ជួបញ្ហានេះគឺជាផែនរបស់ក្នុងសង្គមខ្មែរតាំងពីយូរមកហើយថា ប៉ុន្តែឥឡូវកែប្រែមកហើយវាមិននៅជាជំងឺរ៉ាំរ៉ៃតទៅទៀតទេ វាបានកែច្នៃមកល្អជាបណ្តើរៗហើយ ក៏ប៉ុន្តែបើនិយាយពីកុមារីរីក៏យុវនារីនៅក្នុងសាលាមធ្យមសិក្សាក្តីបឋមសិក្សាក្តី គឺតិចជាងកុមារារីយុវជន៥០% ក្នុងចំណោម១០០នាក់ នៃមនុស្សប្រុសមានមនុស្សស្រី៥០នាក់ទេ ហើយគ្នារៀនមិនបានចប់បឋមសិក្សាស្រួលបួលផង តើហេតុអ្វី ? យើងគិតមើល ប្រហែលជាយើងនៅតែនាំគ្នាគិតថា កូនស្រីមិនបាច់ខំប្រឹងរៀនសូត្រទៅណាឆ្ងាយទេកូននៅជិតម៉ែទៅ បាទមែនកូនស្រីនៅជិតម្តាយមានប្រសិទ្ធភាពជួយម្តាយមែន មែនទេលោកមេឃុំ បើសិនម៉ែទុកកូនស្រីនៅក្បែរខ្លួនប្រសិទ្ធភាពការងារក្នុងគ្រួសារ ប្រាកដជាទទួលបានជោគជ័យ តែបើទុកកូនប្រុសនៅក្បែរម្តាយតើវាយ៉ាងម៉េច? តឹងទ្រូងណាស់ ក៏ប៉ុន្តែបញ្ហានេះខ្ញុំមិនចោទអស់លោកទេ ខ្ញុំនិយាយនេះធ្លាក់មកលើតែខ្ញុំដដែលជាអ្នកទទួលបន្ទុកមិនដឹងជាធ្វើយ៉ាងម៉េចគោលដៅគឺ Gender ស្អីក៏តាមGender ពាក្យថាGenderមិនមែនស្ត្រីភេទទេ Genderគឺជាមនុស្សស្រីត្រូវតែមានទទួលការចេះដឹងដូចគ្នា ទៅសាលារៀនដូចគ្នា ធ្វើមេឃុំបានដូចគ្នានិងបាន Gender បើ Gender៧នាក់ នៅក្នុងអង្គប្រជុំមួយមិនទាន់ជាGenderនៅឡើយមែនទេលោកប្រធាន មិនទាន់Genderទេ ទាល់តែយើងធ្វើយ៉ាងម៉េច ? យើងមើលពីគេយើងកែទំរង់វាយ៉ាងម៉េចអោយវាទៅជាការជាក់ស្តែង ។ បើអញ្ចឹងទេ ខ្ញុំអបអរសាទរណាស់ដែរថាយើងគួរតែជួយស្ត្រីអោយមានមុខមានមាត់ឡើយ ក៏ប៉ុន្តែស្ត្រីខ្លួនឯងក៏អញ្ចឹងដែរ ខ្ញុំករុណាសូមអភ័យទោស ព្រះតេជគុណមិនមែនប្រដៅទេគ្រាន់ទេគ្រាន់តែថា នេះនិយាយដោយស្មោះត្រង់ស្ត្រីខ្លួនឯងក៏ត្រូវតែ ដែលពាក្យពីដើមហៅថាស្វ័យភ្ញាក់រលឹក គឺថាសូមកុំរង់ចាំតែធ្វើប្រពន្ធគេ តួនាទីស្ត្រីគឺមានកាត្តបកិច្ចធ្វើជាម្តាយជាប្រពន្ធ ក៏ប៉ុន្តែកុំរង់ចាំតែឱកាសនោះ ពេលណាដែរគេកំពុងតែលើកយើង យើងត្រូវតែឡើង ពេលណាដែលកំពុងតែរុញយើងត្រូវតែឡើង ក៏ប៉ុន្តែលុះត្រាតែយើងឈានឡើងដោយខ្លួនឯងដែរ បើសិនយើងនៅជាដុំត្បាល់ ដែលត្បាល់បុកទាល់តែគេរមៀលបានមានចលនាបើគេមិនរុញវាមិនមានចលនាទេ អញ្ចឹងយើងជាស្ត្រីក៏អញ្ចឹងដែរ មើលដូចជនជាតិបរទេសគេនៅដល់New Zealandនៅដល់ណាណើគេមក ហេតុអី ? ពិព្រោះគេបានអនុវត្តតាមបែបវិធីGenderតែសម្រាប់ខ្មែរយើងGenderយើងគឺនៅក្នុងតែបបូរមាត់ វាមិនទាន់ឃើញមានប្រើយុទ្ធវិធីអីអោយGenderនោះមានប្រសិទ្ធភាព តើប្រាកដជាយកស្ត្រីធ្វើមេឃុំទេ ? ហើយខ្លួនយើងអញ្ចឹងដែរ បើគេអោយធ្វើមេឃុំប្រាកដជាធ្វើបានទេ ធ្វើបានក៏ដោយមិនបានក៏ដោយត្រូវតែធ្វើសាកមើល រឿងវាមុនតំបូងយើងជន្លតំបូងវាពិបាកហើយ ក៏ប៉ុន្តែដល់ពេលយើងចលនាស្មាំវាស្រួលហើយ វាមិននៅតែពិបាកតទៅទៀតទេ ។ អញ្ចឹងទេក្នុងឱកាសនេះដែរ តាមពិតការប្រជុំនេះជាការងារបោះឆ្នោតទេ ក៏ប៉ុន្តែខ្ញុំបាទឆ្លៀតក្រែងលោចំនេញបានបន្តិចថា បំណាច់មានវេទិការពីមុនមក បំណាច់មានគោលនយោបាយរបស់រាជរដ្ឋាភិបាល គួរតែស្ត្រីជាមេម៉ាយបង្ករឱកាសអោយកុមារីបានទៅសាលាច្រើន បើនៅតែដូចរបៀបនេះទេមិនបានធ្វើឃុំទេ ធ្វើតែស្មៀនគេមិនបានផង វាទាល់តែអត្តាហិអត្តនោនាថោ----- ទាល់តែខ្លួនយើងនេះស្លៀកស្បង់កោរសក់ បើស្លៀកស្បង់មិនកោរសក់មិនមែនព្រះសង្ឃទេ ឆ្លុះកញ្ចក់ទាល់តែបើកព្រះនេត្រដែលតេជគុណ បើស្លៀកតែស្បង់ហើយមិនកោរសក់មិនបើកព្រះនេត្រាក៏មិនមែនជាមនុស្សដែលមើលឃើញពីសមត្ថិភាពខ្លួនឯងដែរ ។ អ្វីដែលខ្ញុំបាទនិយាយនេះ គឺសូមអភ័យទោសហើយក៏សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ ហើយក៏សូមទោសផងដែរចំពោះស្ត្រីនៅក្នុងអង្គប្រជុំនេះ បើខ្ញុំបាទនិយាយប៉ះពារអីយ៉ាងម៉េចក៏គួរ ថ្ងៃក្រោយនៅនិយាយគ្នាកុំអោយជេរគ្នាពីក្រោយខ្នង។ សូមអរគុណ

១១.លោក ឱកសេរីសោភក្តិ

ខ្ញុំបាទឯកភាពទាំងអស់ជាមួយ លោកបងខាងប្រធានមន្ទីអប់រំយុវជននិងកីឡា ដែលមានប្រសាសន៏ឡើងមកទាំងប៉ុន្មាននេះ ហើយមិនចាក់ប្រធានទេរឿងស្ត្រីនេះ សំដីទាំងអស់នេះហើយដែលយើងខំនិយាយតៗគ្នាគ្រប់ទីកន្លែងទាំងអស់ ដែលនឹងជួយអោយផ្នត់គំនិតរបស់បុរសក៏ដោយ របស់ស្ត្រីខ្លួនឯងក៏ដោយ អាចនឹងផ្លាស់ប្តូរការដែលយើងធ្វើពេលនេះ គឺមិនបានសេចក្តីថាយើងបានឃើញ

លទ្ធផលពេលនេះទេ បើយើងមិនភ្ជួររាស់ក៏គ្មានស្រូវដែរប៉ុន្មានខែក្រោយមក ដូច្នេះវាត្រូវតែចាប់ផ្ដើមពេលណាមួយបានពេលណាមួយវាមានចេញជាលទ្ធផល ឥឡូវខ្ញុំបាទ បានឃើញនៅតាមសាលានៅតាមអង្គប្រជុំនានា សមធម៌ សមភាព ស្មើភាព រវាងស្ត្រីនិងបុរសនៅជំនាន់ក្រោយ ជំនាន់អាយុ២០ឆ្នាំជាងឥឡូវចាប់ផ្ដើមមាន តែកាលជំនាន់យើងនេះមិនទាន់សូវមានទេ ដូច្នេះខ្ញុំថាលទ្ធផលយើងចាប់ផ្ដើមមើលឃើញ ហើយនៅវិទ្យាស្ថានCDRI បើសិនជារើស៤នាក់ គឺចាំបាច់ត្រូវតែ២នាក់ជាស្ត្រីតែម្ដង ហើយអង្គការច្រើនណាស់ដែលអនុវត្តនូវភាពសមធម៌នេះ កូនសិស្សខ្ញុំមានជាច្រើនហើយនៅពេលដែលខ្ញុំរើសកូនសិស្សខ្ញុំម្ដងៗ គឺច្បាប់មួយគឺត្រូវតែ៥០% ត្រូវតែជាស្ត្រី ដូច្នេះការដែលយើងចាប់ផ្ដើមនិយាយការដែលយើងចាប់ផ្ដើមចែករំលែកការដែរយើងចាប់ផ្ដើមអនុវត្ត ខ្ញុំបាទសង្ឃឹមថា ១០ឆ្នាំ២០ឆ្នាំទៀតស្ត្រីហ្នឹងព្រោងព្រាតតែម្ដង ប៉ុន្តែទាល់តែយើងចាប់ផ្ដើមធ្វើពីពេលនេះទៅ ។ ពេលដែលយើងប្រជុំគ្នានេះ យើងបានអញ្ជើញស្ត្រីតាមរយៈភ្នាក់ងាររបស់យើង ដែលរៀបចំយើងបានអញ្ជើញច្រើនណាស់ ប៉ុន្តែដូចបងមានប្រសាសន៍អញ្ចឹងមានពេលខ្លះស្ត្រីគាត់មានភារៈកិច្ចនៅផ្ទះហ្នឹងច្រើន ដូច្នេះមានពេលខ្លះគាត់មិនបានមកចូលរួមមិនមែនថាយើងមិនបានអញ្ជើញទេ ព្រោះយើងដាក់ទិសដៅថា៥០%អោយបានជាស្ត្រី ប៉ុន្តែនៅទីណាក៏ដោយមិនថានៅទីនេះទេលទ្ធផលបានមកដូចសព្វថ្ងៃហ្នឹងអញ្ចឹង ក៏ប៉ុន្តែបើសិនជាយើងមើលទៅប៉ុន្មានឆ្នាំទៀតតែ៧ហ្នឹងអត់ផងតែ១ហ្នឹងអត់ផង ដូច្នេះវាមានការកើនឡើងអញ្ចឹង កើនឡើងជាលំដាប់ហើយយើងតោងតែទទួលស្គាល់ថាកិច្ចការធំៗ អញ្ចឹងតោងតែរង់ចាំពេលវេលាអោយវាស៊ីចង្វាក់គ្នា បានមានពេលណាមួយនោះអាចនឹងកើតឡើងបាន ។ ហើយនៅខេត្តដែលយើងបានឆ្លងកាត់ គឺបងៗស្ត្រីហ្នឹងគាត់មានប្រសាសន៍ខ្លាំងៗរបស់គាត់ណាស់នៅក្នុងរឿងការបោះឆ្នោតហ្នឹង ដូច្នេះហើយខ្ញុំកំពុងតែនៅរង់ចាំស្ដាប់ប្រសាសន៍របស់បងស្រីនៅឡើយសង្ឃឹមថាបន្តិចទៀតនឹងបានលឺ។ សូមអញ្ជើញលោកអ៊ំមានប្រសាសន៍

១២. លោក សំ សុផាត (អត់ប្រាប់ឈ្មោះពេលឡើង តែក្នុងListមានដាក់)

ខ្ញុំសូមគោរព និងសូមថ្វាយបង្គំព្រះអង្គនៅទីនេះ។ ខ្ញុំសូមលើកបញ្ហាទាក់ទងនឹងការងារបោះឆ្នោតដែរ ខ្ញុំយកមតិខាងភូមិចាអ៊ុងចំពោះស្ត្រីដែលគាត់ចង់ចុះឈ្មោះបោះឆ្នោត ហើយឯកឧត្តមនៅឆ្ងល់ស្រុកនេះមាន១៥ឆ្នាំ សូមជំរាបថា១៣ម៉ឺននាក់ក្នុងខេត្តរតនះគីរី ជនជាតិភាគតិចរឺជនជាតិដើមនេះមានប្រហែលជា៨៥ទៅ៩០%ហើយ គាត់ឈ្មោះថាជនជាតិភាគតិចមែនតែចំនួនគាត់ច្រើនជាងគេបង្អស់ ដូចស្រុកអូរជុំអញ្ចឹងប្រហែលជាជាប់៩០%ហើយដែលជាជនជាតិដើមរបស់គាត់ ហើយខ្មែរយើងអីនៅតាមផ្សារតិចតួចទេ ហើយភាគច្រើនគឺគាត់ហ្នឹងតែម្ដង ។ ខ្ញុំសូមជំរាបថាប្រពៃណីដែលយកប្រពន្ធពីក្មេងនោះវា សេរីពេកមានផ្ទះក្រមុំហើយមានផ្ទះកំលោះទៀត ហើយដាក់ឆ្ងាយពីម្ដាយ តាំងអាយុ១២ឆ្នាំឡើងដល់១៣ឆ្នាំ បើយើងនិយាយគិតពីប្រវត្តសាស្ត្រខ្មែរពីដើមគេថា ១២ឆ្នាំមានពីធីហែរកូនក្រមុំ យកទៅអោយ តាមប្រវត្តិសាស្ត្រដើមខ្ញុំធ្លាប់រៀនតិចតួចដែរថា អ្នកណាបានទទួលគឺថាអ្នកហ្នឹងអោយចូលម្លប់ទៅ ហើយត្រូវប្រគេនទៅអាចារ្យៗទៀតពីដើមនៅយប់ ខ្ញុំនិយាយជ្រុលបន្តិចហើយ គេគ្រប់អាយុតាំងពី១២រឺ១៣ឆ្នាំហ្នឹង មួយអាយុមនុស្ស១២ឆ្នាំខ្មែរ តែចូលមកដល់ទៀតចូល១៣ឆ្នាំគេតែងចូលអញ្ចឹង ហើយប្រពៃណីវាជាប់មកអញ្ចឹង ហើយទៅបន្ទោសគាត់យ៉ាងម៉េចបើគាត់ខ្មែរដើម ហើយ១៤-១៥ឆ្នាំដែលគាត់យកប្ដីយកប្រពន្ធគឺថាត្រឹមត្រូវហើយ ព្រោះគាត់គិតថាមាននរណាមកកាន់កាប់គាត់ព្រោះគាត់មកនៅអញ្ចឹង យើងធ្វើយ៉ាងម៉េចបើទៅជាម្ដាយគេ ហើយមិនអោយចុះឈ្មោះបោះឆ្នោតទៀត តើគិតយ៉ាងម៉េចរឿងហ្នឹង ? សូមឯកឧត្តមយកទៅពិចារណា ខ្ញុំសូមជំរាបឯកឧត្តមគ្រាន់តែទុកជាទុនទេ ។សូមអរគុណ

១៣. លោក ឱកសេរីសោភក្តិ៍

សូមអញ្ជើញ បន្តទៅទៀតព្រោះនៅក្នុងយន្តការបោះឆ្នោតហ្នឹងវាមាន ការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះបេក្ខជន ការចុះឈ្មោះគណបក្សនយោបាយ ការចុះឈ្មោះបញ្ជីបេក្ខជន យុទ្ធនាការឃោសនាបោះឆ្នោត ការបោះឆ្នោតរាប់សន្លឹកឆ្នោត

យុទ្ធនាការបណ្តឹង ការប្រកាសលទ្ធផល មានយន្តការច្រើនណាស់ដំណាក់ៗកាល តើទាំងអស់ហ្នឹងមានបញ្ហាអ្វីខ្លះនៅខេត្តយើង ? សូមលោកបងមេត្តាមានប្រសាសន៍។

១៤. លោក សាម សារឿន ( ក្រុមប្រឹក្សា ឃុំកាចាញ )

ក្នុងអង្គប្រជុំនាឱកាសនេះ គឺខ្ញុំសូមសំនូមពរ ដល់គណៈកម្មាធិការបោះឆ្នោត ពន្យាពេលការចុះឈ្មោះបោះឆ្នោតអោយបានច្រើនបន្តិច ព្រោះប៉ុន្មានឆ្នាំកន្លងមកហើយ២០ថ្ងៃ គឺថាមិនគ្រប់គ្រាន់ទេ បើភូមិកាចាញមួយគឺទាំងមូលសិតតែជាកម្មករទាំងអស់ពេលព្រឹកទៅពលកម្ម ពេលថ្ងៃវិលមកវិញម៉ោង២ម៉ោង៣ ហេតុនេះស្មេរ្មទឃុំបើកការិយាល័យចុះឈ្មោះបោះឆ្នោតបានតែ២-៣ម៉ោងទេ ក្នុងមួយភូមិៗបានតែ៣ថ្ងៃទេ ហេតុនេះសល់អ្នកដែលគ្រប់អាយុបោះឆ្នោតច្រើនណាស់ រាល់ថ្ងៃហ្នឹងអ្នកដែលមិនទាន់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រហែលជា១០០នាក់ដែលមិនទាន់មានឈ្មោះ ហើយខ្ញុំសង្ឃឹមថាទៅមុខទៀតនឹងប្រហែលជាដូចតែគ្នាហ្នឹង បើមិនពន្យាពេលអោយបានច្រើនទេ ប្រហែលជាថ្ងៃចុះឈ្មោះមិនទាន់ទេ៣-៤ម៉ោងធ្វើបាន៤-៥នាក់វិលមកវិញ ហើយគ្រប់ភូមិដើរចល័តគ្រប់មួយភូមិមួយថ្ងៃពីរថ្ងៃៗ សួរថាអស់មិនអស់ ហើយណាមួយទៀតឃុំកាចាញយើងខ្ញុំមានជនចំនូលថ្មី មកពីក្រោមមកនៅ៤-៥ឆ្នាំគាត់មិនរវីរវល់រឿងចុះឈ្មោះបោះឆ្នោតក៏មានដែរ ។ ខ្ញុំសង្កេតឃើញអញ្ចឹង គឺថាជួនកាលមក១០ឆ្នាំ ហើយមិនដែលទៅបោះឆ្នោតម្តងក៏មានដែរ មូលហេតុមកពីយើងមិនបានទៅផ្សព្វផ្សាយ អំពីការចុះឈ្មោះបោះឆ្នោតក៏អត់បានផ្សព្វផ្សាយទូលំទូលាយដល់គ្រប់មជ្ឈដ្ឋានហេតុនឹង បងប្អូនខ្លះគាត់អត់ដឹងខែណាគេចុះឈ្មោះបោះឆ្នោត ពេលវេលាខ្លីទៀត ហេតុហ្នឹងគឺថាព្រងើយៗគាត់រវល់តែរកស៊ីរកររបស់គាត់ គាត់ធ្វើមិនដឹងមិនលឺយើងអត់បានឃោសនាតាមឃោសនៈស័ព្ទប្រាប់ទីកន្លែងហេតុនិងនាំអោយប្រជាជនយើងខ្លះថាមិនបាច់ឈឺក្បាលទេ បោះឆ្នោតអោយនរណាក៏ដូចនរណាដែរនេះវាអញ្ចឹង ហេតុនេះយើងគួរធ្វើម៉េចជំរុញអោយគាត់យល់ដឹងអំពីសិទ្ធរបស់ប្រជាពលរដ្ឋដើម្បីគាត់ធ្វើតួនាទីកាតួបកិច្ចរបស់ប្រជាពលរដ្ឋ អោយបានចេះភ្ញាក់រលឹកចេះយល់ដឹងនូវអត្ថន័យការបោះឆ្នោតអោយបានស៊ីជំម្រៅ នេះខ្ញុំសូមប៉ុនណ្ណឹងនេះខ្ញុំប្រាប់ត្រង់ជាមួយបងប្រធានមន្ទីអប់រំបន្តិច ខ្ញុំចង់មានយោបល់បន្តិចទេ និយាយពីសមាសផលវីក៏ Gender ហេតុម៉េចបានថាស្ត្រីមិនសូវបានប្រឡូកក្នុងគោលនយោបាយរឺក៏ជាមន្ត្រីរាជការ ? មូលហេតុមួយស្រីៗនិងគឺគាត់បានលើកហើយគឺថារៀនទៅមុខ មិនសូវបានទេ មួយទៀតគ្រួសារក្រីក្ររៀនមិនចប់ឌីប្លូមទេ មូលហេតុមួយមានការពុករលួយមួយចំនួនពេលប្រឡងសាញ្ញាប័ត្រឌីប្លូម និងត្រូវបង់យ៉ាងតិចក៏៥០ដុល្លារ កន្លែងហ្នឹងហើយដែលកូនអ្នកក្រស្រីត្រូវតែថយទៅថែមទៀតហើយហេតុហ្នឹងបើសិនជាមន្ទីអប់រំនិង ក្រសួងអប់រំក៏មានគោលនយោបាយមួយលើកកំពស់កូនស្រី គឺកុំយកសេវាកន្លែងហ្នឹងដើម្បីជំរុញអោយគ្នារៀនទៅមុខទៀតនិងបានដល់ថ្នាក់ខ្ពស់ ដល់បានថ្នាក់ខ្ពស់គាត់ចេះ ហើយគាត់រៀនហើយ គាត់ឈរឈ្មោះជាក្រុមប្រឹក្សាឃុំបានហើយបើគាត់មិនចេះអក្សរធ្វើម៉េចគាត់ ហានគាត់មិនហានទេ ត្រង់កន្លែងហ្នឹងខ្ញុំសូមបញ្ចប់យោលបល់ត្រង់ប៉ុនណ្ណឹង សូមអរគុណ។

១៥ លោក ផាន់ ភិរុណ ( មន្ត្រីមកពីមន្ទីអប់រំយុវជន និងកីឡា ខេត្តរតនៈគីរី )

អំបាញ់មិញគាត់បាននិយាយទាក់ទិនអំពីការអប់រំ ប្រកបដោយអំពើរពុករលួយ ក៏ប៉ុន្តែខ្ញុំមិនប្រកាន់ទេ ប្រទេសខ្មែរយើងកាលពីសម័យមុនឆ្នាំ៧០ បើតាមខ្ញុំដឹងខាងរតនៈគីរីមានអនុវិទ្យាល័យតែមួយទេហើយបឋមសិក្សាមានតែ២គត់ ហើយក្រោយពីរំដោះ៧៩មកទល់សព្វថ្ងៃនេះគឺរយៈពេល២៦ឆ្នាំនៃការរស់លើងវិញ យើងបានប្រមែប្រមូលអ្នកចេះបន្តិចបន្តួចទៅបង្រៀនអ្នកមិនចេះសោះហើយអ្នកចេះច្រើនទៅបង្រៀនអ្នកចេះតិច ហើយបានរក្សានិរន្តភាពរហូតមកដល់សព្វថ្ងៃនេះ ដែលខេត្តរតនៈគីរីមានសាលាមធ្យមសិក្សាដល់ទៅ៩កន្លែង សិស្សដែលមានធ្លាប់តែរាប់រយឥឡូវជាងពីរម៉ឺននាក់ ហើយកូនក្មួយអ្នករតនៈគីរីភាគច្រើនចេញពី វិទ្យាល័យសម្តេចឪសម្តេចម៉ែនេះចំនួន៥០% នៃបុគ្គលិកសិក្សាដែលមានចំនួនជិត៧០០ ហើយមានមន្ត្រីរាជការមួយចំនួនដែលជាកូនចៅអ្នករតនៈគីរីនេះធ្លាប់បានទទួលអាហាររូបករណ៏ដែលមកពីសហគមន៏ក្រីក្របំផុតបានទទួលជាមន្ត្រីរាជការមួយចំនួនក៏មានអង្គុយនៅកន្លែង

នេះដែរប៉ុន្តែខ្ញុំសោកស្តាយត្រង់ថាលោកមានប្រសាសន៏ថា គួរក្រសួងអប់រំនិងមន្ទីអប់រំមានគោលការណ៏យ៉ាងណាដើម្បីកុំអោយមានអំពើរពុករលួយនេះជាការប្រសើរ សង្គមមួយកើតឡើងវាមិនបានម៉ត់ម៉ងល្អទាំងអស់ទេ មនុស្សម្នាក់ដែលខ្លួនយើងគង់តែមានកំហុសខ្លួនយើងរឺក៏ខុសក្នុងគ្រួសារយើងក៏មានដែរ ចុះទំរាំសង្គមទាំងមូលធ្វើម៉េចអោយបានត្រូវចិត្តទាំងអស់គ្នា សូម្បីតែឯកឧត្តមដែរអញ្ជើញមក ពីស្រុកបារាំងខ្ញុំជឿប៉ុន្តែសង្គមបារាំងដែលមានតែសង្គមមួយដែលមានអរិយធមិហើយតើវាសុក្រឹត្យហើយរឺនៅ ? យប់មិញខ្ញុំមើលប្រទេសបារាំងមិនមែនចេះភាសារបារាំងទេ គ្រាន់តែមនុស្សនៅប្រទេសបារាំងដែលគ្មានការងារធ្វើនៅស្រុកបារាំងគឺធ្វើបាតុកម្មពាសទឹកពេសដីរាល់តែថ្ងៃ នៅបាងកកនយោបាយរាល់ថ្ងៃដោយសារប្រជាជនក្តៅក្រហាយអ្នកខ្លះមានការងារធ្វើមិនស្មើរគ្នាមិនទទួលផលអំពីសង្គមធ្វើបាតុកម្មទំលាក់នាយករដ្ឋមន្ត្រី ចុះទំរាំបើមនុស្សខ្មែរដែលមានទំលាប់ថា កូនអើយបើពូជយើងធ្វើស្រែនៅតែស្រែអញ្ចឹងបើឪពុកខ្ញុំប្រើពាក្យថាស៊ីឡូធំនៅតែស៊ីឡូធំអញ្ចឹង និយាយអោយចំទៅគឺថា ឪពុកខ្ញុំគាត់ជាអ្នកស្រែចំការ គាត់កាន់តែនរង្គ័លគាត់ថាទៅរៀនធ្វើអី ពូជយើងអ្នកស្រែនៅតែស្រែ សព្វថ្ងៃហៅម៉ែៗ អំបាញ់មិញបានសួរហើយថាបើម្តាយទុកកូនស្រីនៅក្បែរខ្លួនវាស្រួលទេ គាត់ឆ្លើយទាំង អស់គ្នាថាស្រួលចុះបើទុកអាកំលោះមួយនៅក្បែរគាត់ថាដំបៅទ្រូង អញ្ចឹងយើងឈប់បញ្ចាំងអំពីអត្តាភាពខ្លួនយើងថាតើប្រាកដជា ក្រសួងអប់រំយុវជននិងកីឡា ប្រាកដជាបង្កើតឡើងនូវអំពើរពុករលួយមែនរឺអត់ ? វាមិនដែលសង្គមមួយបង្កើតអំពើរពុករលួយ តាមរយៈការផ្ទេរចំណេះដឹងទេ សម្តេចនាយករដ្ឋមន្ត្រីតែងនិយាយថាកុំអោយមានសញ្ញាប័ត្រដោយគ្មាចំណេះដឹងបើមានសញ្ញាប័ត្រហើយ មិនចេះគេមិនរាប់ថាជាមនុស្សចេះដឹងទេ ។ ភាសិតបារាំង----------វាមិនដែលនរណាសុក្រឹត្យទេ-----------វាមិនដែលសិតតែបរិសុទ្ធទេ ក៏ប៉ុន្តែខ្ញុំសូមសារភាពថា ប្រហែលជាមានករណីនេះតាមរយៈសិស្សនោះខ្ជិលសិស្សនោះអវត្តមានបើមួយថ្ងៃរៀន៤ម៉ោង បើមួយថ្ងៃរៀន៨ម៉ោង ប៉ុន្តែសិស្សខ្លះអវត្តមាន ដោយសារអីចេញពីផ្ទះមកទៅចូលមុខវេទិការដូចនៅមុខផ្ទះខ្ញុំពេញៗរាល់យប់ មានពេលខ្លះបន្ទាត់ក្មេងដេញ វៃមិនដឹងកូនគេកូនខ្ញុំទេ ខឹងខ្លះអីខ្លះដេញវៃរាល់តែយប់នៅតារាងបាល់ទាត់យើងហ្នឹងអត់មានទៅរៀនដល់ទៅពេលធ្លាក់ពិន្ទុយុតឃិតជាមួយគ្រូ លោកគ្រូខ្ញុំមិនបានឡើងថ្នាក់ទី៨ទេឆ្នាំនេះ ចុះឡើងៗទៅយុតឃិតជាមួយគេទៅអោយគ្រូនោះ១ម៉ឺន២ម៉ឺនទៅនេះមានករណីនិងមែនវាមាន ពេលប្រឡងក្រសួងអប់រំមានទិសដៅជាក់លាក់ គឺផ្ទេរចំណេះដឹងអោយមនុស្សទូទៅ ពលរដ្ឋទូទៅ យុវជនទូទៅមាន កាត្តបកិច្ចទទួលចំណេះដឹង គ្រាន់តែពេលប្រឡងមិនដែលកាន់សៀវភៅសោះ មិនដែលចូលសាលាសោះ ទៅយុតឃិតជាមួយគ្រូមួយ ចំនួនដែលគាត់អត់មានលុយមានអីចាយអាណ្ណឹងជារឿងមួយប្រាកដជាមាន ប៉ុន្តែខ្ញុំមិនថារបបសង្គមបច្ចុប្បន្នមិនមានទេ មិនអោយមានអំពើរពុករលួយក្នុងសាលារៀនទេ ខ្ញុំដឹកនាំវិស័យនេះយូរហើយខ្ញុំមិនអោយមានអំពើរពុករលួយ ក៏ប៉ុន្តែបើសិនជាក្មេងនោះទៅរៀនប្រាកដជារៀនពិន្ទុវា ជាប់គ្មាននរណាទៅទំលាក់វាទេព្រោះនេះជាស្តង់ដារប្រលង ក៏ប៉ុន្តែកូនមួយចំនួនមិនទៅទេសូម្បីតែកូនខ្ញុំក៏ដូចគ្នាដែរ បាក់ឌុបនៅ ឆ្នាំ២០០៣ទៅប្រលងនិងគេម៉េចនិងកើតបើសិនជាឪពុកម្តាយមិនដឹងរឿងថាទាល់តែមានលុយទៅសូកគេ តែការពិតចំណេះនៅក្នុងខ្លួននេះវាគ្មានជាមូលដ្ឋានមិនអាចប្រកួតប្រជែងជាមួយនិងគេបាន ដែលការប្រលងនេះមិនមែនមន្ទីអប់រំក្រសួងអប់រំកំណត់ទេ ខ្ញុំជំរាបមិនមែនថាអ្នកឯងទាល់តែមាន៥០ដុល្លារមិនមែនទេ ហើយមួយទៀតថាតើធ្វើយ៉ាងម៉េចដើម្បីអោយកូនស្រីបានទៅសាលារៀន ខ្ញុំសូមជំរាបអង្គប្រជុំអោយបានដឹងថាវិស័យអប់រំនៅខេត្តរតនៈគីរី ដើម្បីអោយការអប់រំប្រកបទៅដោយសមធមិ មន្ទីអប់រំយុវជននិងកីឡា បានទៅសូមជំនួយនៅស្ថានទូតជប៉ុន ដែលគ្រាន់តែ---------២៩៨ទទួលអាហាររូបករណ៏មួយខែ៤៥ក៏មាន៩០ក៏មានហើយថ្មីៗ នេះដាក់អាហាររូបករណ៏នៅអនុវិទ្យាល័យបរកែវទៀតដើម្បីជួយកូនក្មួយជាស្ត្រីភេទដែលគ្មានឱកាសទៅសាលារៀននិងមិនមានឱកាសរៀនដល់៩ឆ្នាំ នេះហើយជាការយកចិត្តទុកដាក់ ក៏ប៉ុន្តែសួរថាប្រាកដជាកូនអស់ហ្នឹងវារៀនល្អទេ ? ខ្ញុំសូមជំរាបកូនខ្ញុំដែលវាចេញពីក្នុង គ្រួសារខ្ញុំទាំងមូលក៏មានភាពខុសៗគ្នា គេថាសារជាតិមនុស្សមិនដូចគ្នាទេ ដូចយើងប្រជុំអញ្ចឹង តាមពិតខ្ញុំក៏ជាមនុស្សដែលយល់ដឹង អំពីសារជាតិច្បាស់

សារជាតិមនុស្សវាមិនដូចគ្នាទេ មានខ្លះស្រួលប្រដៅ ខ្លះដុះដោយខ្លួនឯងក៏មានដែរ ។ អញ្ចឹងសូមលោកសារឿន អភ័យទោសបញ្ហានេះ ខ្ញុំជឿថាមានប៉ុន្តែវាមិនមែនជារបស់ក្រសួងរឺជាពាក្យបញ្ជាត្តិអោយធ្វើដូច្នេះទេ ។ ខ្ញុំបាទសូមអរគុណ

១៦. លោក ឱកសេរិសោភក្តិ

សូមអរគុណចំពោះលោកបងទាំងពីរ នេះជាកត្តាមួយដែលបង្ហាញអោយឃើញថា ខ្ញុំបាទចង់ស្តាប់ថាយើងមានការអ្វីយើងចង់និយាយយើងនិយាយនៅមុខគ្នាតែម្តង រួចហើយបានយើងយល់គ្នាបាន ព្រោះអីទាំង២និងសុទ្ធតែមានមូលដ្ឋានល្អៗរឹងមាំដូចគ្នាហើយ អង្គប្រជុំសិតតែបានស្តាប់ទាំងអស់គ្នា ខ្ញុំបាទបានអនុញ្ញាត្តអោយមានមតិនៅក្រៅអំពីបញ្ហាបោះឆ្នោត ដោយសារបញ្ហានេះជាការសំខាន់ណាស់ហើយចូលរួមនៅក្នុងវប្បធម៌នៃការពិភាក្សាគ្នា ក៏ប៉ុន្តែចាប់ពីពេលនេះតទៅខ្ញុំបាទសូមអនុញ្ញាត្តអោយអង្គប្រជុំត្រឡប់មកបញ្ហារឿង បោះឆ្នោតវិញ ថាតើយើងមានបញ្ហាអ្វីខ្លះ ? ខ្ញុំសូមជូនសំដីទៅវាគ្មិនម្នាក់ទៀតចុងក្រោយមុននឹងយើងសម្រាកពិសារកាហ្វេ។

១៧. លោក គង់ ចាន់ ( តំណាងគណបក្សសមរង្ស៊ី ខេត្តរតនៈគីរី )

សូមគោរពសាមាជិក សមាជិកានៃអង្គប្រជុំទាំងមូល សូមថ្វាយបង្គំដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ។ ជាញឹកញាប់មកហើយដែលខ្ញុំបានចូលរួមនៅក្នុងអង្គប្រជុំវិសិក្ខាសាលាស្តីពីការងារបោះឆ្នោតនៅក្នុងខេត្តរតនៈគីរីនេះ ហើយនៅក្នុងនេះដែរខ្ញុំក៏សូមចូលរួមសំនួរ៣ ដើម្បីជូនឯកឧត្តមយកទៅពិភាក្សានិងជួយកែសម្រួលនូវអ្វីដែលមានភាពខុសឆ្គងវៀសវាង ការបង្ការនូវការទំនាស់នៅក្នុងពេលយុទ្ធនាការនៃការបោះឆ្នោត ។ បញ្ហាទីមួយ ខ្ញុំសូមសំនូមពរអោយគជបមេត្តាជ្រើសរើសមន្ត្រីថ្នាក់SEC,PEC,POSសូមអោយមាន តម្លាភាព នេះបញ្ហាទី១ ។ បញ្ហាទី២ ខ្ញុំសូមអោយPECក៏ដូចជាSECជួយដោះស្រាយរាល់បណ្តឹងវិវាទទាំងឡាយទាក់ទិននិងការបោះឆ្នោតក្នុងពេលបោះឆ្នោតអោយបានសមស្របទៅតាមនីតិវិធីច្បាប់បោះឆ្នោត ហើយអោយភាគីបណ្តឹងនោះទទួលយកការពិតហើយភាគីអ្នកចុងចោទនោះក៏ទទួលយកការពិតបានដូចគ្នា ខ្ញុំសូមសំនូមពរប៉ុណ្ណឹងបញ្ហាទី២ ព្រោះកន្លងមកកើតមានជាច្រើននៅខេត្តនេះដែលខ្ញុំបានទទួលជាអ្នកដើមបណ្តឹង ។ ចំពោះបញ្ហាទី៣ ការធ្វើប្រតិភូកម្មអំណាចរបស់គជបមកដល់ក្រុមប្រឹក្សាឃុំសង្កាត់ដែលទាក់ទិន និងការងារបោះឆ្នោត បញ្ហានេះខ្ញុំក៏ជាសមាជិក្រុមប្រឹក្សាឃុំម្នាក់ដែរហើយខ្ញុំពិនិត្យឃើញថា ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំនេះ ជាការមួយដ៏ល្អបំផុតចំពោះការងារទាក់ទិននិងការបោះឆ្នោត ក៏ប៉ុន្តែគជបធ្វើប្រតិភូកម្មអំណាចតែការងារផ្សេងៗទេ ប៉ុន្តែនៅខ្វះការមិនបានបណ្តុះបណ្តាលសិក្សាចំពោះស្មៀនរឺក្រុមប្រឹក្សាឃុំសង្កាត់ ដែលទទួលបន្ទុកការងារបោះឆ្នោតនោះទាំងបច្ចេកទេស ទាំងរៀបចំឯកសារទាំងការផ្តល់ឯកសារក៏មានការយឺតយ៉ាង ដូច្នេះមានការរាំងស្ទះជាច្រើន កាលពីបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០០៣កន្លងទៅ ផ្តល់សម្ភារៈគឺមិនគ្រប់ដូចជា ហ្វីលដូចជាថ្មសំរាប់ដាក់ម៉ាស៊ីនថតរូប អញ្ចឹងឃុំឡាបាសៀកនៅជិតនេះខ្វះប៉ុណ្ណឹងហើយ ចំពោះឃុំផ្សេងៗដែលបងប្អូនយើងនៅឆ្ងាយដាច់ស្រយាលនោះ គាត់ខ្វះច្រើនជាងហ្នឹងហើយគាត់រហូតដល់រៃអង្គេសលុយគ្នាទិញហ្វីលទិញថ្មយកទៅដាក់ថតថែមហើយចំពោះថតអ្នកខ្លះថតបានមួយកំណាត់ទៅ ហើយខ្លះទៀតថតឃើញតែជើងហើយយើងសួរថាតើយកទៅបិទក្នុងប័ណ្ណបោះឆ្នោតបានដែររឺទេ ? អញ្ចឹងបានថាការផ្តល់សម្ភារៈទាល់តែយើងបង្រៀនទាល់តែយើងណែនាំអោយគាត់ធ្វើអាណ្ហឹងបានគាត់ធ្វើកើត ចុះបើធ្វើតែប្រតិភូកម្មតែអំណាច ហើយសម្ភារៈក៏ខ្វះបច្ចេកទេសក៏គ្មានតើយើងធ្វើបានដែរទេ ? គឺសូមសំនូមពរបែបហ្នឹង ។ បញ្ហាមួយ ទៀតជាប់និងនេះដែរ គឺបញ្ហាថវិការតឡូវប្រតិភូកម្មតែអំណាចហើយសម្ភារៈមួយចំនួនតូចហើយថវិការក្នុងមួយពេលបោះឆ្នោតហ្នឹង មានតែបន្តិច ដូច្នេះហើយគ្រាន់តែស្មៀនហើយនិងក្រុមប្រឹក្សាឃុំជឹកជញ្ជូនតុកៅអីចល័តការងារចុះឈ្មោះបោះឆ្នោតហ្នឹងមិនគ្រាន់ផង ហើយនៅការងារឃោសនាផ្សព្វផ្សាយអីតាមវិឃោសនៈស័ព្ទអោយប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោតនៅកង្វះខាតទៀត អញ្ចឹងកាលណាប្រើប្រតិភូកម្មអំណាចអោយឃុំអញ្ចឹងមានតែយកលុយពីឃុំប្រើ ហើយចុះបើលុយ

រដ្ឋបាលក្នុងមួយឆ្នាំមាន១លានជាង ខ្ញុំសួរថាតើយើង ប្រើបែបណាបើប្រើច្របូកច្របល់បែបនេះ ។ ខ្ញុំសូមអភ័យទោស និងសូមអរគុណ និងសូមអោយឯកឧត្តមជួយសម្របសម្រួលបញ្ហា នេះសូមអរគុណ។

១៨. លោកស្រី តេង បុត្រទេពី ( ជំទប់ទី១ ឃុំឡាបាសៀក )

ខ្ញុំថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ និងសូមគោរពអស់លោក លោកស្រីដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ ។ថ្ងៃនេះបញ្ហាផ្សេងៗដែលអស់លោកលើកឡើងនៅខាងដើមមកមានការពិតហើយនឹងត្រឹមត្រូវ ប៉ុន្តែខ្ញុំសូមលើកនូវបញ្ហាតិចតួច ដែលកន្លងមកវាមានជាក់ស្តែងនៅក្នុងមូលដ្ឋានឃុំនេះ ។ គឺការចុះបញ្ជីអត្រានុកូដ្ឋានគឺប្រជាពលរដ្ឋដែលមានសញ្ជាតិខ្មែរ ដូច្នេះនាងខ្ញុំចង់មានសំនូមពរទៅដល់ខាងនរគលបាលស្ថិតិ ដែលបន្តិចទៀតនេះនឹងចុះធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូច្នេះអ្នកដែលធ្វើអត្តសញ្ញាណប័ណ្ណបានគឺមានសញ្ជាតិជាខ្មែរពិត បើយ៉ាងហោចណាស់ក៏សូមអោយសំគាល់ទៅតាមភាសារសាច់ឈាមដែរ បើសិនជាអ្នកដែលគ្រប់អាយុ១៨ឆ្នាំត្រូវតែធ្វើអត្តសញ្ញាណប័ណ្ណព្រោះបន្តិចទៀតច្បាប់នឹងចេញថាមានអត្តសញ្ញាណប័ណ្ណនឹងអាចបោះឆ្នោតបាន។ ដូច្នេះវាមានបញ្ហាខ្លះពីមុនកន្លងៗមកហើយ ដូច្នេះបានខ្ញុំសូមអោយសុក្រឹត្យក្នុងការចុះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ កាលពីឆ្នាំ២០០២កន្លងមកក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំក្នុងអាណត្តិនេះហ្នឹង គឺនាងខ្ញុំជាអ្នកសង្កេតការណ៍នៅក្នុងការិយាល័យ០០១៩ភូមិថ្មី ហើយលោកគ្រូបង្រៀនមួយណាជាប្រធានការិយាល័យនោះ? ដល់ពេលដែលប្រជាពលរដ្ឋចូលទៅបោះឆ្នោតម្តង៣-៤នាក់ច្រើនគ្នាដែរ ព្រោះវាមានការចង្អៀតស្រាប់តែខ្ញុំសង្កេតឃើញថាមានជនជាតិវៀតណាមម្នាក់គឺពិតជាវៀតណាមអត់ចេះខ្មែរ ខ្ញុំក៏សូមថា នែអូនឯងខ្មែររឺមិនមែនខ្មែរចូលមកបោះឆ្នោត ? គ្រវីក្បាលហើយថាខ្ញុំខ្មែរ ខ្ញុំសូមមើលកាតបោះឆ្នោតហ្នឹង គឺកាតបោះឆ្នោតពិតពណ៌ខៀវ រូបថតវៀតណាមឈ្មោះខ្មៀនយ៉ានឌើរ សញ្ជាតិខ្មែរច្បាស់ណាស់ ចូលទៅបោះឆ្នោត ហើយខ្ញុំថាអូនមិនមែនខ្មែរកុំបោះឆ្នោតអោយខ្មែរ ប្រធានការិយាល័យខ្ញុំនិងគេច្រានខ្ញុំចេញគេ ថាមិនមែនទេ គេមានឯកសារត្រឹមត្រូវរបស់គេ ហើយគេត្រូវតែបានចូលបោះ អញ្ចឹងក៏គេបោះទៅ។ ហើយនៅក្នុងការចុះបញ្ជី អត្រានុកូដ្ឋាននេះ នាងខ្ញុំជាមន្ត្រីអត្រានុកូដ្ឋានសកម្មបំផុតក្នុងការចុះយុទ្ធនាការនៅគ្រប់ភូមិទាំងអស់ក៏ដូចជានៅក្នុងឃុំដែរ ការចុះនេះពីថ្ងៃមុននិងមានបងប្អូនជនជាតិភាគតិចម្នាក់ អាយុហ្នឹងប្រហែលជានៅក្នុងវ័យសិក្សាហើយខ្ញុំកាលធ្វើបញ្ជីអត្រានុកូដ្ឋាននេះខ្ញុំខ្លាច បំផុតត្រង់ថាខុសនិងសញ្ញាប័ត្រសិស្សនៅក្នុងសាលាគ្នាមិនអាចប្រើប្រាស់បានជាផ្លូវការ ។ ពិបាកដល់មន្ត្រីអត្រានុកូដ្ឋានកែអោយទៀត ដូច្នេះខ្ញុំសួរថាតើអូននៅក្នុងវ័យសិក្សារឺមួយក៏អូនឈប់រៀនហើយ ? ថាខ្ញុំនៅរៀនថ្នាក់ទី១០ អញ្ចឹងប្អូនគ្រប់អាយុធ្វើខ្លួនឯងហើយគឺ ១៨ឆ្នាំ វាអាចផ្តិតមេដៃខ្លួនឯងបាន អញ្ចឹងទៅយកកាតមកក្រែងលោកខុសថ្ងៃខែឆ្នាំនៅក្នុងសាលា អញ្ចឹងគាត់ក៏ទៅយក ទៅយក អាយុទើបតែ១៥ឆ្នាំជាងអត់ទាន់គ្រប់១៦ឆ្នាំទេ សួរថាយ៉ាងម៉េចបានជានៅក្នុងសាលាអូនអត់ទាន់គ្រប់អាយុ ហើយនៅក្នុងប័ណ្ណគ្រួសារ របស់ឱពុកម្តាយគ្រប់អាយុ ? គាត់ក៏ឆ្លើយថាបងខ្ញុំគេបន្ថែមអោយខ្ញុំគ្រប់អាយុបោះឆ្នោតចាប់ពីឆ្នាំ២០០៣នេះ អញ្ចឹងឃើញថា រឿងហ្នឹងវាអត់សុក្រឹត្យ វាអត់ទាន់ច្បាស់ការចុះបញ្ជីអត្រានុកូដ្ឋានព្រោះកន្លងមកមានអ្នកខ្លះអាយុ២០-៣០ហើយស្រាប់តែនៅក្នុង បញ្ជីអត្រានុកូដ្ឋាន១២ឆ្នាំ១៣ឆ្នាំ អញ្ចឹងវាមិនសុក្រឹត្យសោះវាប៉ះពាល់ទៅដល់ការចុះឈ្មោះបោះឆ្នោត។ ខ្ញុំមានតែប៉ុនណ្ណឹងទេ សូមអរគុណ។

១៩. លោក ឱកសេរីសោភក្តិ

ខ្ញុំបាទ សូមអរគុណដល់វាគ្មិនទាំងអស់ដែលបានមានប្រសាសន៍ សក្តិសមណាស់នៅក្នុងបញ្ហាទាំងប៉ុន្មាននេះ ដូច្នេះយើងសម្រាក១៥នាទីសិនមុននិងចូលមកបន្តការពិភាក្សាបន្តទៅទៀត ។ សូមអរគុណ។

២០.លោក ឱកសេរីសោភក្តិ

ខ្ញុំសូមថ្វាយព្រះថេរានុថេរៈគ្រប់ព្រះអង្គសាជាថ្មីម្តងទៀត ខ្ញុំបាទសូមគោរពអង្គប្រជុំទាំងមូលតែម្តង ។ ហើយមុននិងយើងសម្រាកនេះគ្មានអ្វីដែលធ្វើអោយយើងសប្បាយនិងមោទនភាព ជាងការដែលបានឃើញខ្មែរយើងជជែកគ្នាទោះបីជារឿងនឹងលំបាករឿង នឹងអាចធ្វើអោយយើងទាស់ចិត្តគ្នាក៏ដោយ ប៉ុន្តែរំភើបណាស់ដែលបានឃើញយើងជជែកគ្នាត្រង់ទៅត្រង់មកយ៉ាងនេះហើយទទួលគ្នា ទៅវិញទៅមកបាន នេះហើយដែលខ្ញុំបាទជឿថាខប់សែលប្រ៊មនេះ បំរើនូវវប្បធម៌នៃការពិភាក្សាពិតប្រាកដមែន ។ ខ្ញុំបាទបន្តទៅនេះសូមជូនសំដីទៅបងប្រធាន PEC និងបងវរសនីយ៍ទោខាងប៉ូលីស បើសិនលោកចង់ធ្វើអត្ថធិប្បាយទាក់ទងរឿងអត្តសញ្ញាណប័ណ្ណជាតិ ហើយបងប្រធាន PEC ទាក់ទងទៅនិងប្រធានបទផ្សេងៗទៀតដែរបានលើកឡើងបន្ទាប់មកខ្ញុំបាទ នឹងជូនសំដីទៅអង្គប្រជុំវិញដើម្បីយើងបន្តស្រង់នូវបញ្ហាប្រឈមផ្សេងៗទៀត ដែលអង្គប្រជុំមើលឃើញនៅក្នុងការឈានទៅរកការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០៧ និងការរៀបចំការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ២០០៨។

២១. លោក ប៉ែន ឈុនឌី

សូមអរគុណ ។ ខ្ញុំសូមបំភ្លឺនូវសំនួរដែលបានលើកឡើងព្រឹកមិញមួយចំនួន ដើម្បីជូនអង្គប្រជុំទាក់ទងទៅនិងការសុំការពន្យាពេលនៅក្នុងការបោះឆ្នោតដែលមតិនេះជាគំនិតមួយល្អ ក៏ប៉ុន្តែខ្ញុំគិតថាគជបកំណត់ថ្ងៃគឺមានច្បាប់សម្រាប់កំណត់ ហើយកាលណាយើងលើកចុះឈ្មោះហួសដល់ជាង២០ថ្ងៃគឺយើងមិនអាចធ្វើបានទេ ព្រោះនេះជាការកំណត់តាមផ្លូវច្បាប់ដែលយើងត្រូវអនុវត្តហើយមួយទៀតគំនិតនេះជាគំនិតល្អ ខ្ញុំទទួលស្គាល់ថាយើងគួរតែធ្វើការបោះឆ្នោតអោយវែង សំរាប់ប្រជាពលរដ្ឋយើងមានឱកាសបានចូលរួមចុះឈ្មោះបានទាន់ពេលវេលានិងគ្រប់ៗគ្នា ។ ចំពោះសម្ភារៈដូចខាង លោកគង់ចាន់ គណបក្សសមរង្ស៊ីបានលើកឡើងក្នុងឆ្នាំ២០០៣មានការយឺតយ៉ាងរឿងសម្ភារៈ នេះជាការទទួលស្គាល់ពិតប្រាកដមែន ហើយគំនិតទាំងអស់នេះគណៈកម្មាធិការ រីក៏លេខាធិការដ្ឋានរៀបចំការបោះឆ្នោតនិងពង្រឹងការងារនេះឡើងវិញអោយបានល្អទៅថ្ងៃអនាគត។ ពាក់ព័ន្ធទៅនិងរឿង លោកស្រីតេងបុត្រទេពីដែលបានលើកឡើងពីរឿងមានជនជាតិវៀតណាមហ្នឹង គឺអាចចូលទៅក្នុងការិយាល័យបោះឆ្នោតបានគឺយើងផ្អែកទៅលើច្បាប់សំខាន់ បើច្បាប់របស់យើងគេមានឯកសាគ្រប់គ្រាន់ ហើយមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានអត្តសញ្ញាណប័ណ្ណ ជនជាតិវៀតណាមយើងមិនអោយទៅបោះឆ្នោតទេ ក៏ប៉ុន្តែគេមានឈ្មោះបោះឆ្នោតមានឯកសារគ្រប់គ្រាន់រឿងនេះគឺត្រូវបោះរឺមិនបោះគឺប្រធាន ការិយាល័យបោះឆ្នោតជាអ្នកសម្រេច ។ ការលើកឡើងនូវយោបល់របស់អស់លោក លោកស្រីនៅថ្ងៃនេះខ្ញុំគិតថាវាមានសារៈសំខាន់ណាស់ យ៉ាងហោចណាស់ក៏យើងឆ្លុះបញ្ចាំងគ្នាថា តើយើងធ្វើអីខ្លះដែលមិនត្រឹមត្រូវធ្វើអីខ្លះដែលត្រឹមត្រូវហើយមានចំនុចខ្វះខាតអីខ្លះដែលយើងគួរកែលំអរ ហើយពង្រឹងដើម្បីជ្រៀសវាងនូវចំនុចខ្វះខាតទាំងអស់នេះ ហើយខ្ញុំគិតថាការងារបោះឆ្នោតយើងនៅមាន២អាណត្តិក្រោយៗទៀតយើងនឹងមានបទពិសោធកាន់តែច្រើន មានការយល់ដឹងកាន់តែច្រើន ដូចជាទាក់ទងទៅនិងការចុះឈ្មោះបោះឆ្នោត ទាក់ទងទៅនិងដំណើរការបោះឆ្នោត ហើយនិងទាក់ទងការអនុវត្តច្បាប់ ហើយលទ្ធផលនៃអង្គប្រជុំយើង យើងនឹងទទួលបាននូវចំនុចអនុសាសន៏ជាច្រើនពីអស់លោក លោកស្រី ហើយអនុសាសន៏ទាំងអស់នេះហើយដែលកែរតំរូវនិងតំរង់ទិសការងាររបស់យើងកុំអោយមានកំហុសឆ្គងតទៅទៀត ។ ទាក់ទងទៅនិងរឿងអត្តសញ្ញាណប័ណ្ណ រឿងអត្តសញ្ញាណប័ណ្ណនេះវាជារឿងមួយសំខាន់ ណាស់ខ្ញុំគិតថាក្រសួងមហាផ្ទៃ កំពុងតែជំរុញការងារនេះខ្លាំងណាស់ ដើម្បីអោយមានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា ដើម្បីបានទៅបោះឆ្នោតគ្រប់ៗគ្នា ហើយទៅការបោះឆ្នោតលើកក្រោយៗទៀតយើងលែងប្រើប័ណ្ណបោះឆ្នោតហើយ យើងប្រើអត្តសញ្ញាណប័ណ្ណសម្រាប់ធ្វើ ការបោះឆ្នោតក្នុងករណីដែលយើងមិនអាច ប្រជាពលរដ្ឋដែលមានការមិនទាន់បានធ្វើអត្តសញ្ញាណប័ណ្ណនិងមានការប្រើទំរង់១០-១៨ មានបិទរូបថត សម្រាប់កាន់ចូលការិយាល័យបោះឆ្នោត នេះសម្រាប់ទៅថ្ងៃអនាគត ។ អញ្ចឹងហើយបានយើងអាចធ្វើ អត្តសញ្ញាណប័ណ្ណបានល្អហើយដូចលោកស្រី តេង បុត្រទេពី លែងមានកង្វល់ហើយព្រោះអី

អត្តសញ្ញាណប័ណ្ណហ្នឹង យើងធ្វើសុក្រឹត្យភាពច្បាស់លាស់ណាស់ជាជនជាតិខ្មែរជាពលរដ្ឋខ្មែរពិប្រាកដ អញ្ចឹងយើងអាចកាត់បន្ថយបាននូវបញ្ហាផ្សេងៗដែលអាចកើត មានឡើងនេះគឺខ្ញុំយល់ឃើញប៉ុននេះ សូមអរគុណ។

២២. ផែន ឌីណា ( ស្នងការរង នរគរបាល ខេត្តរតនៈគីរី )

ជាបឋមសូមគោរពអង្គប្រជុំ សូមគោរពគណអធិបតេយ្យនៅក្នុងអង្គប្រជុំ និងសមាជិកសមាជិកាទាំងអស់ជាទីគោរព ។ ក្នុងនាមខ្ញុំស្នងការខាងនរគលបាលខេត្តរតនៈគីរី តំណាងក្នុងថ្ងៃនេះដោយសារមានការពាក់ព័ន្ធទៅនិងអត្តសញ្ញាណប័ណ្ណ ខ្ញុំសូមលើកឡើងបន្តិច យោងតាមស្មារតីអង្គប្រជុំមហាសន្និបាតបូកសរុប របស់ក្រសួងមហាផ្ទៃតាមប្រសាសន៍សម្តេចហ៊ុនសែន នៅពេលបោះឆ្នោតខាងមុខនេះយើងនិងប្រើអត្តសញ្ញាណប័ណ្ណមកបោះឆ្នោតតែម្តង យើងលែងប្រើប័ណ្ណបោះឆ្នោតទៀតហើយ។ ពាក់ព័ន្ធទៅនិងការងារនេះ ដូចបានស្តាប់ប្រសាសន៍ អ្នកស្រីជំទប់ទី១ឃុំឡាបាសៀក ពាក់ព័ន្ធទៅនិងជនជាតិវៀតណាម ព្រោះអត្តសញ្ញាណប័ណ្ណនេះកន្លងមកយើងចេះតែជិតដាមជាប់មករហូតមក តាំងពីមុនប៉ុន្តែឥឡូវនេះគោលការណ៍ថ្មីរបស់ក្រសួងមហាផ្ទៃក៏ដូចជាអគ្គស្នងការនគរបាលជាតិ ក៏ដូចជាស្នងការយើងបានខិតខំយកចិត្តទុកដាក់ ពង្រឹងដល់មន្ត្រីដែលចុះធ្វើអត្តសញ្ញាណប័ណ្ណនេះនៅតាមបណ្តាលស្រុកឃុំដល់មូលដ្ឋាននោះ គឺថាយើងយកចិត្តទុកដាក់ ធ្វើអោយមានសុក្រឹត្យភាពចាប់ពីពេលនេះតទៅ អញ្ចឹងពីពេលនេះ តទៅយើងលែងបារម្ភហើយពីរឿងអត្តសញ្ញាណប័ណ្ណនេះ ខ្ញុំសូមលើកឡើងតែពីរឿងអត្តសញ្ញាណប័ណ្ណមួយទេ ហើយពាក់ព័ន្ធទៅនិងការងារការពារសន្តិសុខ ពេលចុះឃោសនាបោះឆ្នោត ក៏ដូចជាការពារនៅពេលបោះឆ្នោត នៅតាមមណ្ឌលមួយចំនួននោះគឺថាធ្វើយ៉ាងណាអោយបណ្តាលអស់លោកទាំងអស់ គឺថាសហការជាមួយកំលាំងសមត្ថកិច្ចនោះងាយស្រួលយើងនឹងបែងចែកកំលាំងហ្នឹងអោយបានល្អ ការពារអោយបានល្អកុំអោយមានអំពើរផ្សេងៗកើតឡើងដែលធ្វើអោយយើងមានការលំបាកក្នុង អោយគជបយើងធ្វើការដោះស្រាយ ហើយទន្ទឹមនឹងនេះទៀតខ្ញុំក៏លើកឡើងដែរអំពីបញ្ហាមួយចំនួន ដូចជាតាមខ្ញុំពិនិត្យឃើញថាដូចជាការសរសេរឈ្មោះបោះឆ្នោត ការផ្លាស់ប្តូរទីតាំងបោះឆ្នោត អញ្ចឹងយើងធ្វើទៅគឺថាបងប្អូនប្រជាពលរដ្ឋដែលគាត់មកបោះ និងមានលំបាកមើលឈ្មោះ ហើយនិងការផ្លាស់ប្តូរកន្លែងមួយ ទៅកន្លែងមួយហ្នឹង វាមានការចល័តលឿនពេក ដល់អញ្ចឹងគាត់ពិបាកក្នុងការបោះឆ្នោត ហើយមួយចំនួនតូចទេដែលមិនបានចូល បោះឆ្នោតនោះដោយសារតែមានការលំបាកអញ្ចឹង នេះខ្ញុំក៏សូមលើកនៅក្នុងអង្គប្រជុំរបស់យើងដែរ។ ហើយដូចជាមិនមានការអីវែង ឆ្ងាយទេដោយសារថាពេលវេលាយើងមានកំណត់ដែរ អញ្ចឹងខ្ញុំក៏សូមបញ្ចប់ហើយសូមអរគុណ។

២៣. លោក អួន សំអាន ( និស្សិត សកលវិទ្យាល័យបៀលប្រាយ សាខាខេត្តរតនៈគីរី)

ជាតំបូងនេះខ្ញុំសូមជំរាបសួរ អស់លោក លោកស្រីភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ដែលបានចូលរួមនៅក្នុងអង្គប្រជុំនេះ ហើយសូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ ។ ខ្ញុំមានសំនួរចង់សួរទៅលោកប្រធាន PEC ដែលលោកបាននិយាយថាជនជាតិវៀតណាមគាត់មានឯកសារគ្រប់គ្រាន់ក្នុងការបោះឆ្នោត ខ្ញុំចង់សួរថាតើជនជាតិវៀតណាមហ្នឹង តើត្រូវមានលក្ខខ័ណ្ឌអ្វីខ្លះដើម្បីបានចេញជាលិខិតស្នាមគ្រប់គ្រាន់ដើម្បីបានចុះឈ្មោះបោះឆ្នោត ? ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេ សូមអរគុណ

២៤. លោក ប៉ែន ឈុនឌី

សូមអរគុណ និងសំនួររបស់និស្សិតបៀលប្រាយ ដែលបានលើកឡើងសួរបញ្ជាក់អំពីបញ្ហានេះ ។ ពាក់ព័ន្ធទៅនិងការចុះឈ្មោះនិងគឺ ខ្ញុំបានជំរាបនៅក្នុងបទអន្តរាគមន៍របស់ខ្ញុំនិងគឺគជបបានធ្វើប្រតិភូកម្មអំណាចជូនដល់ក្រុមប្រឹក្សាឃុំសង្កាត់ ហើយក្រុមប្រឹក្សាឃុំសង្កាត់ស្មៀនឃុំហ្នឹងគាត់ជាអ្នកពិនិត្យឯកសារដ៏មានសារៈសំខាន់នេះ ថាតើគេមានឯកសារគ្រប់គ្រាន់ទេសម្រាប់ការចុះឈ្មោះនេះ បើអត់មានទេគឺយើងបដិសេធមិនអោយចុះឈ្មោះ បើគាត់ជាជនជាតិវៀតណាមគឺយើងមិនអោយគាត់ចុះឈ្មោះទេ ប៉ុន្តែក្នុងករណី

ដែលគាត់មានឈ្មោះទៅហើយ ក្នុងករណីដែលយើងធ្វើការគាត់មានឈ្មោះទៅហើយនោះជាទូទៅគឺយើងមិនអោយជនជាតិវៀតណាមមកចុះឈ្មោះបោះឆ្នោតទេ ក៏ប៉ុន្តែក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវតែពិនិត្យឯកសារអោយបានច្បាស់លាស់ស្មៀនឃុំសង្កាត់ នេះជាបន្ទុកការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលតោងតែពិនិត្យមើលឡើងវិញអោយច្បាស់លាស់បំផុតអំពីករណីនេះ ។ ក្នុងកំឡុងពេលចុះឈ្មោះបើសិនជាមានករណីអញ្ចឹង ហើយមានការប្តឹងផ្តល់ឡើងមកដល់លេខាធិការដ្ឋានរៀបចំការបោះឆ្នោត យើងនិងពិនិត្យមើលឡើងវិញតាមឯកសារ ជាក់ស្តែង។ ខ្ញុំសូមឆ្លើយបំភ្លឺជូនប៉ុននេះ សូមអរគុណ។

២៥. លោក ឌិកសេរីសោភក្តិ

នៅក្នុងបញ្ហាជនជាតិវៀតណាមនេះ តោងអោយយើងច្បាស់គ្រប់គ្នាដូចតទៅ ។ ខ្ញុំបាទជឿថាមានសញ្ចេតនាហើយនិងបញ្ហាពី អឌិតរវាងប្រជាជនខ្មែរហើយនិងប្រជាជនវៀតណាមនេះ ហើយជាពិសេសបញ្ហានេះក៏បានក្លាយទៅជាបញ្ហានយោបាយនៅពេលខ្លះ ជាពិសេសនៅពេលរដូវបោះឆ្នោតនេះឯង ក៏ប៉ុន្តែយើងតោងចែកអោយដាច់ថា មានជនជាតិវៀតណាមដែលមកនៅក្នុងស្រុកខ្មែរ មកនៅ មករកស៊ី ហើយទោះបីគាត់នៅមានលក្ខណៈស្របច្បាប់រឺមិនស្របច្បាប់យ៉ាងណានេះជារឿងមួយដាច់ដោយឡែក ហើយនិងនៅមិនទាន់ទាក់ទងទៅនិងរឿងបោះឆ្នោតទេ ក៏ប៉ុន្តែនៅពេលណាដែលជនជាតិវៀតណាមណាម្នាក់ ទោះបីគាត់និយាយខ្មែរច្បាស់ក៏ដោយ គាត់និយាយខ្មែរមិនច្បាស់ក៏ដោយ នៅពេលដែលគាត់មានឯកសារអត្តសញ្ញាណបញ្ជាក់ថាគាត់ជាជនជាតិខ្មែរ ហើយឯកសារហ្នឹងតែ កាលណាគាត់មានហើយគាត់បានសិទ្ធហើយជាជនជាតិខ្មែរគាត់ធ្វើអីក៏បានដែរ ទិញដីធ្លីក៏បាន រកស៊ីក៏បានបោះឆ្នោតក៏បានទោះបីគាត់ មិនចេះនិយាយខ្មែរក៏ដោយ ដូច្នេះយើងត្រូវតែតោងយល់អោយច្បាស់អត់អាចតវ៉ាបានទេ យើងតវ៉ាបាននិងមន្ត្រីដែលពាក់ព័ន្ធដែលទៅនិងការចេញប័ណ្ណអោយគាត់ នៅស្រុកខ្មែរយើងវាមានការ-----ដូចនៅភ្នំពេញមានជនជាតិចិនខ្លះអត់ចេះនិយាយខ្មែរមួយម៉ាត់ ប៉ុន្តែគាត់កាន់ប៉ាស្ព័រ ខ្មែរកាន់អត្តសញ្ញាណប័ណ្ណខ្មែរនិងយើងហៅអោយចំតែម្តងថារឿងពុករលួយតែម្តងអត់មានខុសទេ ប៉ុន្តែនេះមិនមែនជារឿងបោះឆ្នោតទេ តែកាលណាគាត់បានប័ណ្ណហើយទោះគាត់បានដោយរបៀបណាក៏ដោយប៉ុនប័ណ្ណជាតិរបស់យើងបានដល់ដៃរបស់គាត់ហើយគាត់ធ្វើអីក៏បានដែរ ទាំងពីរនេះសូមអោយយើងច្បាស់អញ្ចឹង ដូច្នេះនេះដូចជាការឆ្លើយដោយមិនចំពោះតែសំនួររបស់ក្មួយប្រុសដែលជានិស្សិតនៅសកលវិទ្យាល័យបៀលប្រាយនិងដែរ ដូច្នេះយើងធ្វើ ធ្វើមុនពេលដែលគាត់មិនទាន់បានប័ណ្ណនោះ តែកាលណាគាត់បានប័ណ្ណហើយគឺ គាត់មានសិទ្ធពេញទីដូចតែយើងទាំងអស់គ្នាដែរ។ សូមអញ្ជើញមេត្តាមានប្រសាសន៍បន្តទៅទៀត។

២៦. លោក ប៉ូយ ឡយ (មេឃុំ សោធំ)

ជាបឋមសូមគោពគណអធិបតេយ្យ និងសូមគោរពអស់លោក លោកស្រីទាំងអស់ និងសូមក្រាបថ្វាយបង្គំគ្រប់ព្រះអង្គ ។ ខ្ញុំមានសំនួរចង់សួរខាង NEC,PEC ការរៀបចំបោះឆ្នោត នៅពេលជិតរៀបចំការបោះឆ្នោត យើងពិនិត្យឈ្មោះថ្មី មើលឈ្មោះថ្មីយើងឧទាហរណ៍ឃុំសោធំខ្ញុំវា៧00នាក់អ្នកបោះឆ្នោតឈ្មោះចាស់ ដល់ពិនិត្យឈ្មោះថ្មីវាបាន២៣0 ដល់លើសគាត់ថាមិនបាច់ទេគេចុះចុះមកឈ្មោះថ្មីទៀតខ្លះគេមិនដឹងចុះ គាត់ថាបានហើយអត់ទេកំណត់គេត្រឹម៧៣0 បើលើសពីហ្នឹងគជបហើយនិង PEC,NEC គេអត់ទទួលគេថាអញ្ចឹង-------នេះទី១ ។ ហើយទី២ ទៀតពេលការរៀបចំទៅបោះឆ្នោត ដូចជាឃុំខ្ញុំពេលរដូវការបោះឆ្នោតឃើញថាNEC,PECគេរៀបចំហើយ រួចពីស្រុកចាត់រៀបដូចជាគណៈកម្មាធិការនៅក្នុងឃុំ ពេលរៀបចំទៅគ្មានទៅទំនាក់ទំនងជាមួយឃុំទេរៀបចំរួចជូនទៅ ដល់ឃុំអត់ចេះឃុំទៅជួបដូចជាគណៈកម្មាធិការរឺក៏NEC,PECនៅទីហ្នឹង គាត់ថាគ្មានទៅទំនាក់ទំនង ដល់ទំនាក់ទំនងទៅគាត់ថាជូនដំណឹងមុនអោយឃុំថ្ងៃប៉ុននេះអញ្ចឹងទៅ ហើយអោយឃុំចុះទៅរៀបចំប្រជាពលរដ្ឋហើយផ្សព្វផ្សាយ វាអត់មានស្រាប់តែដល់ពេលទៅ ខ្ញុំនិងហើយអ្នកទៅដល់កន្លែងគាត់ហ្នឹងNECអញ្ចឹងលោកមេឃុំអញ្ជេះ៧ខ្ញុំមក និងគឺជាវាធ្វើការវាគ្មាន

តម្លាភាពវាអត់បានទំនាក់ទំនង  អត់បានសហការណ៏ជាមួយមេឃុំនេះខ្ញុំឃើញពិតប្រាកដ  ខ្ញុំនៅគ្រប់គ្រងក្នុងឃុំ ។ខ្ញុំមានតែប៉ុណ្ណឹងទេ សូមអរគុណ

២៧. លោកស្រី តេង បុត្រទេព

ខ្ញុំសូមលើកមួយចំនុចតូចជូនទៅគជបខេត្ត ដែលខ្ញុំលើកពីបញ្ហាជនជាតិវៀតណាមបានបោះឆ្នោតនោះមិនមែនមានកំហុសឆ្គងពីក្រុមប្រឹក្សាឃុំ  ព្រោះកាលណោះមិនទាន់មានកើតក្រុមប្រឹក្សាទេ  ប័ណ្ណបោះឆ្នោតគាត់មាននោះមិនដឹងជាខាងណាចេញអោយទេ ក៏ប៉ុន្តែដើម្បីមានសុក្រឹត្យភាពនៅក្នុងការបោះឆ្នោតអាណត្តិក្រោយនេះ  គឺនាងខ្ញុំសូមសំនូមពរសំខាន់មួយទៅនរគលបាលស្ថិតិដែលចុះជូនប្រជាពលរដ្ឋនៅពេលខាងមុខសូមអោយចុះយុទ្ធនាការនៅតាមភូមិប្រជាពលរដ្ឋណា ដែលមានអត្រានុកូលដ្ឋានទើបចុះបញ្ជីនៅក្នុងអត្តសញ្ញាណប័ណ្ណបាន  ដើម្បីអោយមានសុក្រឹត្យភាពហើយកុំអោយមានកំហុសឆ្គងតទៅទៀត  ដូច្នេះវាអាចជួយជំរុញដល់ប្រជាពលរដ្ឋដែល  ធ្វេសប្រហែសក្នុងការចុះបញ្ជីអត្រានុកូដ្ឋានផង  បើគាត់ចង់បានអត្តសញ្ញាណប័ណ្ណខ្មែរ  គាត់និងរត់មកចុះអត្រានុកូលដ្ឋានទៅធ្វើអោយការចុះបញ្ជីនេះវាបានលឿនទាន់សភាពការ ។ អរគុណ

២៨. លោក ឱកសេរីសោភក្តិ៍

ចំនុចដែលបងស្រីទេព  មានប្រសាសន៍ខ្ញុំឯកភាពពេញទី  យើងឆ្លៀតយកយុទ្ធនាការនេះដើម្បីតឹរឹមអំពីអត្រានុកូដ្ឋានមកវិញហើយបានចេញពីនោះមកអត្តសញ្ញាណប័ណ្ណជាតិវិញ  ខ្ញុំឯកភាពពេញទីបើអាចធ្វើអញ្ចឹងបានជាការល្អណាស់អ្វីដែលភ្លេចភ្លាំងមិនបានធ្វើពីមុនមកគឺថាយើងតឹរឹមតំរង់វាតែម្តងហើយនិងឃុំអាចងាយស្រួលគ្រប់គ្រងចលនាប្រជាពលរដ្ឋនៅក្នុងឃុំនិមួយៗបានផង  ហើយខ្ញុំជឿថាក្រសួងមហាផ្ទៃដែលខ្ញុំធ្លាប់ជួបជាមួយនិងឯកឧត្តមឧប  ឯកឧត្តមរដ្ឋលេខាធិការនានា  ក៏ចង់ដូចនេះដែរដើម្បីអោយឃុំអាចគ្រប់គ្រងប្រជាពលរដ្ឋបានតាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋានហ្នឹងឯង សូមអរគុណណាស់បងស្រី សូមអញ្ជើញមានមតិតទៅទៀត ។

២៩. ព្រះសង្ឃ កែវ សុគន្ធា ( វត្តស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យរាជធានីភ្នំពេញ )

ជាបឋមអាត្មាភាពសូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ  និងសូមចំរើនពរដល់ឯកឧត្តម ។  អាត្មាភាពសូមសួរថាតើធ្វើយ៉ាងណាដើម្បីទាក់ទាញអោយប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោតអោយបានគ្រប់គ្នាតាមការអនុម័តរបស់គជប ព្រោះកន្លងមកដូចអ៊ី មេឃុំគាត់បានលើកច្រើនហើយថា ទោះបីទៅដល់មុខផ្ទះហើយក៏គាត់មិនទាំងមកផង គឺថាទៅបោះឆ្នោត--------ដោយក៏រិតព្រោះ  កន្លែងពាក្យនេះអាត្មាក៏ធ្លាប់លឺដែរ  ។  ហើយទី២  សូមសួរមួយទៀត  ហើយក៏ដូចជាសំនូមពរដល់គជបធ្វើយ៉ាងណាជួយសម្រួលដល់  ព្រះសង្ឃនៅក្នុងប្រទេសកម្ពុជាយើង  អោយបានទៅចុះឈ្មោះបោះឆ្នោតអោយបានគ្រប់អង្គផង  ព្រោះកន្លងមកអាត្មាបានទៅចុះឈ្មោះបោះឆ្នោតផងដែរ  កាលអាត្មានៅខេត្តនេះ  គឺទៅចុះឈ្មោះនៅសាលាបឋមសិក្សា----ចុះឈ្មោះបានប័ណ្ណទៅបោះឆ្នោត  ហើយរៀបទៅបោះឆ្នោតគេមិនអោយយើងទៅបោះឆ្នោត  នេះគឺជាបញ្ហាមួយ  ។  ព្រះសង្ឃក៏ជាប្រជាពលរដ្ឋមួយរូបដែរ  ប្រសិនណាជាព្រះសង្ឃមិនបាន ទៅបោះឆ្នោតបានន័យថាព្រះសង្ឃមិនមានសិទ្ធជាប្រជាពលរដ្ឋទេ នេះការដែលអាត្មាស្តាប់តាមវិទ្យុអាស៊ីសេរីកន្លងមក  បញ្ហានេះមួយ  អាត្មាក៏ចង់សំនូមពរផងដែរព្រោះដល់ពេលគេធ្វើប័ណ្ណបោះឆ្នោត សម្តេចព្រះសង្ឃរាជគាត់អោយចេញសេចក្តីប្រកាសមកអោយទៅធ្វើប័ណ្ណបោះឆ្នោតព្រោះព្រះសង្ឃក៏ដូចជាប្រជាពលរដ្ឋមួយរូបដែរ  ប៉ុន្តែដល់ពេលដល់ថ្ងៃទៅបោះឆ្នោត  ចេញសេចក្តីប្រកាសមួយទៀតមកថា  មិនអោយទៅបោះឆ្នោត  ប៉ុន្តែសំរាប់ព្រះសង្ឃនៅតាមខេត្ត  ប៉ុន្តែសំរាប់ព្រះសង្ឃនៅទីក្រុងភ្នំពេញវិញគេទៅបោះទោះបីជាមានការហាម  ឃាត់ពីមន្ត្រីសង្ឃក៏ដូចជាពីមេកុដិក៏ដោយក៏នៅតែទៅបោះនេះជាចំនុចមួយ ។ ហើយមានដល់សង្ឃខ្លះមានកាន់សមាជិកគណបក្សទៀត  មានអាត្មាសូមជំរាប  ចំនុចនេះហើយអាត្មាសូមសំនូមពរធ្វើយ៉ាងណាដើម្បីសម្រួលដល់ព្រះសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាយើងអោយបានចុះឈ្មោះបោះឆ្នោត  ព្រោះព្រះសង្ឃនៅប្រទេសកម្ពុជាច្រើន

ណាស់ សូម្បីតែវត្តអាត្មានៅសព្វថ្ងៃដល់ទៅ៣០០អង្គច្រើនណាស់ ប៉ុន្តែអង្គខ្លះដោយសារខ្លាចមេកុដិ ខាងគ្រូសូត្រធ្វេងស្តាំ ខាងសង្ឃដិការអីនិងមិនហានទៅបោះឆ្នោតទេ សូម្បីទៅធ្វើប័ណ្ណបោះឆ្នោត គេមិនហានទៅផង ប៉ុន្តែសំរាប់ព្រះសង្ឃខ្លះគេជំនះដើម្បីបំពេញតួនាទីជាប្រជាពលរដ្ឋមួយរូប ដើម្បីទៅបោះឆ្នោត អាត្មាសូមសំនូមពរ តែប៉ុណ្ណឹងសូមចំរើនពរ។

៣០. លោក ប៉ែន ឈុនឌី

ខ្ញុំបាទសូមបំភ្លឺជូនចំពោះព្រះសង្ឃដែលមានពុទ្ធដីការថា ធ្វើម៉េចដើម្បីអោយប្រជាពលរដ្ឋបានចូលរួមចុះឈ្មោះទាំងអស់គ្នា ? ជាទូទៅប្រជាពលរដ្ឋលោកមានកាត្តបកិច្ចក្នុងការមកចុះឈ្មោះបោះឆ្នោតដើម្បីមានសិទ្ធនៅក្នុងការបោះឆ្នោត ហើយកន្លងមកក៏យើងបានធ្វើការផ្សព្វផ្សាយតាមរយៈខិតប័ណ្ណ តាមរយៈមេក្រូ តាមរយៈមន្ត្រីរបស់យើងចុះសហការជាមួយក្រុមប្រឹក្សាឃុំក្នុងការអញ្ជើញប្រជាពលរដ្ឋដែលគ្រប់អាយុអោយមកបោះឆ្នោតបានគ្រប់ៗគ្នាគឺខាងលេខាធិការដ្ឋានយើងបានទៅទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំដើម្បី ប្រជុំជាមួយមេភូមិ ហើយអញ្ជើញប្រជាពលរដ្ឋដែលគ្រប់អាយុ១៨ឆ្នាំអោយគាត់មកចុះឈ្មោះបានគ្រប់ៗគ្នា ប៉ុន្តែក្នុងករណីដែលគាត់មិនបានអញ្ជើញមក យើងក៏គ្មានសិទ្ធអីទៅបង្ខំគាត់អោយមកត្រូវតែមក គឺយើងគ្មានសិទ្ធអីទៅបង្ខំគាត់ដែរ នេះសូមមានយោលបល់ពាក់ព័ន្ធទៅនិងបញ្ហានេះ ហើយសូមជំរាបផងដែរការបោះឆ្នោតបានគឺទាល់តែមានឈ្មោះក្នុងបញ្ជី មានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយ ត្រូវមានអត្តសញ្ញាណប័ណ្ណទៀតទើបយើងអាចបោះឆ្នោតបាន នេះសូមជំរាបខ្លីប៉ុននេះ សូមអរគុណ។

៣១. លោកឱុកសេរីសោភក្តិ

តាមមើលទៅមុននិងជូនសំដីទៅលោកអីហើយនិងបងខាងនោះ តាមមើលទៅបងប្រធានPECបងអត់មានប្រសាសន៏ព្រោះបងជាភ្នាក់ងារជាអ្នកដឹកនាំខេត្តរបស់គជប ដូច្នេះហើយបងមិនចង់មានប្រសាសន៏អំពីរឿងទាក់ទងនិងព្រះតេជគុណសួរ ប៉ុន្តែខ្ញុំករុណាអត់មានបញ្ហាទេអំពីរឿងហ្នឹង ខ្ញុំករុណាអាចមានទូលជំរាបជូនបាន។ មកទល់និងថ្ងៃនេះដាច់គុនទោះបីមានបញ្ហាណាក៏ដោយខ្ញុំករុណាអត់ដឹងលឺទេ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបរួមទាំងព្រះសង្ឃផងដែរនូវសិទ្ធនៃការបោះឆ្នោតព្រោះនេះជាសិទ្ធមូលដ្ឋានដែលយើងហៅថា[redacted]មកទល់និងពេលនេះអត់មានច្បាប់ណាមួយដែលនិយាយផ្ទុយអំពីលក្ខខ័ណ្ឌនិងទេ ក៏ប៉ុន្តែដែលមានបញ្ហានោះដោយសារតែមាននិន្នាការ គឺថាហាមឃាត់រឺមួយជំរុញព្រះសង្ឃមិនអោយទៅរឺអោយទៅបោះឆ្នោតតែប៉ុណ្ណឹងឯង ដូច្នេះបញ្ហាអស់នេះជាបញ្ហាផ្ទាល់ខ្លួនរបស់ព្រះសង្ឃមួយអង្គៗ ជាការសម្រេចចិត្តរបស់ព្រះសង្ឃមួយអង្គៗ មានកន្លែងខ្លះបើមិនទៅបោះមានបញ្ហា មានកន្លែងខ្លះទៀតបើទៅបោះមានបញ្ហា ដូច្នេះជាការសម្រេចចិត្តរបស់ព្រះសង្ឃមួយអង្គៗ ចំនែកសិទ្ធនៅក្នុងការបានទទួលអត្តសញ្ញាណប័ណ្ណ មានបានដូចប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ដូច្នេះសិទ្ធនៅក្នុងការចុះឈ្មោះមានដូចប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ដូច្នេះសិទ្ធទៅបោះឆ្នោតមានគ្រប់ ខ្ញុំករុណាអាចនិយាយបានរួចហើយអត់មានខុសនិងអ្វីដែលសម្តេចនាយកលោកមានប្រសាសន៏អត់មានខុសអ្វីដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រីលោកមានប្រសាសន៏អត់មានខុសនិងស្មារតីរដ្ឋធម្មនុញ្ញដាច់ខាត ។ រឿងក្រៅពីនិងជារឿងនយោបាយដែលខ្ញុំករុណា យល់ថានឹងមិនទាក់ទងនិងរឿងច្បាប់គោលនៃរដ្ឋធម្មនុញ្ញទេព្រះតេជគុណ ដូច្នេះហើយជាការសម្រេចចិត្តរបស់ព្រះសង្ឃមួយអង្គៗដែលត្រូវធ្វើ បើនិមន្តទៅសិទ្ធពេញទី មិននិមន្តទៅក៏សិទ្ធពេញទី នេះតែប៉ុណ្ណឹងឯង។ ខ្ញុំសូមជូនសំដីទៅបងប្រុសខាងណ្ណោះ បន្ទាប់មកបងប្រុសខាងនេះបាទ។

៣២. លោក សំ សុផាត

សូមគោរពអង្គប្រជុំជាលើកទី២ និងសូមថ្វាយបង្គំព្រះអង្គ ។ សូមឆ្លៀតយកចំនេញបន្តិចចុះ ព្រោះវាពាក់ព័ន្ធនិងការងារក្រុមប្រឹក្សាឃុំមិនមែនតែឃុំខ្ញុំទេទូទាំងឃុំនៅក្នុងព្រះរាជាណាចក្រកម្ពុជា សិទ្ធរបស់ព្រះសង្ឃលោកមានហើយគ្រាន់តែថា ដើម្បីមានទុនបោះឆ្នោត ហើយខ្ញុំមេឃុំនៅឃុំបាសៀកនិងមានវត្ត២ ហើយព្រះសង្ឃនិងលោកអត់មានសំបុត្រកំណើតហើយចាប់បង្ខំព្រះអង្គធ្វើ

បានតែប៉ុន្មានអង្គក្នុង២វត្ត------ដូច្នេះព្រះអង្គត្រូវគិតពិចារណាមុននិងឈានទៅបានធ្វើអត្តសញ្ញាណប័ណ្ណ ដូចលោកទីប្រឹក្សាលោកបានលើកឡើងហើយថាលោកស្រីទេពគាត់និយាយនិងក៏ត្រឹមត្រូវហើយ ហើយខ្ញុំក៏ចង់និយាយដែរកន្លងទៅត្រូវតែមានសំបុត្រកំណើតដើម្បីយកទៅបង្ហាញធ្វើកាត ហើយព្រះអង្គលោកកាន់កាតអីសព្វថ្ងៃ កាតឆៃយ៉ានោះបោះឆ្នោតបានទេទានព្រះអង្គ ? ដល់គេបង្កើតច្បាប់អត្តសញ្ញាណប័ណ្ណនិងវារៀងយ៉ាប់បន្តិចហើយ ប៉ុន្តែខ្ញុំមិនទាន់ដឹងទេ ប៉ុន្តែឥឡូវគ្រាន់តែសម្រួលអញ្ចឹងថាអោយព្រះអង្គនិមន្តទៅធ្វើសំបុត្រកំណើតបញ្ជីជាតិ ព្រោះថាបើកាលណាយើងអត់មានបញ្ជីជាតិអត់មានសំបុត្រកំណើតគេហៅថាមនុស្សអត់មានកំណើតមិនដឹងមនុស្សហ្នឹងកើតនៅឯណាស្រុកណាវាពិបាក អញ្ចឹងសូមព្រះអង្គនិមន្តទៅធ្វើអោយបានគ្រប់ព្រះអង្គ ហើយមួយទៀតចំពោះជនជាតិផ្សេងដែលខ្ញុំចង់និយាយ នៅឃុំរបស់ខ្ញុំអត់មានជនជាតិបរទេសណាទៅបោះឆ្នោតទេ ព្រោះថាវាមានរឿងមួយវាហាក់ដូចជាបិទសិទ្ធគេដែរ មិនមែនបិទសិទ្ធទេ បិទរបៀបម៉េច ? កាលណាគាត់យកសៀវភៅមកសូមចុះអត្រានុកូលដ្ឋានរឺធ្វើបញ្ជីជាតិពួកខ្ញុំត្រូវតែមើល មើលចេះតែទុក មិនធ្វើអោយគេសាកសួរអោយបានត្រឹមត្រូវ ព្រោះខ្ញុំមើលដូចជារៀងសង្ស័យអីអញ្ចឹងដល់យូរៗគេថាអត់បានទេហើយគេលែងមកធ្វើ ហើយធ្លាត់មួយពីរដែរពីមុនៗហើយអាណ្ណឹងនិងអត់មានមកធ្វើទេ តែកាលណាអត់មានបញ្ជីជាតិ យកទៅធ្វើអត្តសញ្ញាណប័ណ្ណអត់បានក៏វាអត់បានទៅបោះឆ្នោតដែរ រឿងហ្នឹងវាហុចតៗគ្នាអញ្ចឹង អញ្ចឹងអាណ្ណឹងជារឿងមួយដែរ អញ្ចឹងសូមអំពាវនាវឆ្លៀតឱកាសក្នុងការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សូមនិមន្តព្រះអង្គដែលមានទីស្នាក់អាស្រ័យនៅវត្តឥសានក៏ដោយសាមគ្គីរតនាក៏ដោយសូមនិមន្តទៅធ្វើអត្រានុកូលដ្ឋាន ទាន់ពួកខ្ញុំករុណាធ្វើ ប៉ុនសូមអោយច្បាស់លាស់ទានកុំធ្វើនៅកន្លែងនេះផងនៅកន្លែងនោះផង នេះទទួលខុសត្រូវលើព្រះអង្គខ្លួនឯងតេ គេអោយធ្វើតែមួយសន្លឹកៗទេពួកខ្ញុំនិយាយមែនទែនវានៅក្នុងក្រុមប្រឹក្សាឃុំខ្ញុំអ្នកដែលធ្វើនិង៣-៤គណបក្សនៅជុំគ្នាទាំងអស់ម្លោះហើយ នរណាមួយហានធ្វើផ្តេសផ្តាស់ អត់ហានទេអញ្ចឹងហើយការឆ្លងដើម្បី----វាមានក្រឹត្យវាមានអនុក្រឹត្យត្រឹមត្រូវ ប៉ុនដល់អញ្ចឹងពួកខ្ញុំ មើលមុខថាឯងហានីមួយថាឯងហានី ? នេះជារឿងមួយធ្វើអោយពួកនោះអត់ហានដែរ អញ្ចឹងភាពសុក្រឹត្យវាអោយទៅតាមហ្នឹង អញ្ចឹងអោយគេធ្វើម៉េចបើវាទៅតាមនិងហើយចេះតែទ្រាំៗទៅ ។ សូមអរព្រះគុណ

៣៣. លោក ឱកសេរីសោភក្តិ៍

ខ្ញុំឯកភាពពេញទី ជាមួយលោកអីដែលមានប្រសាសន៍អំបាញ់មិញនេះនៅក្នុងរឿងហ្នឹង ព្រោះបើសិនជាព្រះសង្ឃក៏ដូចជាប្រជាពលរដ្ឋធម្មតា ក៏ព្រះសង្ឃត្រូវតែមានសំបុត្រកំណើត បញ្ជីជាតិអីដូចតែប្រជាពលរដ្ឋធម្មតាដូចគ្នាអញ្ចឹង អត់មានបញ្ហាអីទេហើយបានជាខ្ញុំគាំទ្រសំដីរបស់បងស្រីទេព និងគឺដោយសារនឹកឃើញខ្លួនឯង ខ្ញុំបានអត្តសញ្ញាណប័ណ្ណជាតិនិងមុនសំបុត្រកំណើតមុនចុះអត្រានុកូលដ្ឋានប៉ូលីសគេទៅធ្វើអោយខ្ញុំដោយសារខ្ញុំនៅក្នុងក្រសួងធ្វើការក្នុងក្រសួងទៅម្លោះហើយគេមកចុះអោយមកថតរូបអីអោយ ហើយ បានខ្ញុំទៅឃុំដើម្បីអោយវាត្រូវទៅតាមច្បាប់នោះទៅអាជ្ញាធរឃុំ បង្ខំតែម្តងថាសូមអោយធ្វើសំបុត្រកំណើតអោយខ្ញុំដូច្នេះគឺខុសហើយបានជា អ្វីដែលលើកឡើងហ្នឹងត្រឹមត្រូវណាស់ យើងចេញពីហូវហែររបស់គេមក ចេញពីសំបុត្រកំណើតចេញពីបញ្ជីជាតិ ចេញពីស្មីហូវហែរ មកបានឈានមកដល់អត្តសញ្ញាណប័ណ្ណជាតិ ។ បាទសូមអញ្ជើញបងខាងនោះ

៣៤. លោក សាម សារឿន ( ក្រុមប្រឹក្សាឃុំ កាចាញ )

ខ្ញុំសូមបន្ថែមបន្តិចទេគឺថា អំបាញ់មិញមេឃុំឡាបាសៀក គាត់បាននិយាយហើយធ្វើអត្តសញ្ញាណប័ណ្ណ ធ្វើអត្រានុកូដ្ឋានហើយដល់មន្ត្រីនរគលបាល បើសិនអោយស្របតាមបញ្ជីកំណើតរឺក៏សំបុត្រអត្រានុកូលដ្ឋាននោះគឺវាល្អហើយ តែក្រែងលោគាត់ធ្វើផ្សេង គាត់អត់បានយកសំបុត្រនិងមកផ្ទៀងផ្ទាត់ ដើម្បីធ្វើអត្តសញ្ញាណប័ណ្ណអោយគេ និងជូនកាលជនជាតិបរទេសទៅគេកាន់តែប័ណ្ណគ្រួសារមួយទៅគេធ្វើបានដូចគ្នាហ្នឹង តែបើយកល្អធ្វើម៉េចសហការ ធៀបដល់ប្រជាជនអោយមានសំបុត្រកំណើត ហើយសូមចុះ

អត្តសញ្ញាណប័ណ្ណអោយ ដូច្នេះបានវាសុក្រិត្យ ហើយបើសិនជាកុំមានប័ណ្ណអត្រានុកូដ្ឋានហើយ យើងចេញអត្តសញ្ញាណប័ណ្ណអោយនឹងគេអាចបន្លំបាន ត្រង់កន្លែង ហ្នឹងអាចបន្លំបាន ហើយគ្រួសារវៀតណាមមួយចំនួនមានប័ណ្ណគ្រួសារ ហេតុនេះអត់យកតាមប័ណ្ណគ្រួសារទេធ្វើអត្តសញ្ញាណប័ណ្ណរឿងនេះអាចច្រឡំបាន តែបើសិនជាដូចមេឃុំឡាបាសៀកលើកឡើង ហើយ៣គណបក្សចុះអត្រានុកូលដ្ឋាន ជនជាតិបរទេសមិនអាចចុះ បានទេ បើសិនជាយើងធ្វើគោលការណ៍មួយ ដែលធ្វើតាមសំបុត្រកំណើតមិនអាចបន្លំបានទេទៅអនាគតពេលខាងមុខយើងអាចយក អត្តសញ្ញាណប័ណ្ណទៅបោះឆ្នោតបាន ហេតុនេះគួរអង្គភាពនគរបាលសហការធ្វើម៉េចជួយក្បៀសង្កត់ប្រជាជន ដែលមិនទាន់ធ្វើអត្រានុកូលដ្ឋាននិងអោយគាត់ធ្វើ ពេលដែលបើកយុទ្ធនាការចុះតាមភូមិធ្វើអត្តសញ្ញាណប័ណ្ណ ត្រូវទៀមទារសំបុត្រកំណើត ដែលជនដែលគ្រប់ អាយុ១៨ឆ្នាំឡើងទៅ ត្រូវទៀមទារសំបុត្រកំណើតដើម្បីអោយស្រប ជៀសវាងជនខិលខូច ដែលបន្លំចុះឈ្មោះដើម្បីបោះឆ្នោត ។ សូមបញ្ចប់តែប៉ុននេះ សូមអរគុណ ។

៣៥.លោក ឱកសេរីសោភក្តិ៍

សូមអរគុណបង ការដែលបងលើកឡើងនេះជាការសំខាន់ណាស់ហើយអ្វីៗដែលបានលើកឡើងទាំងប៉ុន្មានហ្នឹង គឺសិតតែចុះនៅក្នុងកំណត់ហេតុអត់មានកាត់ទេ ព្រោះឥទ្ធិពលយន្តការខប់សែលហើយនិងខប់សែលប្រ៉ុមនេះគឺ អ្វីដែលបងមានប្រសាសន៍នៅក្នុងមេក្រូទាំងប៉ុន្មានថតជាខ្សែអាត់ទាំងអស់ ហើយដល់ទៅលេខាធិការដ្ឋានយកទៅធ្វើអត់មានបាត់មួយមាត់ទេ គឺថាយើងចម្លងដូចច្បាប់ដើមយើងគ្រាន់តែកែអក្ខរាវិរុទ្ធកែវេយ្យាករណ៍ដែលជាភាសានិយាយអោយទៅជាភាសារសរសេរហើយផ្ញើរថ្វាយទៅព្រះមហាក្សត្រថ្មី ទាំងអតីតព្រះមហាក្សត្រ សម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា ហើយនិងសម្តេចនាយករដ្ឋមន្ត្រី ហើយនិងរដ្ឋមន្ត្រីទាំងអស់ហូរហែរទាំងអស់គ្នាបានមើល ដូច្នេះអ្វីដែលមានប្រសាសន៍ទាំងប៉ុន្មាននេះ ជាពិសេសទាក់ទងទៅនិងចំនុចមួយដែលថាទាល់តែយើងសម្រួលអោយត្រឹមត្រូវតាមច្បាប់នៅក្នុងក៏រិតអត្រានុកូលដ្ឋាន និយាយថាបញ្ជីជាតិសំបុត្រកំណើតអញ្ចឹង បានចេញជាអត្តសញ្ញាណប័ណ្ណជាតិបាន ចំនុចហ្នឹងគឺថាយើងនឹងធ្វើចលនានេះ ដើម្បីអោយក្លាយទៅជាស្វ័យប្រវត្តិបែបនិងតែម្តង ហើយការដែលយើងជជែកគ្នានិងហើយបានធ្វើអោយឪពុកម្តាយរបស់យើងដែលជារាជរដ្ឋាភិបាលនោះ លោកដឹងថាប្រជាពលរដ្ឋលោកចាប់អារម្មណ៍លោកមានមតិលោកមាន រលំបាកនៅថ្នាក់មូលដ្ឋានរបស់លោកអញ្ចេះអញ្ចុះ ដូច្នេះថ្នាក់លើជួនកាលមិនមែនសិតតែភ្នែកម្ចាស់នោះទេជួនកាលខ្ញុំជជែកជាមួយ និងឯកឧត្តមឧបនាយកនិងសព្វថ្ងៃក៏នៅតែបន្តជជែកជាមួយលោកដែរ មានការខ្លះឪពុកម្តាយរបស់យើងនៅថ្នាក់លើមើលមិនដឹងទេ មើលមិនឃើញទេមើលមិនបានជ្រៀបថាបញ្ហាពិបាករបស់យើងជីវិតប្រចាំថ្ងៃនៅមូលដ្ឋានមើលមិនឃើញទេទាល់តែយើងនិយាយ និយាយហើយបានឪពុកម្តាយរបស់យើងលោកមើលឃើញលោកកែប្រែទៅតាមហ្នឹង ផ្ទះក្នុងគ្រួសារមួយដូចគ្នាកូនច្រើនជួនកាលកូនខ្លះ លំបាកតែមិននិយាយចេញមកក៏ឪពុកម្តាយមិនបានដឹងទេ កូនណាដែលនិយាយច្រើនជាងឪពុកម្តាយដឹងច្រើនជាងរឿងនិងក៏ដូចគ្នាផងដែរ ដូច្នេះហើយបានជាយើងគិតថា យើងបញ្ចេះយន្តការខប់សែលនេះពីថ្នាក់ជាតិមកថ្នាក់ខេត្តថ្នាក់មូលដ្ឋាននេះជាការប្រសើរណាស់ ។ ខ្ញុំបាទសូមជំរាប សូមអនុញ្ញាត្ត ខ្ញុំព្រះករុណាខ្ញុំសូមទូលថ្វាយ សូមជំរាបសួរសាជាថ្មីម្តងទៀតមានមតិអ្វីផ្សេងលើសពីនេះទៀតទេ ?

៣៦.លោក សុខ ឋាម ( តំណាងគណបក្សប្រជាជន ខេត្តរតនៈគីរី )

ខ្ញុំបាទចង់និយាយអំពីការងារបោះឆ្នោត ក៏ប៉ុន្តែវាគ្មិនទាំងអស់ដែលបានឡើងធ្វើអត្ថាធិប្បាយនោះឃើញថាវាសក្តិសមទៅហើយ ក៏ប៉ុន្តែវានៅចំនុចខ្លះដែលយើងគួរតែចាប់អារម្មណ៍បន្ថែម ។ អ្វីដែលលោកវាគ្មិនខាងដើមបានលើកខ្ញុំមិនឡើកទេ ខ្ញុំចង់លើកថ្មីយើងដឹងហើយថាការងារបោះឆ្នោតរបស់កម្ពុជាយើងទើបតែទទួលបានពីឆ្នាំ១៩៩៣ទេ ក្រោមការជួយឧបត្ថមពីអង្គការសហប្រជាជាតិដែលយើងហៅថាអ៊ុមតាក់ អញ្ចឹងការបោះឆ្នោតនៅពេលនោះ អាយុឃើញថាវាជួបប្រទះនូវការលំបាកច្រើន ចំនុចទី១គឺការចុះឈ្មោះ

បោះឆ្នោតនិងតែម្តង ចំពោះប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅទាំង២ភេទគឺ មានសិទ្ធបោះឆ្នោតទាំងអស់ក៏ប៉ុន្តែការទៅចុះឈ្មោះបោះឆ្នោតនោះវាមិនបានគ្រប់ចំនួនទេ ហើយ៩៣យើងឃើញហើយថាវានៅមានសង្គ្រាមផងសន្តិភាពផង សូម្បីតែកងទ័ពនៃអង្គការសហប្រជាជាតិដែលជាកងទ័ពថែរក្សាសុវត្ថភាពនៅក្នុងការបោះឆ្នោតនោះក៏មិនអាចជួយបានដែរ កន្លែងខ្លះស្លាប់របួសបាត់ហឹបឆ្នោតធ្លាក់ទឹកគឺមានគ្រប់បែបយ៉ាងទាំងអស់ អញ្ចឹងខ្ញុំសូមជំរាបប៉ុណ្ណឹង។ ចំនុចទី២ ចូលមកដល់ឆ្នាំ១៩៩៨ ក៏យើងធ្វើការបោះឆ្នោតម្តងទៀតដោយខ្មែរខ្លួនឯងធ្វើ ហើយការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៨នោះ យើងឃើញថាប្រជាពលរដ្ឋកម្ពុជាទាំងអស់សស្រាក់សស្រាំណាស់ក្នុងការទៅចុះឈ្មោះបោះឆ្នោត ក៏ប៉ុន្តែហេតុអីបានជាចុះវាមិនអស់ ? មូលហេតុអី ? មូលហេតុមកពីការបោះឆ្នោតនៅពេលនោះនៅរដូវវស្សា ហើយការចុះឈ្មោះនៅពេលនោះក៏វាជួបប្រទះលំបាក ដូច្នេះយើងមិនអាចចុះឈ្មោះអោយប្រជាពលរដ្ឋបានគ្រប់ចំនួនទេនៅ៩៨។ ដល់ពេលយើងធ្វើការបោះឆ្នោតទៅ បានយើងឃើញថាយើងជួបការលំបាកដែលយើងលើកឡើងមកពេល នេះដែលយើងហៅថាភាពទំនាស់នៅពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ២០០៧-២០០៨ដែលជាបោះឆ្នោតជាតិនោះតើយើងធ្វើម៉េច ដើម្បីបង្ការកុំអោយមានទំនាស់ ? ភាពទំនាស់ទាំងឡាយកាលពីមុនមក៩៣-៩៨-២០០២-២០០៣គឺការទំនាស់កើតឡើងច្រើន តែពីគណបក្សរវាងគណបក្សទេ រឹងប្រជាពលរដ្ឋមិនសូវមានទេ ព្រោះថាសិទ្ធរបស់គាត់ ពេលគាត់ទៅចុះឈ្មោះបោះឆ្នោតគាត់ទំនេរគាត់ទៅ ចុះបានក្រោយពីការអប់រំការប្រកាសរបស់គណៈកម្មការបោះឆ្នោតគ្រប់មូលដ្ឋានហើយនិងអាជ្ញាធរដែនដីដែលបានជំរាបគាត់អោយគាត់ ទៅចុះឈ្មោះ ហើយដល់ពេលបោះឆ្នោតជំរាបគាត់ទៀតអោយគាត់ទៅបោះឆ្នោត គាត់មានពេលក្រៅពីទុក្ខធុរៈដ៏ធ្ងន់ធរដែលមិនបានទៅ គាត់មិនបានទៅមែនប៉ុន្តែចំពោះអ្នកដែលបានទៅគឺទៅបោះឆ្នោតដោយសម្ងាត់ ដោយសេរីយុត្តធមិនិងតម្លាភាពបំផុត នេះយើងឃើញ ថាប្រជាពលរដ្ឋខ្មែរស្រលាញ់ណាស់ការបោះឆ្នោត ស្រលាញ់ណាស់ការជ្រើសរើសថ្នាក់ដឹកនាំដោយផ្ទាល់ខ្លួនឯង អញ្ចឹងយើងឃើញថា ការទំនាស់នៅពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ២០០៧ខាងមុខនិងបោះឆ្នោតជាតិ២០០៨នោះបើជាយោបល់បុគ្គលខ្ញុំបាទផ្ទាល់ប្រហែលជាមិនសូវមានទំនាស់ទេ មូលហេតុអី ? ពិព្រោះគណបក្សធំទាំង៣ដែលមានអាសនៈនៅសភាគឺសិតតែជាគណបក្សដែលចាស់ទុំមាន ការយល់ដឹងច្រើនអំពីបញ្ហានយោបាយ អញ្ចឹងមានការធ្វើសម្បទានរវាងគ្នានិងគ្នាយើងឃើញថាសភាពការណ៏កម្ពុជាក៏ដូចជានៅលើសកលោកដែលរយៈពេលកន្លងមកនេះ ដែលគណបក្សទាំង៣មានការយល់ចិត្តគ្នាទៅវិញទៅមកបានច្រើន អញ្ចឹងយើងសង្ឃឹមថា ប្រហែលជាមិនសូវមានទំនាស់ទេ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ២០០៧និងបោះឆ្នោតជាតិ២០០៨នោះ ប៉ុន្តែយើងបារម្ភទៀតថា តើប្រជាពលរដ្ឋដែលទៅចុះឈ្មោះបោះឆ្នោតគ្រប់ទេ ? ហើយបើមិនគ្រប់មកពីមូលហេតុអី ? ហើយយើងមានវិធានការណ៏យ៉ាងម៉េច ដើម្បីអោយប្រជាពលរដ្ឋបានអញ្ជើញទៅបោះឆ្នោតអោយបានគ្រប់គ្រាន់ ? ចំនុចទីមួយគឺការិយាល័យចុះឈ្មោះបោះឆ្នោត ដែលគជបបានធ្វើ ប្រតិភូកម្មអំណាចជូនដល់ក្រុមប្រឹក្សាឃុំ ក្នុងការចុះឈ្មោះបោះឆ្នោត ហើយពេលនេះទៀតយើងទាំងអស់គ្នាបានលឺហើយថាមិនមាន ប័ណ្ណបោះឆ្នោតទៀតទេ គឺមានតែអត្តសញ្ញាណប័ណ្ណ ហើយមូលហេតុអោយមានអត្តសញ្ញាណប័ណ្ណ ធ្វើម៉េចដើម្បីមានអត្តសញ្ញាណប័ណ្ណ ដោយស្របច្បាប់ ? គឺអត្រានុកូដ្ឋានសំបុត្រកំណើតអត្រានុកូដ្ឋានមានដល់ទៅ៣ កើតស្លាប់ហើយនិងការប្តីប្រពន្ធ ដូច្នេះយើងគួរថានៅ ទីនេះក៏មានដែរក្រុមប្រឹក្សាឃុំដែលបានអញ្ជើញចូលរួមតំណាងគណបក្សអង្គការ NGO ផ្សេងៗដែលនៅក្នុងខេត្តហើយនិស្សិតហើយ និងព្រះសង្ឃដែលនិមន្តមកចូលរួម យើងឃើញថាមុននិងយើងធ្វើអត្តសញ្ញាណប័ណ្ណជាតិបាននោះ ទាល់តែយើងមានសំបុត្រកំណើត ត្រឹមត្រូវថាជាខ្មែរកើតនៅឯណាដូចអស់លោកដែលបានលើកកាលពីដើមហើយ ប៉ុន្តែចំនុចមួយទៀតចំពោះការធ្វើអត្តសញ្ញាណប័ណ្ណ ជាតិខ្មែរជាភារៈកិច្ចរបស់អ្នកណាជាអ្នកធ្វើគឺនរគលបាលមិនមែនមេឃុំជាអ្នកធ្វើអោយទេរឿងហ្នឹង អញ្ចឹងកន្លងមកយើងឃើញថា ប្រជាពលរដ្ឋនៅរតនៈគីរី ដោយឡែកខ្ញុំនិយាយថាឃុំឡាបាសៀកដែលមានអាយុ១៨ឆ្នាំហើយចង់ទៅធ្វើអត្តសញ្ញាណប័ណ្ណឥឡូវធ្វើអត់ បានទេមូលហេតុអីដែលទៅធ្វើមិន

បាន ? គេថាគេមិនទាន់បើយុទ្ធនាការ អញ្ចឹងយើងឃើញថាបើយើងមិនត្រៀមពីពេលនេះតទៅទេ ដល់ពេលការបោះឆ្នោតក្រុមប្រឹក្សាឃុំ២០០៧នៅតែមិនទាន់បានអស់ប្រជាពលរដ្ឋដែលគ្រប់អាយុ១៨ឆ្នាំ។ អញ្ចឹងសំនូមពរចំនុចមួយ ដល់លោកវិរៈសេនីទោដែលតំណាងអោយស្នងការដ្ឋាននរគលបាលខេត្តមេត្តាពិភាក្សាវីក៏ផ្លាស់ប្តូរយោលបល់យ៉ាងណានោះ បើសិនក្រសួងមហាផ្ទៃ រឺក៏អគ្គស្នងការនរគលបាលជាតិអនុញ្ញាត្តគួរតែយើងចាប់បន្តធ្វើអត្តសញ្ញាណប័ណ្ណជូនពលរដ្ឋដែលគ្រប់អាយុ១៨ឆ្នាំ ពេលណាក៏បានដែរអោយតែគ្រប់អាយុចូលទៅស្នងការដោយមានកាន់សំបុត្រកំណើតទៅធ្វើបាន នេះជាការល្អណាស់ជាការសំនូមពររបស់ខ្ញុំបាទ គ្រប់ភូមិទាំងអស់ពិព្រោះខេត្តរតនះគីរីមាន២៤០ភូមិហើយនិង៤៩ឃុំហើយប្រជាពលរដ្ឋមានអាយុគ្រប់បោះឆ្នោតដែលចុះឈ្មោះពិនិត្យបញ្ជីឈ្មោះនៅឆ្នាំ២០០៥យើងឃើញថាវាកើន កើនដល់ទៅពីរពាន់នាក់ជាង អញ្ចឹងបើយើងគ្មានអត្តសញ្ញាណប័ណ្ណជាតិទេ យើងថាមិនមានប័ណ្ណបោះឆ្នោតនោះ យើងថាយកអត្តសញ្ញាណប័ណ្ណទៅបោះឆ្នោតក៏បាននោះយើងត្រូវតែរប៉ស់ទៅធ្វើអត្តសញ្ញាណប័ណ្ណនេះអោយបានគ្រប់ប្រជាពលរដ្ឋ ដែលគ្រប់អាយុ១៨ឆ្នាំ ហើយខ្លះទៀតក៏មិនទាន់មានដែរ គឺទៅបោះឆ្នោតពីមុននោះយើងមានតែកាន់ប័ណ្ណបោះឆ្នោតរឺក៏អ្វីផ្សេងៗទៀត ហើយឧទាហរណ៍ជាក់ស្តែងដូចយើងបោះឆ្នោតព្រឹទ្ធសភារយៈពេលកន្លងមកប្រមាណខែកន្លងទៅនេះយើងឃើញថាគ្រាន់តែអ្នកដែលមានសិទ្ធបោះឆ្នោតព្រឹទ្ធសភា តំណាងរាស្ត្រដែលនៅក្នុងតំណែង សមាជិកក្រុមប្រឹក្សាឃុំចំនួនតែ២៥០នាក់ជាងនៅខេត្តរតនះគីរីក៏ជួបការលំបាកដែរ ជួបការលំបាកត្រង់ថាយកអីទៅបោះឆ្នោតព្រឹទ្ធសភា ? មុនដំបូងថាយកប័ណ្ណបោះឆ្នោតក្រោយមកថាយកស្លឹតេនោះហើយដោយគ្មានស្លឹជំនួសទំរង់១០-១៨ ដល់ក្រោយមកដល់ពេលបោះឆ្នោតយកតែប័ណ្ណសមាជិកក្រុមប្រឹក្សាឃុំទៅបោះតែប៉ុណ្ណោះហើយធ្វើដោយដុតដៃដុតជើងទំរាំតែបានគ្រប់២៥០ប្លាយនាក់ នេះជាការងារមួយដែលខ្ញុំបាទលើកឡើងថាអាចមានទំនាស់បញ្ហាហ្នឹង វាធ្វើអោយការយឺតយ៉ាវមិនគ្រប់ប្រជាពលរដ្ឋដែលមានអាយុគ្រប់បោះឆ្នោតហើយមិនបានទៅបោះឆ្នោតដែលធ្វើអោយមានការសោកស្តាយរបស់គាត់ គាត់ជាប្រជាពលរដ្ឋគ្មាមិនបានធ្វើកាត្តបកិច្ចជ្រើសរើសថ្នាក់ដឹកនាំកំពូលរបស់ខ្លួន រឺក៏ថ្នាក់ដឹកនាំនៅមូលដ្ឋានរបស់ខ្លួន ។ នេះខ្ញុំបាទមានយោបល់តែប៉ុណ្ណឹងទេ សូមអោយអង្គប្រជុំទាំងអស់ពិចារណា បើកន្លែងណាត្រូវយើងទុកជា បទពិសោធបើកន្លែងណាខុសទេយើងបោះចោលទៅ សូមអរគុណ។

៣១. លោក ឱកសេរីសោភក្តិ៍

ខ្ញុំបាទសូមថ្លែងនូវអំណរគុណចំពោះលោកប្រធានតំណាងខាងគណបក្សប្រជាជន គឺថាអ្វីដែលលោកមានប្រសាសន៏ហ្នឹងគឺត្រឹមត្រូវណាស់ ដូច្នេះហើយយើងគិតថាយុទ្ធនាការដើម្បីឈានទៅដល់អត្តសញ្ញាណប័ណ្ណជាតិគឺវាមានមានការទទួលខុសត្រូវគ្រប់គ្នាទាំងអស់។ យុទ្ធនាការនៅថ្នាក់ឃុំសង្កាត់អំពីបញ្ហាការចុះអត្រានុកូលដ្ឋានជាពិសេសសំបុត្រកំណើតបញ្ជីជាតិ យុទ្ធនាការខាងអាជ្ញាធរប៉ូលីសក្នុងការឈរនៅលើឯកសារនោះយុទ្ធនាការនៃការធ្វើអត្តសញ្ញាណប័ណ្ណជាតិ ក៏ប៉ុន្តែក្រសួងក៏ត្រូវផ្តល់មធ្យោបាយដើម្បីអោយប៉ូលីសនិងអាចធ្វើទៅបានដែលនិងត្រូវតែអញ្ចឹង នៅក្នុងពេលនេះផងដែរដោយសារអញ្ចឹងហើយបានជានៅពេលយន្តការខប់សែលធ្វើការជាមួយ UNDPយើងបានឆ្លុះបញ្ចាំងរឿងអាណ្តឹង គឺការខ្វះសម្ភារះនិងបានខាងUNDPនិងមានបំរុងទុកលុយមួយចំនួនសម្រាប់ជូនដល់ ទៅរាជរដ្ឋាភិបាលដើម្បីជួយធ្វើយុទ្ធនាការនៅក្នុងរឿងអត្តសញ្ញាណប័ណ្ណជាតិនោះសម្រាប់ឆ្នាំ២០០៦នេះតែម្តង។ នេះជាដំណឹងដែល ខ្ញុំបាទអាចនឹងជំរាបជូនបាន ដោយសារវាហួរហែរអញ្ចឹងបានជាយើងត្រូវត្រៀមគ្រប់លក្ខខ័ណ្ឌទាំងអស់នៅក្នុងរឿងនេះ ហើយអំពីបញ្ហាក្រុមប្រឹក្សាឃុំសង្កាត់ ដែលខ្លួនលោកផ្ទាល់អត់មានទាំងអត្តសញ្ញាណប័ណ្ណនោះផង និងខេត្តយើងនៅជួបបញ្ហាប៉ុណ្ណឹងឯខេត្ត ឯទៀតៗជួបបញ្ហាចម្រុងចម្រាស់សម្បើមណាស់ អំពីក្រុមប្រឹក្សាឃុំសង្កាត់និងដែលលោក ក្រសួងមហាផ្ទៃប្រកាសកាសកាលពី សុពលភាពកាលពី២០០២ហើយនោះដែលក្រោយមកគាត់ដូរឈ្មោះដូរអីទៅខុសពីឈ្មោះពេលប្រកាសខាងដើម ធ្វើឡើងវិញត្រឡប់ត្រឡិនបញ្ហាច្រើនណាស់ក្នុងរឿងនេះ ដូច្នេះឥឡូវនេះយើងជជែកគ្នាយើងដឹងលឺអស់ហើយថា ក្រុមប្រឹក្សាឃុំសង្កាត់ខ្លួនឯង

អញ្ជើញមានឈ្មោះណាហើយ គឺថាកុំអោយដូរទៀត ជាពិសេសកុំអោយខុស អំពីបញ្ជីឈ្មោះប្រកាសរបស់ក្រសួងមហាផ្ទៃនោះ ព្រោះនោះជាផ្លូវការហើយ មានត្រាមានអីច្បាស់លាស់ ដូច្នេះខ្ញុំបាទសូមអរគុណសារជាថ្មីទៀតបាទ ។

៣៨. ព្រះសង្ឃ ម៉ៅ វិច្ចិការ( ព្រះសង្ឃវត្តភូមិថ្មី ខេត្តរតនៈគីរី )

ជាបឋមខ្ញុំព្រះករុណា អាត្មាភាពសូមក្រាបថ្វាយបង្គំព្រះថេនានុថេរៈគ្រប់ព្រះអង្គ និងសូមចំរើនពរដល់អង្គគណធិតេយ្យទាំងអស់ជាពិសេសក៏សូមចំរើនពរដ៏លោកឱកសេរីសោភក្ដីដែលជាទីប្រឹក្សានិងជាអ្នកសម្របសម្រួលនៅក្នុងកិច្ចប្រជុំនេះ។ អាត្មាភាពឃើញថាគ្រប់ការសំដែងនូវមតិក៏ដូចជាការលើកឡើងស្ថាបនានូវជុំវិញនៅក្នុងការបោះឆ្នោត ឃើញថាគ្រប់មតិរបស់អស់លោកទាំងអស់ក៏ដូចជាព្រះអង្គបានសំដែងចេញមកសិតតែជាអ្នកចង់ស្វែងរកនូវអ្វីដែលជាការពិតជាសច្ចៈភាពជាសច្ចៈធមិអ្វីដែលជាការពិតធ្វើទៅតាមច្បាប់ប៉ុន្ដែដោយឡែកនៅពេលនេះ អាត្មាគ្រាន់តែថាចង់លើកឡើងអំពីបញ្ហាខ្លះៗដែលយើងមានការយល់ច្រឡំថា ព្រះសង្ឃព្រោះអីបញ្ហានេះគឺបញ្ហាព្រះសង្ឃនៅជុំវិញការបោះឆ្នោត ដែលថាព្រះសង្ឃគ្មានសិទ្ធនៅក្នុងការបោះឆ្នោតទេ នេះគ្រាន់តែជាមតិមួយចំនួនដែលថាពាក្យសំដីដែលគេនិយាយនៅខាងក្រៅ ដែលថាព្រះសង្ឃគ្មានការបោះឆ្នោតទេ ប៉ុន្ដែបើសិនជាតាមដែលអាត្មាធ្លាប់អានលេងៗនៅក្នុងវដ្ដធម្មនុញ្ញ គេបានចែងថាព្រះសង្ឃទាំង២ភេទ អាចមានសិទ្ធដើម្បីចូលរួមនៅក្នុងការបោះឆ្នោត ប៉ុន្ដែទាំង២ភេទនឹងអត់ទាន់ចេញមកថាជាព្រះសង្ឃរឺក៏ព្រះសក់ទេ ២ភេទអាចនិយាយថាបុរសរឺក៏ស្ដ្រី ប៉ុន្ដែព្រះសង្ឃដោយឡែកតែបើតាមទស្សនៈរបស់អាត្មាដែលបានសិក្សាថាចាំតិចតួច ប៉ុន្ដែមិនអោយឈ្មោះថាជាអ្នកចេះទេគ្រាន់តែជាអ្នកចាំតិចតួច ចាំនូវអ្វីដែលជាទ្រឹស្ដីរបស់វាមច្បង គឺថាព្រះសង្ឃអាចមានសិទ្ធចូលរួមនៅក្នុងការបោះឆ្នោត ប៉ុន្ដែបើយើងនិយាយអោយចំទៅតាមលក្ខណៈត្រឹមត្រូវគឺថាព្រះសង្ឃឈរនៅលើបេក្ខាឈរនៅលើធមិអព្យាក្រឹត្យមិនថាទៅកាន់នៅខាងណាខាងណាទេ ព្រោះជាទូទៅគេនិយាយថាតែកាលណាព្រះសង្ឃបោះឆ្នោត មានន័យថាព្រះសង្ឃអង្គហ្នឹងកាន់គណបក្សដែរហើយ ប៉ុន្ដែបើយើងយោងទៅលើថាបាវចនាជាតិក៏មានចែងថា ជាតិ សាសនា និង ព្រះមហាក្សត្រ បើយើងនិយាយពីរឿងជាតិ យើងថាព្រះសង្ឃមិនបាច់គិតគូរក៏ហីទៅ រឿងព្រះមហាក្សត្រអាណ្ហឹងជារឿងរបស់លោក ក៏ប៉ុន្ដែក្នុងនោះក៏មានចែងថាសាសនាមួយទៀត អញ្ចឹងនិងយោងទៅលើពាក្យស្លោកមួយផងដែលថា វប្បធមិរលត់ជាតិរលាយ សាសនាពណ្ណារាយទើបជាតិថ្កើនថ្កានបាន អញ្ចឹងការដែលថាជាតិនិងថ្កើនថ្កានទៅបានដោយសារសាសនានិងវាគង់នៅ និងដោយសារបរិសាទទាំងឡាយ៤ជំពូកមានការគោរពប្រតិបត្តិ អញ្ចឹងបានន័យថាព្រះសង្ឃរឿងជាតិនិងព្រះមហាក្សត្រលោកមានការគិតគូរហើយ ប៉ុន្ដែលោកមានការភ័យខ្លាចចំពោះការបាត់បង់នូវអ្វីដែលជាពុទ្ធោឱវាទរបស់ព្រះសមាសាមពុទ្ធ ដូច្នេះអាត្មាលើកឡើងថាព្រះសង្ឃ លោកក៏អាចមានសិទ្ធចូលរួមនៅក្នុងការបោះឆ្នោតបានដែរ ពិព្រោះលោកអាចធ្វើការការពារនូវសាសនារបស់លោកដែរ ពិព្រោះលោក បួសនៅក្នុងម្លប់សាសនា អញ្ចឹងដូចជាអស់លោកអញ្ចឹងដែរ ព្រោះថាយើងវិយយើងនិយាយទៅយើងមិនដឹងថាវាជាបញ្ហាស៊ីសំណូក សូកប៉ាន់ពុករលួយអីទេ អស់លោកទាំងអស់ដែលថាចូលកាន់គណបក្សរឺបោះឆ្នោតអោយបុគ្គលណាម្នាក់នោះ គឺសម្លឹងមើលឃើញថារឺ ប្រកាន់យកនូវទស្សនៈថា បុគ្គលនិងគឺជាមេដឹកនាំដ៏ល្អ បុគ្គលនិងគឺជាអ្នកប្រកបដោយគតិបណ្ឌិតនៅក្នុងការដឹកនាំណាស់ អញ្ចឹងយ៉ាងណាមិញព្រះសង្ឃក៏ដូចគ្នា ព្រះសង្ឃសម្លឹងមើលឃើញថាបុគ្គលនិងកាលណាដឹកនាំជាតិបានល្អ ក៏អាចធ្វើអោយសាសនារបស់ ព្រះអង្គបានរីកចំរើនបាន ព្រោះអាណ្ហឹងវាដូចគ្នាអត់មានចាត់ទុកវាថាជារឿងអគតិទេជារឿងលំអៀងអីទេ ហើយមិនមែនជាការថា ព្រះសង្ឃកាន់គណបក្សនោះក៏អត់។ អាត្មាសំដែងមកព្រឹកនេះក៏ថាដើម្បីរិះរកនូវអ្វីដែលជាការពិតមិនមែនជាការអគតិលំអៀងកាន់ គណបក្សទេ ប៉ុន្ដែនេះគឺថាជាការជួយសេបគប់ ព្រោះថានេះជារឿងសេបគប់មួយដែរអស់លោក ព្រះសំដែងថាបើសេបគប់ជាមួយ បុគ្គលខុសវាគឺខុស សេបគប់ជាមួយបុគ្គលសប្បុរសតែងតែនាំដើរផ្លូវល្អ ហើយ ហើយម្យ៉ាងទៀតអាត្មាយល់ថា កាលណាទាំងអាត្មាក្ដី ទាំងអស់លោកក្ដីទាំងព្រះសង្ឃក្ដីគឺសិតតែធ្វើទៅតាមលទ្ធិប្រជាធិតេយ្យ

និងបើនិយាយទៅតាមច្បាប់អាណាចក្រគឺថាអស់លោកមាន ការសិក្សាចេះដឹងជាងអាត្មាទៅទៀត ក៏ប៉ុន្តែបើអាត្មាថាចាំតិចតួចស្តួចស្តើងនូវអ្វីដែលជាខ្លឹមសាររបស់លទ្ធិប្រជាធិតេយ្យ គឺថា លទ្ធិប្រជាធិតេយ្យគឺជាលទ្ធិដែលយករាស្ត្រជាធំនិងជាម្ចាស់នៃអំណាចអញ្ចឹងក្នុងឋានៈរាស្ត្រជាម្ចាស់នៃអំណាចរាស្ត្រមានកាតួបកិច្ច ជ្រើសរើសបុគ្គលណាម្នាក់ដែលមានសមត្ថិភាព និងប្រកបដោយចំនេះវិជ្ជាខ្ពង់ខ្ពស់ក្នុងការដឹកនាំប្រទេសជាតិប្រកបដោយគតិបណ្ឌិត ដើម្បីស្វែងរកនូវសច្ចៈភាព សេរីភាព ហើយនិងវឌ្ឍនៈភាពភាពរតនៈភាព និងសមភាព និងសុភមង្គល ។ តាមពិតទៅគ្រាន់តែថា ទាំងអាត្មាក្តី ទាំងអស់លោកក្តីគឺថាធ្វើអ្វីគឺដើម្បីតែស្វែងរកនូវអ្វីដែលជាការពិតអ្វីដែលជាសេចក្តីល្អ អ្វីដែលជាសេចក្តីចម្រុងចម្រើន ដែលកើតមានឡើងគឺថាអោយវាមានការប្រព្រឹត្តទៅបានដោយសារអ្នកដឹកនាំ ។អញ្ចឹងទេអាត្មាចំរើនពរ សូមបញ្ចេញយោលបល់តែប៉ុននេះ

៣៩. ព្រះសង្ឃ ស្រីថេរ៉ា ( វត្តឥសានរតនារ៉ាម ខេត្តរតនៈគីរី )

ខ្ញុំករុណាសូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ និងសូមចំរើនពរដល់អង្គសិក្ខាសាលាទាំងអស់ ដល់លោកប្រធានទាំងអស់។ ខ្ញុំករុណាមានចម្ងល់បន្តិចបន្តួចដែលនឹងលើកមកជាបញ្ហា ហើយចង់បានចំឡើយនៅពេលនិងដែរមើលទៅនេះ។ ព្រោះថាបដិបថដែលយើងលើកមកក្នុថ្ងៃនេះគឺយើងនិយាយពីយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ហេតុដែលបង្ការទំនាស់និងវាមានច្រើនប៉ុន្តែអ្វីដែលអាត្មានឹងលើកយកមកក្នុងឱកាសនេះនិងវាមិនមែនជាលក្ខណៈទាំងស្រុងទេវាគ្រាន់តែជាផ្នែកតូចដែលអាចបង្ការមកនូវទំនាស់និងការយល់ច្រឡំរឺក៏ពាក្យសំដីបន្ទាប់ពីការបោះឆ្នោត ដូចជាថាជួនកាលទៅអាចមកពីរឿងប្រាក់បៀវត្សនៃមន្ត្រីដែលជាអ្នករៀបចំការបោះឆ្នោតរឺមកពីថាមន្ត្រីទាំងអស់ហ្នឹងត្រូវបានជ្រើសរើសដោយគ្មានការចំរាញ់រឺខ្វះសមត្ថិភាពដែលបណ្តាលអោយការងារនិងមិនប្រកបដោយប្រសិទ្ធភាពមិនបានប្រើប្រាស់នូវសមត្ថិភាពរបស់ខ្លួនអស់ទាំងស្រុងទេនេះភាគច្រើនគឺសំដៅទៅលើតំបន់ជនបទដាច់ពីខេត្តភាគច្រើនគឺយ៉ាងហ្នឹងមែន មិនបានប្រើប្រាស់សមត្ថិភាពរបស់ខ្លួនទេ មូលហេតុនឹងអាចបង្ករមកអោយបានទៅជាជំលោះ រឺអាក់សូដង់នៅក្នុងការរៀបចំការបោះឆ្នោតរឺចុះឈ្មោះបោះឆ្នោតហ្នឹង ប៉ុន្តែមិនមែនជាផ្នែកទាំងស្រុកទេគ្រាន់តែជាផ្នែកតូចមួយ ហើយយើងនិយាយពីព្រះសង្ឃដែលជាតួអង្គមួយអាចថាព្រះសង្ឃអាចជាបុគ្គលម្នាក់ រឺជាជនម្នាក់មិនសំដៅថាជា គ្រហស្ថរឺជាបុព្វជិតទេ គឺជាបុគ្គលជាតួអង្គម្នាក់នៅក្នុងសង្គមអញ្ចឹង ជាផ្នែកមួយនៅក្នុងសង្គមដែលចាំបាច់ត្រូវតែបញ្ចេញនូវមតិរបស់ខ្លួន រឺក៏មនសិការរបស់ខ្លួនរឺក៏បញ្ញារបស់ខ្លួន ដើម្បីជួយក្នុងសង្គមដូចគ្នា អញ្ចឹងព្រះសង្ឃក៏មានតួនាទីយើងមិនបាច់និយាយពីតួនាទីខាងបុព្វជិតទេ យើងនិយាយពីតួនាទីខាងគ្រហស្ថ ជាតួអង្គមួយដែលខាងសង្គមដែលចាំបាច់ត្រូវតែបញ្ចេញមតិ និងបញ្ចេញនូវបញ្ញារបស់ខ្លួន ដើម្បីជួយដល់សង្គមអញ្ចឹងទៅចុះ ហើយព្រះសង្ឃក៏ដូចជាអស់លោកអញ្ចឹងដែរ អាចទទួលបានគ្រប់បាតុភូតទាំងអស់ដែលកើតមកពីនយោបាយ រឺក៏សកម្មភាពនយោបាយ រឺក៏សកម្មភាពផ្សេងៗដែលកើតនៅក្នុងប្រទេសរបស់ខ្លួន។ អញ្ចឹងតើព្រះសង្ឃអាច បើចែងនៅក្នុងច្បាប់ថាព្រះសង្ឃមានសិទ្ធបោះឆ្នោត ត្រង់ថាលោកមិនបានប្រើប្រាស់នូវសិទ្ធរបស់ខ្លួន ដូច្នេះលោកទុកសិទ្ធរបស់ខ្លួនមួយផ្នែកក្រៅពីខ្លួន ដោយហេតុថាបើសិនជាលោកទៅបោះឆ្នោត លោកទៅជាលំអៀងហើយទៅជាអ្នកដែលកាន់គណបក្សហើយអញ្ចឹង អាត្មាក៏យល់ស្របដែលថាមិនបាច់ទៅបោះឆ្នោតទេ ប៉ុន្តែដាច់ខាតត្រូវតែមានសិទ្ធ គ្រាន់តែថាមិនបានប្រើប្រាស់នូវសិទ្ធរបស់ខ្លួនតែប៉ុណ្ណឹងទេ មិនបានលូកដៃចូលទៅក្នុងនយោបាយទេនៅជាកណ្តាលនៅជាឧបេក្ខាអញ្ចឹងទៅចុះ ប៉ុន្តែសូមសួរហើយក៏សូមលើកជាសំនួរថាតើព្រះសង្ឃនឹងអាចក្លាយខ្លួនទៅជាផ្នែកមួយនៃមន្ត្រីណាមួយរឺក៏ជាបុគ្គលិកមន្ត្រីរឺតាមថ្នាក់តំបន់ថ្នាក់ខេត្តអីមួយនៅក្នុងផ្នែកវេទិការរៀបចំការបោះឆ្នោតរឺក៏ការបោះឆ្នោតតែម្តង តើព្រះសង្ឃអាចក្លាយខ្លួន រឺក៏មានសិទ្ធក្នុងការបញ្ចេញមតិ រឺក៏យើងអាចថាត្រឹមជាអ្នកសង្កេតការជាដើម យើងឧបមាយ៉ាងនិងទៅចុះ ព្រោះថាព្រះសង្ឃមិនបាច់ចាំទៀមទារនូវប្រាក់បៀវត្សទេហើយព្រះសង្ឃមិនបានលូកដៃទៅក្នុងនយោបាយគឺព្រះអង្គបរិសុទ្ធអញ្ចឹង ដាច់ខាតគឺមិនលំអៀង ហើយនៅជាអធ្យាក្រឹត្យ ដូច្នេះព្រះសង្ឃអាចធានាបាននូវសមភាពច្បាស់លាស់ប្រកដជាធានាបាននូវ

សមភាពនូវតម្លាភាពនៅក្នុងការរៀបចំការបោះឆ្នោតរឺក៏ការបោះឆ្នោតនិងតែម្តង។ អាត្មាគ្រាន់តែចង់សួរថា តើលោកអាចមានសិទ្ធក្លាយខ្លួនទៅជាផ្នែកណាមួយនៃមន្ត្រីនៃការងាររៀបចំការបោះឆ្នោតនោះបានរឺអត់ ? ព្រោះថាលោកក៏ជាអ្នកទទួលរងនូវបាតុភូតពីនយោបាយដូចគ្នា។ នេះជាសំនួរនិងជាបញ្ហាដែលត្រូវលើកយកនិងចង់បាននូវចំឡើយនៅក្នុងពេលហ្នឹងដែរ។ ហើយរឿងមួយទៀតសូមបិតរង្វង់ក្រចកបន្តិចចុះ សូមលើកពីរឿងដែលថា Gender និងនៅក្រៅរង្វង់ក្រចកទេ ប៉ុន្តែថាអញ្ចេះមិនបដិសេធទេ យើងដឹងហើយថានៅក្នុងសង្គមយើងតែងតែមានផ្នត់គំនិតមួយថា ស្ត្រីមានតួនាទីសំខាន់នៅក្នុងសង្គមដែរ ប៉ុន្តែសំខាន់បំផុតគឺនៅក្នុងក្រុមគ្រួសារ អញ្ចឹងយើងចង់អោយស្ត្រីនឹង ទាញចេញពីក្នុងផ្នត់គំនិតទាំងអស់នោះថា តើមូលហេតុដែលស្ត្រីមិនអាចចេញមកក្រៅរង្វង់គ្រួសារបាននោះមូលហេតុអ្វី ? មូលហេតុសំខាន់បើយើងនិយាយដោយស្រាលទៅគឺមកពីស្វាមីមកពីគ្រួសារ អញ្ចឹងហើយតើយើងត្រូវធ្វើម៉េចដើម្បីអោយស្ត្រីនឹងអាចរួចចេញពីផ្នត់គំនិតទាំងអស់នោះបាន ហើយបើតាមការដែលអាត្មាសិក្សាមកអាចបញ្ជាក់បានត្រង់ថាអញ្ចេះនៅក្នុងការិយាល័យមួយចាំបាច់ត្រូវមាន ស្ត្រីនិងបុរសស្មើភាពគ្នាយើងថាសមធម៌ ប៉ុន្តែបើតាមអាត្មាយល់ពាក្យថាសមធម៌និងគឺវាអញ្ចឹងមែនហើយ ប៉ុន្តែអ្វីដែលគេថាសមធម៌ នៅក្នុងរង្វង់ការងារនោះប្រហែលសំដៅទៅលើDisrectសំដៅទៅលើសញ្ញាប័ត្រច្រើនជាងមើលទៅមិនមែននិយាយអញ្ចឹង អាត្មានិយម រឺក៏ថានិយមលើប្រុសៗអីទេគ្រាន់តែថាស្ត្រីសំខាន់ ប៉ុន្តែពាក្យដែលថាសំខាន់នៅក្នុងរង្វង់ការងារនោះ គឺសំខាន់គេទ្បើមទារ ទៅលើសញ្ញាប័ត្រដែរ ឧនមាថា១០០នាក់បុរសមានសញ្ញាប័ត្រ៧០នាក់ហើយស្ត្រីមានតែ៣០នាក់ទេ អញ្ចឹងនៅក្នុងប្រទេសដែល គេជឿនលឿនដូចជាសហរដ្ឋក្នុងការិយាល័យគេមានមនុស្ស៥នាក់ កាលណាមានមនុស្ស៥នាក់ត្រូវយកស្បែកសពនាក់ស្បែកខ្មៅ២នាក់ ហើយស្ត្រី២នាក់បុរស៣នាក់អញ្ចឹងទៅ និងគេបញ្ជាក់ថាមានសមភាពនិងតម្លាភាពដូចគ្នា ប៉ុន្តែគេមិនមែនបញ្ជាក់ថាអោយប្រុសនោះ ស្មើនិងស្រី រឺស្រីនោះស្មើនិងប្រុសទេ គឺសំខាន់ទៅលើការTotal ទៅលើសញ្ញាប័ត្រផងដែរ មានតែប៉ុណ្ណឹងទេដែលនៅក្រៅរង្វង់ក្រចក ប៉ុន្តែសូមបញ្ចប់តែសូមអោយអង្គប្រជុំនិងជួយផ្តល់នូវចំឡើយគឺថាតើព្រះសង្ឃនិងមានសិទ្ធ ឈរជាតំណាងណាមួយរឺក៏ជាផ្នែកណាមួយនៅ ក្នុងមន្ត្រីនៃការរៀបចំការបោះឆ្នោតបានដែររឺអត់?

៤០. លោក ឱកសេរីសោភក្តិ

ខ្ញុំករុណាអរព្រះគុណ ដូច្នេះខ្ញុំករុណាសូមប្រគល់ប្រសាសន៍ទៅបងប្រធានPEC នៅខេត្តរតនៈគីរីយើងនេះ លោកមានមតិសរុបតែម្តងហើយនិងឆ្លើយទៅសំណួរខ្លះៗដែលមិនទាន់បានឆ្លើយ បន្ទាប់មកខ្ញុំបាទនិងជំរាបជូនជាសង្ខេបជាសរុបនូវបញ្ហាមួយចំនួនដែលយើងបានដឹងបានលឺហើយនិងបានលើកឡើងពីព្រឹកមិញនេះ។ សូមអញ្ជើញ

៤១.លោក ប៉ែន ឈុនឌី

សូមអរគុណ ខ្ញុំករុណាសូមទូលថ្វាយ និងសូមជំរាបជូនអង្គប្រជុំអោយបានជ្រាបនៅក្នុងថ្ងៃនេះ ពាក់ព័ន្ធទៅនិងសំនួររបស់ព្រះសង្ឃដែលមានពុទ្ធដីការសួរថា ព្រះសង្ឃអាចជាផ្នែកមួយជាមន្ត្រីបោះឆ្នោតដែររឺទេ ? ខ្ញុំសូមឆ្លើយបញ្ជាក់ជូនថា មិនអាចទេព្រោះច្បាប់បានកំណត់មុននិងយើងធ្វើការមុននិងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសរើសនិងគឺមានពតិមានស្តីអំពីការជ្រើសរើសស្តីអំពីលក្ខណៈសម្បត្តិ គឺព្រះសង្ឃមិនអាចចូលជាផ្នែកណាមួយនៃមន្ត្រីបោះឆ្នោតបានទេ សូមទូលជំរាបជូន។ ពាក់ព័ន្ធនិងកិច្ចប្រជុំដ៏មានសារៈសំខាន់នៅក្នុងថ្ងៃនេះ ខ្ញុំសូមចាប់អារម្មណ៏ដោយខ្លីមុននិងឈានចូលទៅការបញ្ចប់នៃកម្មវិធី ពាក់ព័ន្ធទៅនិងការងារពិនិត្យបញ្ជីឈ្មោះហើយនិងចុះឈ្មោះបោះឆ្នោតកន្លងទៅលេខាធិការដ្ឋានតែម្នាក់ឯងមិនអាចធ្វើអ្វីបានទេ គឺមានតែការសហការណ៏គ្នាគ្រប់លំដាប់ថ្នាក់នៅក្នុងរង្វង់អាជ្ញាធរដែនដី អង្គការសង្គមស៊ីវិលដែលយើងអាចសម្រេចបានលទ្ធផលល្អដូចការបោះឆ្នោតព្រឹទ្ធសភាកន្លងមកហើយនិងការរៀបចំបញ្ជីឈ្មោះកន្លងមក ក៏យើងធ្វើការដោយរលូនមិនមានពាក្យបណ្តឹងអ្វី ដែលធ្វើអោយយើងកត់សម្គាល់រឺក៏មានបញ្ហា ស្មុគ្រស្មាញអ្វីមួយដែលយើងមិនអាចដោះស្រាយបាននោះទេ ហើយលទ្ធផលប្រកបដោយផ្លែផ្កានេះគឺខ្ញុំសូមសំដែងនូវការកោត

សរសើរជាពិសេសសម្រាប់ក្រុមប្រឹក្សាឃុំសង្កាត់ដែលបានប្តាជ្ញាចិត្តយ៉ាងមុះមុតនៅក្នុងការងាររបស់ខ្លួនទោះបីយើងមានប្រាក់កំរៃបន្តិចបន្តួចឧបត្ថម្ភក៏ដោយ ក៏ប៉ុន្តែខ្ញុំសង្កេតឃើញជាទូទៅគឺមានការប្តាជ្ញាចិត្តនៅក្នុងការធ្វើការងារដល់មានសារៈសំខាន់នេះ។ ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណ អង្គប្រជុំ គណៈធិតេយ្យ អស់លោកលោកស្រី ដែលចូលរួមប្រជុំនៅក្នុងថ្ងៃនេះសូមជួបនូវពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈពាលៈ និងបដិភាណៈកុំប្បីឃ្លាតឃ្លាឡើយសូមអរគុណ។

៤២. លោក ឱកសេរីសោភក្តិ

ខ្ញុំព្រះករុណាខ្ញុំបាទសូមថ្លែង មិនគ្រាន់តែអំណរគុណទេ គឺសេចក្តីរំភើបដល់ជ្រាលជ្រៅបំផុតចំពោះអង្គប្រជុំដែលបានមានមតិយ៉ាងសស្រាក់សស្រាំមួយព្រឹកនេះ ច្រើនបញ្ហាណាស់ដែលខ្ញុំបាទបានស្រង់ត្រឡប់មក។ ទី១យើងបានស្តាប់នូវប្រសាន៏របស់លោក ឡារីស្រ្តេន្ទ ដែលជំរាបជូនអង្គប្រជុំអំពីកិច្ចការរបស់វិទ្យាស្ថានCDRIហើយជាពិសេសទាក់ទងទៅនិងបញ្ហាការកសាងសន្តិភាពដែលកម្មវិធីខប់សែលនេះជាកម្មវិធីស្នូល។ ទី២ យើងបានស្តាប់អ្វីដែលខ្ញុំបាទបានជំរាបជូននូវប្រវត្តិដើមនិងមូលដ្ឋាននៃការបង្កើតឡើងនូវយន្តការខប់សែលដំណាក់កាលទី១ និងខប់សែលដំណាក់កាលទី២ដែលនឹងមានសកម្មភាពបន្តរហូតទៅដល់បញ្ចប់ការបោះឆ្នោតនៅឆ្នាំ២០០៨ការបោះឆ្នោតថ្នាក់ជាតិរបស់យើង។ ទី៣ យើងបានទទួលស្តាប់នូវរបាយការណ៏របស់លោកប៉ែនឈុនឌី ដែលជាប្រធានPEC នៅខេត្តរតនៈគីរីស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឆ្នាំ២០០៥កន្លងមកនេះ ហើយនិងដំណើរការរៀបចំការបោះឆ្នោតព្រឹទ្ធសភានៅខែមករាឆ្នាំ២០០៦យើងនេះ។ ទី៤ យើងបានទទួលស្គាល់លក្ខណៈពិសេសរបស់ខេត្តរតនៈគីរីនេះដែលមានប្រជាពលរដ្ឋសិងតែ៩០%ជាជនជាតិដែលយើងហៅថាជនជាតិភាគតិច តែខ្ញុំបាទយល់ស្របជាមួយលោកអ៊ីដែលមានប្រសាសន៏គឺថាតែ៩០%លែងជនជាតិភាគតិចហើយ គឺជនជាតិភាគច្រើនហើយវិញម្តងហើយ ខ្ញុំបាទទៅដែលជាអ្នកជនជាតិភាគតិចមកទីកន្លែងនេះ។ ដូច្នេះហើយគឺថា៩០%និងមានទំនៀមទំលាប់មានបញ្ហាច្រើនតាំងពីរឿងកែអាយុដើម្បីតំរូវទៅនឹងស្ថានការសង្គមស្ថានការជាក់ស្តែង បញ្ហាសំបុត្រកំណើត បញ្ហាផ្តត់គំនិតដែលធ្លាប់មានមក បញ្ហាអស់ទាំងនេះ គឺនៅមានច្រើនដែលធ្វើអោយឃុំសង្កាត់មានការលំបាកនៅក្នុងការបំពេញកិច្ចការរបស់ខ្លួន ហើយនេះក៏ឈានចូលទៅក្នុងបញ្ហាទី៥ ដែលទាក់ទងទៅនិងការចុះឈ្មោះបោះឆ្នោត ដោយសារបញ្ហាលំបាកអស់ទាំងនេះហើយបានជា មានការស្នើរសូមអោយបន្ថែមនូវចំនួនថ្ងៃអោយលើសពី២០ថ្ងៃ នៅខែតុលានិងដើម្បីអោយឃុំសង្កាត់និងឃុំមានការចុះឈ្មោះអោយបានច្រើន ប៉ុន្តែបើតាមយើងមើលទៅប្រហែលជាមានការពិបាកនៅក្នុងចំនុចនេះ ដោយសារកំណត់ប្រតិទិននេះបានធ្វើមកអញ្ចឹងទៅហើយ ក៏ប៉ុន្តែខ្ញុំបានគិតថាក្រោយពីពេលយើងជំនុំគ្នានេះទៅ យើងគួរធ្វើយ៉ាងណាដើម្បីធ្វើសហប្រតិបត្តិការគ្នា ប្រើប្រាស់ពេលវេលាដែលនៅសល់សំរាប់ការចុះឈ្មោះត្រៀមនេះអោយបានពេញទំហឹងតែម្តងជាពិសេសការធ្វើយ៉ាងណាអោយឃុំសង្កាត់និងប្រជាពលរដ្ឋនិងអោយបានយល់ យើងតោងធ្វើយុទ្ធនាការជាមួយនិងគាត់។ ទី៦ បញ្ហាទាក់ទងទៅនិងអត្តសញ្ញាណប័ណ្ណជាតិ នេះក៏ទាក់ទងទៅនិងចំនុចទី៤ដែរ ដែល៩០%ជាជនជាតិនោះដែលលោកមានការរស់នៅរបស់លោកធ្វើយ៉ាងណាដើម្បីសម្រួលនៅក្នុងការងារនេះ តាំងពីការចុះអត្រានុកូលដ្ឋាន ធ្វើសំបុត្រកំណើត បានឈានទៅដល់ការធ្វើអត្តសញ្ញាណប័ណ្ណជាតិជាដើម។ បញ្ហានេះក៏មានលើកពីជនជាតិវៀតណាមដែលបានធ្វើអត្តសញ្ញាណប័ណ្ណជាតិផងដែរ។ ទី៧ បញ្ហាស្រ្តីនិងបញ្ហាGenderជាមួយគ្នា ដែលជាមេឃុំយើងបានទទួលស្គាល់ថា ដើម្បីអោយស្ត្រីមានតួនាទីនៅក្នុងសហគមន៏ នៅក្នុងសង្គមនិងនៅក្នុងនយោបាយមូលដ្ឋានរបស់យើងការបង្កើនលើកស្ទួយនូវវិស័យអប់រំដល់ស្ត្រីជាពិសេសផ្តល់នូវអាហារូករណ៏ដល់ស្ត្រីដែលមានដើមកំណើតជាជនជាតិភាគតិចនោះអោយបានរៀនអោយបានខ្ពង់ខ្ពស់បំផុតនោះជាការសំខាន់ណាស់។ ហើយនៅក្នុងនេះផងដែរ ខ្ញុំបាទសូមជំរាបជូនជាដំណឹងដែលល្អខ្ញុំបាទបាន ធ្វើជាទីប្រឹក្សាអោយអង្គការUNDP នៅក្នុងរឿងជនជាតិដើមភាគតិច នៅក្នុងនេះគឺថាបានធ្វើសហប្រតិបត្តិការជាមួយUNDPតំបន់ប្រចាំទីក្រុងបាងកកមានគម្រោងការធំណាស់និងមានថវិការធំដើម្បីនិងផ្តល់នូវអាហារូបករណ៏

ដល់ជនជាតិដើមភាគតិច ជាពិសេសស្ត្រីដែលបានទៅរៀនដល់សកលវិទ្យាល័យនៅភ្នំពេញ ហើយអាចនឹងអញ្ជើញចេញទៅរៀននៅប្រទេសក្រៅទៀតយើងកំពុងតែរៀបចំបញ្ហានេះ ដូច្នេះហើយសូមជំរាបអង្គប្រជុំថា អ្វីដែលបានលើកឡើងពីព្រឹក គឺនៅកន្លែងផ្សេងនៅអង្គការសហប្រជាជាតិក៏បានទទួលស្គាល់នូវបញ្ហានេះថាជាបញ្ហាសំខាន់ផងដែរ។ ចំនុចទី៨ គឺសូមអោយមានតម្លាភាពពីការជ្រើសរើសបុគ្គលិកតាំងពីថ្នាក់PEC,SECនិងរហូត ដល់PSOជាដើម។ ទី៩ គឺសូមអោយPECនៅខេត្តរតនៈគីរី ធ្វើយ៉ាងណាយកចិត្តទុកដាក់អោយបានខ្ពស់ជាងនេះ ទៅតាមច្បាប់ទំលាប់និងទៅ តាមនីតិវិធីនៅក្នុងការដោះស្រាយពាក្យបណ្តឹងនានារបស់គណបក្សបានលើកឡើងនៅក្នុងបញ្ហាបោះឆ្នោតនេះ។ ទី១០ សូមថ្លែងនូវ អំណរគុណ ក្នុងការផ្តល់នូវប្រតិភូកម្មអំណាចដោយPECទៅដល់ក្រុមប្រឹក្សាឃុំសង្កាត់ក៏ប៉ុន្តែក្នុងនេះផងដែរក៏មានសំណើរសូមអោយមាន ការលើកតំកើនសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់ហើយនិងស្មៀននិងការផ្តល់នូវថវិការនិងឧបករណ៍អោយបានគ្រប់គ្រាន់ដើម្បីអោយក្រុមប្រឹក្សាឃុំសង្កាត់ហើយនិងស្មៀនឃុំសង្កាត់ធ្វើការបានត្រឹមត្រូវច្បាស់លាស់ជាពិសេសទាក់ទងទៅនិងបញ្ហាចុះឈ្មោះបោះឆ្នោត។ ទី១១ បញ្ហាចូលរួមធ្វើសហប្រតិបត្តិការជាមួយគ្នាដើម្បីផ្សព្វផ្សាយនូវដំណឹងពតិមាននានាហើយនិងធ្វើការអប់រំដល់ប្រជាពលរដ្ឋជាពិសេសនៅតំបន់ដាច់ស្រយាលដូចជាខេត្តរតនៈគីរីនេះដើម្បីអោយគាត់បានជ្រួតជ្រាបអោយគាត់ដឹងពីតួនាទីនិងសិទ្ធរបស់គាត់នៅក្នុងការចុះឈ្មោះធ្វើអត្តសញ្ញាណប័ណ្ណនិងការបោះឆ្នោត។ ទី១២ មានការជជែកគ្នាអំពីសិទ្ធរបស់ព្រះសង្ឃនៅក្នុងការបោះឆ្នោតដែលនៅក្នុងស្មារតី នៃរដ្ឋធម្មនុញ្ញរបស់ ព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ ដូច្នេះសម្រួលយ៉ាងណាអោយព្រះសង្ឃអាចចុះឈ្មោះបោះឆ្នោតបាននៅក្នុង ដំណើរការ។ ទី១៣ មាកការទទួលស្គាល់ថានៅខេត្តប្រទេសកម្ពុជារបស់យើង ហើយខេត្តរតនៈគីរីក៏បានចូលរួមផងដែរ គឺគណបក្សធំ៧ទាំង៣បានឈានទៅដល់ក៏រិតចាស់ទុំនយោបាយមួយដែលនាំអោយមានស្ថេរភាពនៅក្នុងសង្គមនៅក្នុងនយោបាយ និងនៅក្នុងយន្តការបោះឆ្នោតទាំងមូលផងដែរ។ ចំនែកបញ្ហាដែលនៅសេសសល់ជាបញ្ហាបច្ចេកទេសជាបញ្ហាដើម្បីធ្វើអោយប្រជាពលរដ្ឋលោកយល់ ហើយសម្រួលក្នុងការចុះឈ្មោះនិងការបោះឆ្នោតរបស់ប្រជាពលរដ្ឋជាពិសេសនៅតំបន់ចុងកាត់មាត់ញ៉ែក។ ទី១៤ មិនមែនជាបញ្ហាទេ ក៏ប៉ុន្តែជាការរំភើបដែលក្នុងឋានៈខ្ញុំជាអ្នកសម្របសម្រួលយន្តការខប់សែល ខ្ញុំបាទសូមថ្លែងនូវការរំភើបយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការពិភាក្សាត្រង់ទៅត្រង់មកលើបញ្ហារវាងសមាជិកទាំងអស់របស់អង្គប្រជុំ ហើយគ្មានអ្វីដែលថ្លៃថ្លាគ្មានអ្វីដែលវិសេសវិសាល ជាងអ្វីដែលយើងបានលឺបានឃើញពេញមួយព្រឹកនេះទេ។ ហើយខ្ញុំបាទសន្យាថាអ្វីដែលបានលើកឡើងនឹងជំរាបជូនទៅខាងថ្នាក់ជាតិ និងទៅអង្គការអន្តរជាតិពាក់ព័ន្ធដើម្បីជួយយន្តការបោះឆ្នោតនៅខេត្តរតនៈគីរីនេះអោយបានកាន់តែប្រសើរថែមទៀត នៅប៉ុន្មានថ្ងៃខាងមុខនេះយើងនិងឆ្លងចូលទៅបុណ្យចូលឆ្នាំខ្មែរដែលជាបុណ្យសំខាន់របស់ប្រជាពលរដ្ឋរបស់យើងខ្ញុំបាទសូមបួងសួង ដល់គុណបុណ្យព្រះរតនៈត្រៃ និងទេព្តាទាំងមួយម៉ឺនរូបធាតុសូមលោកជួយថែរក្សាដល់អស់លោកលោកស្រីទាំងអស់និងប្រជាពលរដ្ឋនៅខេត្តរតនៈគីរីនេះអោយបានជួបប្រទះតែនិងសេចក្តីសុខជាពិសេសកុំអោយមានជំងឺឈឺថ្កាត់ និងពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខះ ពលះនិងបណិភាណៈ កុំបីឃ្លាតឃ្លាឡើយ។សូមអរគុណ